ក្រសួងអប់រំ យុវជន និងកីឡា

សម្រាប់លក់

# វិទ្យាសាស្ត្រ

# ជីវវិទ្យា

# ៩



គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

ក្រសួងអប់រំ យុវជន និងកីឡា

# វិទ្យាសាស្ត្រ

## ថ្នាក់ទី ៩

បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៩៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ

| | | |
|---|---|---|
| **គណៈកម្មការនិពន្ធ** | លោក សូ គន្ធី | លោក ហែម សាលី |
| | លោក សួន សុជាតិ | លោកស្រី យឹម យីហ៊ុប |
| | លោកស្រី ហ៊ុយ ចន្ធូ | លោក នី ពុទ្ធី |
| **អ្នកខាយអត្ថបទ** | លោក ហៃ វីរៈ | លោក ចាំន់ ជាតិ |
| **វិចិត្រករ** | លោក តន់ ជាតិ | |
| **អ្នករៀបរៀង** | លោក ស៊ឹម ចាន់ធី | លោក ចាន់ ខេង |
| | លោក វ៉ា វុទ្ធី | លោក ជួន វណ្ណា |
| **អ្នករចនាគំពរ** | លោក គង់ ចិត្រា | |
| **អ្នកឯកទេស** | លោក អ៊ឹង ហេង | |
| **គណៈកម្មការពិនិត្យ** | លោកស្រី អៀម ចាន់ឌី | លោកស្រី អន កិត្យាស៊ី |
| | លោកស្រី អ៊ាន សារិន | លោកស្រី ណារ៉េត ប៉ូលីរីន |

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី **ក្រសួងអប់រំ យុវជន និងកីឡា** តាមប្រកាសលេខ ២១៣ អយក.ប្រក. ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ដើម្បីប្រើប្រាស់នៅតាមសាលារៀន ។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ពផ្សាយ ឆ្នាំ ២០១៨

ISBN 9-789-995-001-346

# អារម្ភកថា

សៀវភៅវិទ្យាសាស្ត្រថ្នាក់ទី១ នេះ គណៈកម្មការនិពន្ធបានរៀបចំចងក្រងឡើងដោយផ្អែកលើកម្មវិធីសិក្សាថ្មី (2006) របស់ក្រសួងអប់រំ យុវជន និងកីឡា។ នៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ មានមុខវិជ្ជារងចំនួនបួន រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យា។

រាល់ខ្លឹមសារមេរៀនដែលមានក្នុងសៀវភៅនេះ អ្នកនិពន្ធបានរៀបចំពីកម្រិតងាយទៅកម្រិតលំបាក ហើយស្របតាមកម្មវិធីសិក្សាថ្មីនិងស្របតាមវិធីវិទ្យាសាស្ត្រ។

គណៈកម្មការនិពន្ធសង្ឃឹមថា សៀវភៅវិទ្យាសាស្ត្រថ្នាក់ទី១នេះនឹងក្លាយជាមិត្តដ៏ល្អរបស់ប្អូនៗសិស្សានុសិស្សជាក់ជាមិនខាន។ ទន្ទឹមគ្នានោះដែរគណៈកម្មការនិពន្ធរីករាយនឹងទទួលយកមតិកែលំអពីសំណាក់ លោកគ្រូ អ្នកគ្រូ និងគ្រប់មជ្ឈដ្ឋាន។

គណៈកម្មការនិពន្ធ

ជំពូក 1 : រស្មីសំយោគ (ជីវវិទ្យា)

1. រូបផ្តុំនៃស្លឹករុក្ខជាតិ 160
2. ដំណើររស្មីសំយោគ 164
3. ដង្ហើមរុក្ខជាតិ 172

ជំពូក 2 : ប្រព័ន្ធប្រសាទ

1. ណឺរ៉ូន 180
2. មជ្ឈមណ្ឌលប្រសាទ 184
3. បរិមណ្ឌលប្រសាទ 190

ជំពូក 3 : ប្រព័ន្ធស៊ាំ

1. កិច្ចការពារសារពាង្គកាយ 198
2. ប្រព័ន្ធស៊ាំ 202

ជំពូក 4 : ភ្នាក់ងារបង្ករោគនិងជំងឺ

1. ភ្នាក់ងារបង្ករោគ 212
2. ជំងឺឆ្លង 222
3. ជំងឺមិនឆ្លង 236

ជំពូក 5 : ផលប៉ះពាល់បណ្តាលមកពីមនុស្សលើឋាន ប្រព័ន្ធធម្មជាតិ

1. អំពើរបស់មនុស្សលើបរិស្ថាន 244
2. ការបំពុលបរិស្ថាន 248

# ជំពូកទី 1 រស្មីសំយោគ




ភាវៈរស់បរជីពមួយចំនួនដូចជា សត្វ មនុស្សមិនអាចបង្កើតអាហារដោយខ្លួនឯងបានទេ។ វាទទួលបានអាហារតាមការស៊ីសារពាង្គកាយដទៃទៀត។ ឯពួកបរជីពមួយចំនួនទៀតដូចជាផ្សិតស្រូបយកអាហារពីសាកសពសារពាង្គកាយផ្សេងទៀត។

រុក្ខជាតិបៃតងជាភាវៈរស់ស្វ័យជីព ព្រោះវាផលិតអាហាររបស់វាដោយផ្ទាល់។ រុក្ខជាតិបៃតងផលិតអាហារតាមរយៈដំណើររស្មីសំយោគ។ តើដំណើររស្មីសំយោគជាអ្វី ?

មេរៀនទី

# 1 រូបផ្គុំនៃស្លឹករុក្ខជាតិ

**ចប់មេរៀននេះ សិស្សអាច**

- ❑ រាប់ឈ្មោះជាលិកាបីប្រភេទនៃរូបផ្គុំក្នុងរបស់ស្លឹក
- ❑ ពណ៌នាពីរូបរាងនិងនាទីនៃជាលិកាប្រភេទនីមួយៗ
- ❑ បង្ហាញពីមូលហេតុដែលធ្វើឱ្យស្លឹកអាចផលិតអាហារបាន ។

ទោះបីជាស្លឹកមានរូបរាងខាងក្រៅខុសគ្នាយ៉ាងណាក៏ដោយ ក៏ស្លឹកទាំងអស់បង្កើតឡើងដោយជាលិកាបីប្រភេទគឺជាលិកាការពារមានអេពីឌែម ជាលិកាគ្រឹះមានមេសូភីល និងជាលិកានាំមានទ្រនុងស្លឹក ។




*រូបទី 1.1 : ខ្នាត់ទទឹងរបស់ស្លឹក*




*រូបទី 1.2 : រូបផ្គុំក្នុងនៃស្លឹករុក្ខជាតិ*

# 1. អេពីឌែម




*រូបទី 1.3 : សកម្មភាពរបស់ស្តូម៉ាត*

ស្រទាប់ក្រៅបង្អស់នៃផ្ទៃស្លឹក ស្រោបទៅដោយសារធាតុម្យ៉ាងភ្លឺរលោង ដែលមានឈ្មោះថា គុយទីគុល ។ ស្រទាប់នេះការពារជាលិកានៃផ្ទៃខាងក្នុងស្លឹក ព្រមទាំងជួយបន្ថយការបាត់បង់ទឹកចេញពីស្លឹក ។ នៅក្រោមគុយទីគុលមានអេពីឌែមដែលជាស្រទាប់កោសិកាមានជាតិពណ៌តិច ឬគ្មានជាតិពណ៌ ។ ស្រទាប់នេះមានលក្ខណៈថ្លាដែលអាចឱ្យពន្លឺព្រះអាទិត្យជ្រៀតចូលដល់កោសិកាស្រទាប់ក្នុង ។ អេពីឌែមកើតឡើងពីកោសិកាមួយស្រទាប់ដែលមានភ្នាសក្រៅក្រាស់ ហើយតម្រៀបកៀកជិតគ្នា ។ អេពីឌែមអាចការពារកោសិកានៅក្នុងស្លឹកឱ្យផុតពីភាពស្ងួតនៅពេលពន្លឺព្រះអាទិត្យក្ដៅខ្លាំង ។

អេពីឌែមផ្ទៃក្រោមស្លឹកមានស្តូម៉ាតច្រើនជាងអេពីឌែមផ្ទៃលើស្លឹក ។ ស្តូម៉ាតនីមួយៗផ្គុំឡើងដោយកោសិកាអេពីឌែមមានឯកទេសកម្មមួយគូដែលមានទ្រង់ទ្រាយដូចគ្រាប់សណ្ដែក វាមានឈ្មោះថាកោសិកាល្បាត ។ នៅចន្លោះកោសិកាល្បាតមានលំហតូចមួយ(ឬអូស្យូល) ។ ស្តូម៉ាតជាកន្លែងធ្វើបណ្ដូរឧស្ម័ន( $CO_2$ និង $O_2$ ) រវាងកោសិកានៅខាងក្នុងស្លឹកនិងមជ្ឈដ្ឋានខាងក្រៅ ។ រំភាយចំហាយទឹកក៏ចេញទៅក្រៅស្លឹកតាមរយៈស្តូម៉ាតនេះដែរ ។ ស្តូម៉ាតមិនមែនបើករាល់ពេលនោះទេ តែវាបើកនិងបិទអាស្រ័យតាមតម្រូវការរបស់ស្លឹកប៉ុណ្ណោះ ប៉ុន្តែស្ថិតនៅក្រោមការត្រួតពិនិត្យរបស់កោសិកាល្បាត ។

# 2. មេសូភីល

នៅចន្លោះអេពីឌែមលើនិងអេពីឌែមក្រោមនៃស្លឹកមានស្រទាប់ជាលិកាជាច្រើន ដែលមានផ្ទុកក្លរ៉ូប្លាសសម្រាប់ធ្វើរស្មីសំយោគ ។ ជាលិកានេះឈ្មោះថា មេសូភីល ។ ចំពោះរុក្ខជាតិមួយចំនួនមេសូភីលបង្កឡើងពីកោសិកាមានភ្នាសស្ដើងពីរប្រភេទ គឺមេសូភីលប៉ាលីសាតនិងមេសូភីលស្ពោត ។ នៅក្រោមអេពីឌែមលើជាស្រទាប់មេសូភីលប៉ាលីសាត ដែលកើតឡើងពីកោសិកាក្រាស់មួយ ឬពីរស្រទាប់ ។ ស្រទាប់នេះកើតឡើងពីកោសិការាងទ្រវែងដែលតម្រៀបកៀកគ្នាយ៉ាងខ្លាំង ។ កោសិកាទាំងនេះផ្ទុកដោយក្លរ៉ូប្លាសយ៉ាងច្រើន ។ ក្រោមស្រទាប់មេសូភីលប៉ាលីសាតជាស្រទាប់មេសូភីលស្ពោតដែលកើតឡើងពីកោសិកាមានទ្រង់ទ្រាយមិនទៀងទាត់ ។ នៅចន្លោះកោសិកាទាំងនេះមានលំហធំៗ

ជាច្រើនសម្រាប់ផ្ទុកឧស្ម័នកាបូនិច។ ផ្ទៃក្រោមនៃស្លឹកនៅជាប់និងលំហចន្លោះកោសិកាមេសូភីលស្ពោត មានស្តូម៉ាតនៃអេពីឌែមផ្ទៃក្រោមស្លឹក។ កោសិកានៃមេសូភីលប៉ាលីសាតមានក្លរ៉ូប្លាសច្រើនជាងកោសិកានៃមេសូភីលស្ពោតដែលធ្វើឱ្យផ្ទៃលើនៃស្លឹករុក្ខជាតិមានពណ៌បៃតងចាស់ ហើយផ្ទៃក្រោមនៃស្លឹកមានពណ៌ខ្ចីជាង។ ប៉ុន្តែរុក្ខជាតិមួយចំនួន កោសិកាមេសូភីលប៉ាលីសាតរបស់ស្លឹកមានចំនួនក្លរ៉ូប្លាសប្រហាក់ប្រហែលគ្នានឹងកោសិកាមេសូភីលស្ពោតដែលធ្វើឱ្យផ្ទៃលើនិងផ្ទៃក្រោមស្លឹករុក្ខជាតិមានពណ៌ដូចគ្នា។ *ឧទាហរណ៍* ស្លឹកស្រូវ ស្លឹកត្រែ ស្លឹកអំពៅ ... ។ ស្លឹកប្រភេទនេះដុះត្រង់ឡើងលើ ដែលធ្វើឱ្យផ្ទៃលើស្លឹកនិងផ្ទៃក្រោមស្លឹកចាប់យកពន្លឺព្រះអាទិត្យបានដូចគ្នា។ ជាតិពណ៌បៃតងនៃស្លឹកជាក្លរ៉ូភីលដែលស្ថិតនៅក្នុងក្លរ៉ូប្លាស។ ក្លរ៉ូភីលកើតឡើងបាន អាស្រ័យទៅនឹងពន្លឺព្រះអាទិត្យ ដូចនេះបើរុក្ខជាតិដុះនៅកន្លែងខ្វះពន្លឺព្រះអាទិត្យ ស្លឹករុក្ខជាតិនឹងប្រែពីពណ៌បៃតងទៅជាពណ៌លឿង មួយរយៈពេលក្រោយមករុក្ខជាតិនិងអាចងាប់បាន។

ស្រទាប់មេសូភីលមាននាទីចាប់យកពន្លឺព្រះអាទិត្យស្តុកទុកនិងធ្វើបណ្តូរឧស្ម័នរវាងកោសិកាក្នុងផ្ទៃស្លឹក និងមជ្ឈដ្ឋានខាងក្រៅដើម្បីផលិតអាហារសម្រាប់រុក្ខជាតិតាមរយៈរស្មីសំយោគ។

## 3. ទ្រនុងស្លឹក

ទ្រនុងស្លឹកកើតឡើងពីជាលិកានាំពីរប្រភេទគឺ ស៊ីឡែម និងផ្លូអែម។ ស៊ីឡែមដឹកនាំទឹកនិងអំបិលខនិជរលាយពីឫសទៅស្លឹក។ ផ្លូអែមដឹកនាំអាហារដែលផលិតដោយរស្មីសំយោគទៅឱ្យគ្រប់ផ្នែកទាំងអស់នៃរុក្ខជាតិ ដើម្បីចិញ្ចឹមផ្នែកទាំងនោះ។ ស៊ីឡែមនិងផ្លូអែមរបស់ទ្រនុងស្លឹកបន្តពីស៊ីឡែមនិងផ្លូអែមរបស់ដើមនិងឫស។ ទ្រនុងស្លឹកម៉ូណូកូទីលេដូន តម្រៀបខុសគ្នាពីទ្រនុងស្លឹកឌីកូទីលេដូន។ ចំពោះស្លឹកម៉ូណូកូទីលេដូន ទ្រនុងចំៗតម្រៀបស្របគ្នាតាមបណ្តោយស្លឹក។ ចំណែកស្លឹកឌីកូទីលេដូនវិញ ទ្រនុងស្លឹកតម្រៀបជាបណ្តាញមួយបែកខ្នែងពេញផ្ទៃស្លឹក។




*រូបទី 1.1 : ប្រភេទទ្រនុងស្លឹក*

## មេរៀនសង្ខេប

- រូបផ្ចុំក្នុងរបស់ស្លឹកបង្កើតឡើងពី :
  - អេពីដែមគ្របដណ្ដប់ដោយសារធាតុភ្លឺរលោងគឺគុយទីគុល ។ ក្នុងអេពីដែមរបស់ស្លឹក មានស្ដូម៉ាតច្រើន ។ ស្ដូម៉ាតជាកន្លែងធ្វើបណ្ដូរឧស្ម័នរវាងកោសិកានៅខាងក្នុងស្លឹក និង មជ្ឈដ្ឋានក្រៅ ។
  - នៅចន្លោះអេពីដែមលើ និងអេពីដែមក្រោមនៃស្លឹក មានស្រទាប់ជាលិកាមេសូភីល ។ មេសូភីលបង្កឡើងពីកោសិកាពីរប្រភេទ គឺមេសូភីលប៉ាលីសាតនិងមេសូភីលស្ពោត ។ មេសូភីលប៉ាលីសាតមានផ្ទុកក្លរ៉ូប្លាសច្រើនជាងមេសូភីលស្ពោត ។ ដំណើររស្មីសំយោគ ប្រព្រឹត្តទៅនៅក្នុងស្រទាប់ជាលិកាមេសូភីល ។
  - នៅក្នុងស្រទាប់មេសូភីលមានបណ្ដាញទ្រនុងស្លឹក ។ ទ្រនុងស្លឹកកើតឡើងពីជាលិកានាំ ពីរប្រភេទគឺ ស៊ីឡែម និងផ្លូអែម ។
- ទ្រនុងស្លឹកម៉ូណូកូទីលេដូន តម្រៀបស្របគ្នាតាមបណ្ដោយស្លឹក ។
- ទ្រនុងស្លឹកឌីកូទីលេដូន តម្រៀបបែកខ្នែងជាបណ្ដាញមួយនៅពេញផ្ទៃស្លឹក ។

## សំណួរ

1. តើនាទីចម្បងរបស់ស្លឹកគឺអ្វី ?
2. តើរូបផ្ចុំក្នុងរបស់ស្លឹកមានជាលិកាប៉ុន្មានប្រភេទ ? អ្វីខ្លះ ?
3. ចូរពណ៌នាពីនាទីនៃប្រភេទជាលិកានីមួយៗ នៃរូបផ្ចុំក្នុងរបស់ស្លឹក ។
4. តើស្រទាប់មេសូភីលមានលក្ខណៈពិសេសអ្វីដែលធ្វើឱ្យស្រទាប់នេះមាននាទីផលិតអាហារ សម្រាប់រុក្ខជាតិ ?
5. តើប្រភេទជាលិកាអ្វីនៃរូបផ្ចុំក្នុងរបស់ស្លឹកដែលមានស្ដូម៉ាត ?
6. តើស្ដូម៉ាតមាននាទីអ្វី ? តើលក្ខណៈពិសេសអ្វីដែលធ្វើឱ្យវាមាននាទីនេះ ?
7. ហេតុអ្វីបានជាស្លឹករុក្ខជាតិភាគច្រើន ផ្ទៃលើស្លឹកមានពណ៌បៃតងចាស់ជាងផ្ទៃក្រោមស្លឹក ?
8. ហេតុអ្វីបានជាពន្លឺព្រះអាទិត្យអាចជ្រៀតចូលដល់កោសិកាស្រទាប់ក្នុងរបស់ស្លឹកបាន ?
9. ចូរប្រៀបធៀបការតម្រៀបនៃទ្រនុងស្លឹកម៉ូណូកូទីលេដូននិងទ្រនុងស្លឹកឌីកូទីលេដូន ។

# 2 ដំណើររស្មីសំយោគ

**ចប់មេរៀននេះ សិស្សអាច**

- ពន្យល់ពាក្យ រស្មីសំយោគ
- បកស្រាយពីដំណាក់កាលទាំងពីរនៃដំណើររស្មីសំយោគ
- រៀបរាប់ពីកត្តាផ្សេងៗដែលជះឥទ្ធិពលទៅលើដំណើររស្មីសំយោគ
- មានស្មារតីចូលរួមថែរក្សាធម្មជាតិ ជាពិសេសរុក្ខជាតិ ។

តាមធម្មតា ដើមឈើមានស្លឹកគ្របដណ្ដប់ពេញមួយឆ្នាំ ។ រៀងរាល់ឆ្នាំស្លឹកឈើប្រែពណ៌ពីបៃតងទៅលឿង ហើយទុំជ្រុះធ្លាក់មកលើដី ។

ប្រសិនបើ គេបេះស្លឹកឈើទាំងអស់ពីដើមឈើដោយមិនឱ្យវាមានស្លឹករយៈពេលមួយឆ្នាំ តើដើមឈើទាំងអស់នោះអាចរស់បានដោយគ្មានស្លឹកដែរឬទេ ? វាមិនអាចរស់បានទេ ។ ស្លឹកឈើគឺជាសរីរាង្គសំខាន់ណាស់ក្នុងការផលិតអាហារសម្រាប់រុក្ខជាតិ ។ អាហារទាំងនេះត្រូវបានប្រើប្រាស់ដោយកោសិកាទាំងអស់នៃរុក្ខជាតិ ។ តើដើមអាចរស់បានដោយគ្មានអាហារដែរឬទេ ?

## 1. រុក្ខជាតិជាប្រភពអាហាររបស់ភាវៈរស់

មនុស្សខ្លះមានជំនឿថា រុក្ខជាតិទទួលបានអាហារពីដី ។ ដោយរុក្ខជាតិលូតលាស់ធំហើយខ្ពស់ពីលើដី មនុស្សក៏គិតថានេះជាលទ្ធផលនៃអាហារដែលរុក្ខជាតិស្រូបយកពីដី ។ តែយ៉ាងណាក៏ដោយការពិសោធបានបង្ហាញថា រុក្ខជាតិលូតលាស់ធំនិងខ្ពស់ទៅៗ តែបរិមាណដីស្ថិតនៅដដែល ។ យើងបានដឹងថា ស្លឹកជាផ្នែកមួយយ៉ាងសំខាន់របស់រុក្ខជាតិក្នុងការផលិតអាហារ ។

រុក្ខជាតិបៃតងជាអ្នកផលិតអាហារដ៏សំខាន់ សម្រាប់គ្រប់ភាវៈរស់ទាំងអស់នៅលើផែនដី ។ អាហារដែលប្រើប្រាស់ញឹកញាប់បំផុតគឺ គ្លុយកូស ។ គ្លុយកូសជាសារធាតុសរីរាង្គសំខាន់ ព្រោះវាផ្ទុកថាមពលគីមី ។

ភាវៈរស់បរជីពដូចជាមនុស្ស សត្វ មិនអាចផលិតអាហារដោយខ្លួនឯងបានឡើយ ។ វាទទួលបានអាហារតាមការស៊ីសារពាង្គកាយដទៃទៀត ។ ឯពួកបរជីពមួយចំនួនទៀតដូចជាផ្សិតស្រូបយកអាហារពីកាកសំណល់និងសាកសពសារពាង្គកាយផ្សេងៗទៀត ។

រុក្ខជាតិបៃតងជាភាវៈរស់ស្វ័យជីព ព្រោះវាអាចផលិតអាហារដោយខ្លួនឯងបាន ។ រុក្ខជាតិផលិតអាហារតាមរយៈដំណើររស្មីសំយោគ ។ តើរស្មីសំយោគជាអ្វី ?

## 2. ដំណើររស្មីសំយោគ

រុក្ខជាតិបៃតងចាប់យកថាមពលពន្លឺព្រះអាទិត្យ ហើយប្រើប្រាស់ថាមពលនេះដើម្បីផលិតអាហារ ដំណើរបែបនេះហៅថា ដំណើររស្មីសំយោគ ។ ដំណើររស្មីសំយោគ អាចកើតមានក្នុងគ្រប់កោសិការុក្ខជាតិដែលផ្ទុកក្លរ៉ូភីល ។ ចំពោះរុក្ខជាតិថ្នាក់ខ្ពស់ រស្មីសំយោគកើតមាននៅក្នុងសរីរាង្គពិសេសមួយគឺស្លឹក ។

រស្មីសំយោគគឺជាដំណើរមួយស្មុគស្មាញ ។ ពេលធ្វើរស្មីសំយោគ រុក្ខជាតិប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ ដើម្បីបំប្លែងឧស្ម័នកាបូនិច ($CO_2$) និងទឹក ($H_2O$) ឱ្យទៅជាឧស្ម័នអុកស៊ីសែន ($O_2$) និងស្ករងាយ គឺគ្លុយកូស ($C_6H_{12}O_6$) ។ ដំណើររស្មីសំយោគមានពីរដំណាក់កាលគឺ ការចាប់យកថាមពលពន្លឺព្រះអាទិត្យនិងការផលិតស្ករ ។

- **ការចាប់យកថាមពលពន្លឺព្រះអាទិត្យ**

រុក្ខជាតិមានពណ៌បៃតង ព្រោះវាផ្ទុកសារធាតុគីមីម្យ៉ាងឈ្មោះថាក្លរ៉ូភីល ។ កោសិកាស្លឹកនិងកោសិកាដើមរុក្ខជាតិមួយចំនួនមានផ្ទុកសារធាតុគីមីនេះ ។ វាជាសារធាតុគីមីចាំបាច់បំផុតសម្រាប់ដំណើររស្មីសំយោគ ។

ចំពោះរុក្ខជាតិថ្នាក់ខ្ពស់ភាគច្រើន ការចាប់យកថាមពលពន្លឺព្រះអាទិត្យកើតមាននៅក្នុងស្លឹកតែប៉ុណ្ណោះ ។ រុក្ខជាតិប្រើប្រាស់ក្លរ៉ូភីលដែលជាជាតិពណ៌បៃតងនៅក្នុងស្លឹក ដើម្បីចាប់យកថាមពលពន្លឺព្រះអាទិត្យ ។

- **ការផលិតស្ករ (គ្លុយកូស)**

នៅក្នុងដំណាក់កាលនេះ រុក្ខជាតិត្រូវការរូបធាតុដើមពីរគឺទឹក ($H_2O$) និងឧស្ម័នកាបូនិច ($CO_2$) ។ ឫសស្រូបយកទឹកពីក្នុងដី បន្ទាប់មកទឹកធ្វើចលនាឡើងតាមដើមឆ្ពោះទៅស្លឹករុក្ខជាតិតាមស៊ីឡែម ។ ចំណែក $CO_2$ នៅក្នុងបរិយាកាសសាយចូលទៅក្នុងរុក្ខជាតិតាមរន្ធចំហតូចៗដែលស្ថិតនៅផ្នែកខាងក្រោមផ្ទៃស្លឹកហៅថា ស្តូម៉ាត ។ ក្នុងស្លឹក $H_2O$ និង $CO_2$ ធ្វើដំណើរទៅកាន់ក្លរ៉ូប្លាស ដែលមានផ្ទុកក្លរ៉ូភីល ។ បន្ទាប់មករុក្ខជាតិប្រើប្រាស់ថាមពលដែលក្លរ៉ូភីលចាប់បានជួយដល់ការភ្ជាប់ $CO_2$ និង $H_2O$ ដើម្បីផលិតស្ករម្យ៉ាងហៅថា គ្លុយកូស និងបំភាយឧស្ម័នអុកស៊ីសែន ($O_2$) ។

ដំណើររស្មីសំយោគអាចសង្ខេបបានតាមសមីការគីមីដូចខាងក្រោម :

$$6CO_2 + 12H_2O \xrightarrow[\text{ក្លរ៉ូភីល}]{\text{ថាមពលពន្លឺព្រះអាទិត្យ}} C_6H_{12}O_6 + 6O_2\uparrow + 6H_2O$$

ឧស្ម័នកាបូនិច ទឹក គ្លុយកូស អុកស៊ីសែន ទឹក




*រូបទី 2.1 : ដំណើររស្មីសំយោគ*

គ្លុយកូសជាផលិតផលសំខាន់នៃដំណើររស្មីសំយោគ ។ រុក្ខជាតិប្រើប្រាស់គ្លុយកូសសម្រាប់បង្កើតសមាសធាតុសរីរាង្គសំខាន់ដទៃទៀតដូចជា សែលុយឡូស លីពីត ប្រូតេអ៊ីន ... ។ គ្លុយកូសដែលលើសពីតម្រូវការបំប្លែងទៅជាអាមីដុង ហើយស្តុកទុកក្នុងឫស ។

ផលិតផលមួយផ្សេងទៀតនៃរស្មីសំយោគគឺអុកស៊ីសែន ($O_2$) ។ អុកស៊ីសែននេះភាយចេញពីស្លឹកតាមស្តូម៉ាត ។ អុកស៊ីសែនស្ទើរទាំងអស់នៅក្នុងបរិយាកាសនៃផែនដីត្រូវបានផលិតឡើងដោយរុក្ខជាតិបៃតង តាមដំណើររស្មីសំយោគ ។

ក្នុងដំណើររស្មីសំយោគ ថាមពលពន្លឺព្រះអាទិត្យដែលស្រូបបានត្រូវប្លែងទៅជាថាមពលគីមីចាំបាច់ក្នុងការសំយោគគ្លុយកូស ។

# 3. ការសំយោគគ្លុយកូស(អាមីដុង)ដោយរុក្ខជាតិបៃតង

## 3.1. ពិសោធន៍ទី 1

- យកបន្ទះកំណាត់ខ្មៅទៅបាំងផ្នែកណាមួយលើផ្ទៃទាំងសងខាងរបស់ស្លឹក ហើយយករុក្ខជាតិនេះទៅដាក់ក្រោមពន្លឺព្រះអាទិត្យក្នុងរយៈពេលបីថ្ងៃ (រូប ក) ។
- បន្ទាប់មកយកកន្ត្រៃកាត់ស្លឹកឈើចេញពីដើម ព្រមទាំងយកកំណាត់ខ្មៅចេញពីស្លឹក ។ យកកែវដែលមានទឹកជិតពេញ ដាក់លើចង្ក្រានរួចដុតភ្លើងតិចៗរហូតដល់ពុះ ។ ប្រើតង្កៀបចាប់យកបំពង់កែវក្រិតដែលមានអាល់កុលប្រហែល 100 មីលីលីត្រទៅដាក់ក្នុងកែវទឹកពុះ (ដែលបានរៀបរាប់ខាងលើ) រហូតដល់អាល់កុលក្នុងបំពង់កែវក្រិតពុះ ។ បន្ទាប់មកទើបប្រើតង្កៀបចាប់យកស្លឹកទៅដាក់ក្នុងអាល់កុលដែលកំពុងពុះនោះឱ្យបានប្រហែល 30 នាទី ដើម្បីដកយកក្លរ៉ូភីលចេញពីស្លឹក(រូប ខ) ។ បន្ទាប់មកប្រើតង្កៀបចាប់យកស្លឹកចេញពីបំពង់កែវក្រិតដែលមានអាល់កុលកំពុងពុះនោះ ទៅដាក់លាងសំអាតក្នុងកែវទឹកក្តៅឧណ្ហៗ (រូប គ) ។

- ប្រើតង្កៀបចាប់យកស្លឹកចេញពីកែវទឹកក្ដៅឧណ្ហៗទៅដាក់ក្នុងទឹកអ៊ីយ៉ូតវិញ ។ យើងសង្កេតឃើញថា ផ្នែកមិនបាំងបន្ទះកំណាត់ពណ៌ខ្មៅមានពណ៌ស្វាយ នេះបញ្ជាក់ថាមានអាមីដុង ។ ផ្នែកមានបាំងបន្ទះកំណាត់ពណ៌ខ្មៅគ្មានពណ៌ បញ្ជាក់ថាគ្មានអាមីដុង ។ ស្លឹកមានអាមីដុងនៅផ្នែកមិនបាំងបន្ទះកំណាត់ពណ៌ខ្មៅបញ្ជាក់ថារស្មីសំយោគកើតមានឡើងនៅកន្លែងនោះ (រូប ឃ) ។




*រូបទី 2.2 : ការបញ្ជាក់ពីវត្តមានអាមីដុងនៅក្នុងស្លឹក*

## 3.2. ពិសោធន៍ទី 2

យករុក្ខជាតិមួយដែលបណ្ដុះក្នុងផើងទៅដាក់ក្នុងទីងងឹតឬរុំឱ្យជិតជាមួយស្បោងប្លាស្ទិចពណ៌ខ្មៅក្នុងរយៈពេលប្រហែលបីថ្ងៃដោយមិនឱ្យត្រូវពន្លឺ ។ បន្ទាប់មកយកកន្ត្រៃកាត់ស្លឹកឈើចេញពីដើម រួចយកស្លឹកនោះទៅដាក់ក្នុងទឹកអ៊ីយ៉ូត ។ ស្លឹកមិនប្រែទៅជាពណ៌ស្វាយទេ នេះបញ្ជាក់ឱ្យដឹងថាគ្មានវត្តមានអាមីដុងក្នុងស្លឹកទេ ។ ដូចនេះស្លឹកត្រូវការពន្លឺព្រះអាទិត្យដើម្បីផលិតអាហារ ។

# 4. បណ្ដូរឧស្ម័នរវាងរុក្ខជាតិបៃតងនិងបរិស្ថានខាងក្រៅ

ចំពោះរុក្ខជាតិ ឧស្ម័នកាបូនិចជាវត្ថុធាតុដើមសម្រាប់ដំណើររស្មីសំយោគ ហើយឧស្ម័នអុកស៊ីសែន គឺជាផលិតផលចុងក្រោយដែលត្រូវភាយទៅក្នុងបរិយាកាស ។ ដូចនេះបណ្ដូររូបធាតុចំពោះរុក្ខជាតិ គឺការស្រូបយកឧស្ម័នកាបូនិចពីបរិយាកាសនិងការភាយឧស្ម័នអុកស៊ីសែនទៅក្នុងបរិយាកាសវិញ ។ បណ្ដូរឧស្ម័ននេះកើតឡើងបានតែនៅក្នុងសរីរាង្គរបស់រុក្ខជាតិដែលធ្វើរស្មីសំយោគនៅពេលមានរស្មីពន្លឺប៉ុណ្ណោះ ។

## 4.1. ក្រោមពន្លឺព្រះអាទិត្យរុក្ខជាតិបៃតងភាយឧស្ម័នអុកស៊ីសែន ($O_2$)




*រូបទី 2.3 : ការបញ្ជាក់ពីរុក្ខជាតិបៃតងបញ្ចេញឧស្ម័នអុកស៊ីសែន ($O_2$) ក្រោមពន្លឺព្រះអាទិត្យ*

ពិសោធន៍បង្ហាញឱ្យឃើញពីការភាយអុកស៊ីសែន ($O_2$) របស់រុក្ខជាតិ

- យកចកកន្ទុយឆ្កែ(ឬរុក្ខជាតិទឹកផ្សេងទៀត)ដាក់ក្នុងជើងកែវ(ក)និងជើងកែវ(ខ)ដែលមានដាក់ទឹកធម្មតា ។ យកបំពង់កែវក្រិតពេញដោយទឹកគ្របពីលើចកកន្ទុយឆ្កែទាំងពីរជើង ប៉ុន្តែធ្វើយ៉ាងណាកុំឱ្យឧស្ម័នបរិយាកាសចូលបាន ដើម្បីងាយស្រួលដល់ការប្រមូលឧស្ម័នដែលភាយចេញពីចកកន្ទុយឆ្កែ ។
- យកជើងកែវ (ក)ដាក់ក្នុងទីងងឹតឬរុំវាឱ្យជិតជាមួយស្បោងក្រដាសខ្មៅ ។
- យកជើងកែវ (ខ)ដាក់នៅក្រោមពន្លឺព្រះអាទិត្យ ។
- ប្រាំមួយម៉ោងក្រោយមក គេឃើញមានពពុះជាច្រើនភាយចេញពីចកកន្ទុយឆ្កែនៅក្នុងជើងកែវ(ខ)រួចអណ្ដែតឡើងលើនៅពេញបាតបំពង់កែវក្រិត ។ ចំណែកចកកន្ទុយឆ្កែនៅជើងកែវ (ក) មិនមានពពុះភាយចេញទេ ។

- ឧស្ម័នដែលភាយចេញពីចកកន្ទុយឆ្កែនៅផើងកែវ (ខ)ធ្វើឱ្យគ្រាប់ឈើគូសដែលមានតែរងើកឆេះច្រាលជាអណ្តាតភ្លើងឡើងវិញ ។ នេះបញ្ជាក់ឱ្យដឹងថា ក្នុងកែវគ្រិតមានវត្តមានឧស្ម័នអុកស៊ីសែន ($O_2$) (រូប គ) ។

ដូចនេះ ក្រោមពន្លឺព្រះអាទិត្យរុក្ខជាតិបៃតងធ្វើរស្មីសំយោគ ហើយភាយឧស្ម័នអុកស៊ីសែន ($O_2$) ។

## 4.2. ក្រោមពន្លឺព្រះអាទិត្យរុក្ខជាតិបៃតងស្រូបយកឧស្ម័នកាបូនិច ($CO_2$)

យើងដឹងហើយថា ក្នុងស្រទាប់កោសិកាមេសូភីលស្ពោតមានលំហជាច្រើនដែលមាននាទីផ្ទុកឧស្ម័នកាបូនិចនៃបរិយាកាស ។ តើស្លឹករុក្ខជាតិត្រូវការឧស្ម័នអ្វីពីបរិយាកាសដើម្បីសំយោគអាមីដុង ?

## 4.3. ពិសោធន៍




*រូបទី 2.4 : ការបញ្ជាក់រុក្ខជាតិបៃតងស្រូបយកឧស្ម័នកាបូនិច ($CO_2$) ក្រោមពន្លឺព្រះអាទិត្យ*

- យកផើង(ក)និងផើង(ខ)ដែលមានដាំរុក្ខជាតិទៅដាក់លើថាសកញ្ចក់សើមមួយ ដោយមានគ្របកែវគ្រុងថ្លាទៅលើផើងទាំងពីរនេះ ។ ប៉ុន្តែនៅក្នុងកែវគ្រុង(ក)មានដាក់បន្ថែមកែវទឹកកំបោរថ្លា ដើម្បីឱ្យវាស្រូបយកឧស្ម័នកាបូនិចដែលមាននៅក្នុងកែវគ្រុងនោះ ។ បន្ទាប់មកយកផើងនិងកែវគ្រុង(ក)និង(ខ) ដែលបានរៀបចំរួចនោះទៅដាក់ក្នុងទីងងឹតរយៈពេលពីរឬបីថ្ងៃដើម្បីកុំឱ្យមានវត្តមានអាមីដុងនៅក្នុងស្លឹកទៀត ។

- យកផើងនិងកែវគ្រុង(ក)និង(ខ)ចេញពីទីងងឹតទៅដាក់ក្រោមពន្លឺព្រះអាទិត្យ ។ រយៈពេល 5ទៅ 6ម៉ោងក្រោយមក យកកែវគ្រុងចេញពីផើងរុក្ខជាតិ ហើយប្រើកន្ត្រៃកាត់ស្លឹកពីដើមរុក្ខជាតិរបស់ផើងទាំងពីរនេះ ទៅដាក់ក្នុងចានទឹកអ៊ីយ៉ូត(កនិងខ)ផ្សេងគ្នា ។ ទឹកអ៊ីយ៉ូតក្នុងចាន(ក) មិនធ្វើឱ្យស្លឹកប្រែពណ៌ទេ ។ ចំណែកទឹកអ៊ីយ៉ូតនៅចាន(ខ)ធ្វើឱ្យស្លឹកប្រែពណ៌ ។ នេះបញ្ជាក់ថាស្លឹករុក្ខជាតិនៅផើង(ខ)មានអាមីដុង ។

ដូចនេះ ក្រោមពន្លឺព្រះអាទិត្យរុក្ខជាតិបៃតងស្រូបយកឧស្ម័នកាបូនិច($CO_2$ )ដើម្បីផលិតអាហារ(អាមីដុង) ។

## 5. កត្តាផ្សេងៗមានឥទ្ធិពលនៅលើដំណើររស្មីសំយោគ

កត្តាមួយចំនួនដែលជះឥទ្ធិពលទៅលើល្បឿនរស្មីសំយោគមាន សីតុណ្ហភាព ទឹក ពន្លឺ ឧស្ម័នកាបូនិច និងសារធាតុខនិជ ។

- ពន្លឺមានសារៈសំខាន់ចំពោះដំណើររស្មីសំយោគ ។ ប៉ុន្តែតម្រូវការពន្លឺព្រះអាទិត្យរបស់រុក្ខជាតិមិនដូចគ្នាទេ ។ រុក្ខជាតិមួយចំនួនអាចដុះលូតលាស់បានតែនៅក្នុងមជ្ឈដ្ឋានដែលមានពន្លឺព្រះអាទិត្យខ្លាំង បើខ្វះថាមពលពន្លឺព្រះអាទិត្យ រុក្ខជាតិទាំងនេះនឹងក្លាយទៅជាពណ៌លឿង ហើយអាចនឹងងាប់បានដូចជា ពោត ស្រូវ ដំឡូង ... ដែលជាប្រភេទរុក្ខជាតិត្រូវការពន្លឺព្រះអាទិត្យ ។ រុក្ខជាតិមួយចំនួនទៀតអាចដុះលូតលាស់ក្នុងម្លប់មានដើមម្លូ ជីក្តូ អ័រគីដេ ... ដែលជារុក្ខជាតិត្រូវការថាមពលពន្លឺព្រះអាទិត្យតិចតួច ។
- ទឹកមានបរិមាណច្រើនជាងគេបំផុតនៅក្នុងរុក្ខជាតិ ។ ទឹកជារូបធាតុចាំបាច់ចំពោះរុក្ខជាតិក្នុងដំណើររស្មីសំយោគ ។ ទឹកក៏ជាមធ្យោបាយនៃដំណឹកនាំរូបធាតុទាំងអស់នៅក្នុងរុក្ខជាតិនិងចូលរួមតម្រូវសីតុណ្ហភាពដល់រុក្ខជាតិ ។ ដំណើររស្មីសំយោគអាចឈប់ធ្វើសកម្មភាពនៅពេលមានកង្វះទឹកឬទឹកច្រើនហួស ។
- រុក្ខជាតិអាចធ្វើរស្មីសំយោគក្នុងកម្រិតធម្មតារបស់ឧស្ម័នកាបូនិចគឺ 0.03% នៃឧស្ម័នក្នុងបរិយាកាស ។ បរិមាណឧស្ម័នកាបូនិចកើន ផលិតផលនៃរស្មីសំយោគក៏កើនឡើងដែរ ប៉ុន្តែបើឧស្ម័នកាបូនិចកើនដល់កម្រិត 0.20% នៃឧស្ម័នបរិយាកាស រុក្ខជាតិនឹងអាចងាប់បាន ។
- តាមធម្មតាដំណើររស្មីសំយោគអាចប្រព្រឹត្តទៅបានក្នុងសីតុណ្ហភាពមួយសមស្រប(ចាប់ពី 20°C ទៅ 30°C ) ។ នៅសីតុណ្ហភាពទាបខ្លាំងឬខ្ពស់ខ្លាំង(ក្រោម 0°C ឬលើសពី 35°C )ដំណើររស្មីសំយោគថយចុះឬអាចឈប់បាន ព្រោះក្លរ៉ូប្លាសត្រូវបានបំផ្លាញ ។
- កង្វះសារធាតុខនិជជះឥទ្ធិពលទៅលើដំណើររស្មីសំយោគនិងលំនាំមេតាបូលីសផ្សេងៗទៀតរបស់រុក្ខជាតិ ។

## មេរៀនសង្ខេប

- ដំណើរដែលរុក្ខជាតិបៃតងផលិតអាហារហៅថា រស្មីសំយោគ ។
- ក្នុងដំណើររស្មីសំយោគមានពីរដំណាក់កាលគឺការស្រូបយកថាមពលពីពន្លឺព្រះអាទិត្យនិងការផលិតអាហារ(គ្លុយកូស) ។
- ដំណើររស្មីសំយោគត្រូវមានលក្ខខណ្ឌពីរគឺពន្លឺព្រះអាទិត្យនិងក្លរ៉ូភីលដែលជាជាតិពណ៌បៃតងក្នុងក្លរ៉ូប្លាស ។ ក្លរ៉ូភីលមាននាទីស្រូបយកថាមពលពន្លឺព្រះអាទិត្យ ។
- រូបធាតុដើមសម្រាប់រុក្ខជាតិបៃតងធ្វើរស្មីសំយោគគឺឧស្ម័នកាបូនិចនិងទឹក ។
- ផលិតផលរបស់រស្មីសំយោគគឺគ្លុយកូសនិងអុកស៊ីសែន ។
- សមីការគីមីនៃដំណើររស្មីសំយោគ

$$6CO_2 + 12H_2O \xrightarrow[\text{ក្លរ៉ូភីល}]{\text{ថាមពលពន្លឺព្រះអាទិត្យ}} C_6H_{12}O_6 + 6O_2\nearrow + 6H_2O$$

ឧស្ម័នកាបូនិច ទឹក គ្លុយកូស អុកស៊ីសែន ទឹក

- រុក្ខជាតិជាច្រើនបំប្លែងគ្លុយកូសដែលផលិតបាននៅពេលរស្មីសំយោគ ឱ្យទៅជាអាមីដុង ។
- កត្តាផ្សេងៗមានឥទ្ធិពលទៅលើដំណើររស្មីសំយោគមាន ពន្លឺព្រះអាទិត្យ ទឹក បរិមាណឧស្ម័នកាបូនិច សីតុណ្ហភាព និងសារធាតុខនិជ ។

## សំណួរ

1. ចូរពន្យល់ពាក្យ រស្មីសំយោគ ។
2. តើរូបធាតុដើមពីរសម្រាប់ធ្វើរស្មីសំយោគគឺអ្វីខ្លះ ?
3. តើថាមពលដែលប្រើសម្រាប់ដំណើររស្មីសំយោគជាថាមពលអ្វី ?
4. តើឧស្ម័នអ្វីដែលចូលរួមក្នុងដំណើររស្មីសំយោគ ?
5. តើផលិតផលដែលបានមកពីដំណើររស្មីសំយោគគឺអ្វីខ្លះ ?
6. តើដំណើររស្មីសំយោគបញ្ចេញឧស្ម័នអ្វី ?
7. តើធាតុពណ៌បៃតងដែលនៅក្នុងស្លឹកមានឈ្មោះអ្វី ?
8. ចូរសរសេរសង្ខេបសមីការនៃដំណើររស្មីសំយោគ ។
9. តើអាហារដែលរុក្ខជាតិបៃតងផលិតបានត្រូវដឹកនាំទៅកន្លែងណា ?
10. តើកត្តាអ្វីខ្លះដែលជះឥទ្ធិពលទៅលើដំណើររស្មីសំយោគ ?

មេរៀនទី

# 3 ដង្ហើមរុក្ខជាតិ

ចប់មេរៀននេះ សិស្សអាច

- បកស្រាយពីដំណាក់កាលទាំងពីរនៃដំណើរដង្ហើមរុក្ខជាតិ
- ប្រៀបធៀបដំណើរដង្ហើមរុក្ខជាតិនិងដំណើររស្មីសំយោគ
- ពណ៌នាពីការផ្ទេរថាមពលរបស់ភាវៈរស់
- បណ្តុះស្មារតីសិស្សឱ្យចេះថែរក្សានិងការពាររុក្ខជាតិ ។

រុក្ខជាតិបែតងដកដង្ហើមទាំងថ្ងៃទាំងយប់ ។ ប៉ុន្តែនៅពេលគ្មានពន្លឺព្រះអាទិត្យគឺនៅពេលដំណើររស្មីសំយោគផ្អាកសកម្មភាព ពេលនោះនៅសល់តែដំណើរដង្ហើមរបស់រុក្ខជាតិប៉ុណ្ណោះ ។ គ្រប់សរីរាង្គរបស់រុក្ខជាតិ (ឫស ដើម ស្លឹក ផ្កា ផ្លែ គ្រាប់)ចូលរួមក្នុងដំណើរដង្ហើមនិងបណ្តូរឧស្ម័នដោយផ្ទាល់ជាមួយមជ្ឈដ្ឋានខាងក្រៅ ។

ដូចនេះយើងអាចបង្កើនសំណើមនៅលើដីស្រទាប់លើដោយស្រោចទឹក ។ យើងអាចធ្វើឱ្យដីស្រទាប់លើផុសដោយការកាប់គាស់ឬភ្ជួរ ។ ការបាចអង្កាម កំទេចថ្ម ឬធ្យូងក៏ជួយឱ្យដីផុសផងដែរ ។ សកម្មភាពនីមួយៗក្នុងចំណោមសកម្មភាពទាំងនេះនឹងជួយបង្កើនដំណើរខ្យល់ (បរិមាណអុកស៊ីសែននៅក្នុងដី) ដើម្បីឱ្យរុក្ខជាតិដកដង្ហើមបានងាយស្រួល ។ តើរុក្ខជាតិដកដង្ហើមយ៉ាងដូចម្តេច ?

## 1. ដង្ហើមរុក្ខជាតិ

ដង្ហើមរុក្ខជាតិជាដំណើរការមួយដែលរុក្ខជាតិបែតងទទួលបានថាមពលពីម៉ូលេគុលគ្លុយកូស ។ ក្នុងដំណើរដង្ហើម រុក្ខជាតិបំបែកអាហារ(ដូចជាគ្លុយកូស) ហើយបញ្ចេញថាមពលដែលស្តុកទុកក្នុងម៉ូលេគុលអាហារនោះ ។ ដង្ហើមប្រព្រឹត្តទៅក្នុងគ្រប់កោសិការបស់ភាវៈរស់ ។

តើក្នុងដំណើរដង្ហើម រុក្ខជាតិបានគ្លុយកូសមកពីណា ?

ក្នុងដំណើររស្មីសំយោគ រុក្ខជាតិបែតងចាប់យកថាមពលពន្លឺព្រះអាទិត្យ ហើយរក្សាថាមពលនេះទុកក្រោមទម្រង់ជាគ្លុយកូស រួមមានស្ករនិងអាមីដុង ។ ពេលណារុក្ខជាតិត្រូវការថាមពល វាទាញយកថាមពលដែលស្តុកទុកនោះមកប្រើប្រាស់តាមរយៈការបំបែកគ្លុយកូសក្នុងដំណើរដង្ហើម ។

## 1.1. ដំណាក់កាលទាំងពីរនៃដង្ហើមរុក្ខជាតិ

### ក. ដំណាក់កាលទី 1

ដំណាក់កាលទី 1 ប្រព្រឹត្តទៅនៅក្នុងស៊ីតូប្លាសនៃកោសិកា ។ ក្នុងដំណាក់កាលនេះ គ្លុយកូសត្រូវបានបំបែកតែបន្តិចបន្តួចដោយពុំទាន់បានប្រើប្រាស់អុកស៊ីសែនទេ ហើយបញ្ចេញថាមពលបន្តិចបន្តួចតែប៉ុណ្ណោះ ។

### ខ. ដំណាក់កាលទី 2

ដំណាក់កាលទី 2 ប្រព្រឹត្តទៅនៅក្នុងមីតូកុងទ្រី(ធាតុកោសិកា) ។ ក្នុងដំណាក់កាលនេះ គ្លុយកូសត្រូវបានបំបែកបន្តទៅទៀតដោយប្រើប្រាស់អុកស៊ីសែន ($O_2$) ហើយបញ្ចេញថាមពលយ៉ាងច្រើន ។ ផលិតផលនៃដង្ហើមរបស់រុក្ខជាតិបៃតងគឺឧស្ម័នកាបូនិច ($CO_2$) និងទឹក($H_2O$) ដែលត្រូវបញ្ចេញទៅមជ្ឈដ្ឋានខាងក្រៅ ។

សង្ខេបប្រតិកម្មដង្ហើមរបស់រុក្ខជាតិបៃតង

$$\underset{\text{ស្ករ}}{C_6H_{12}O_6} + \underset{\text{អុកស៊ីសែន}}{6O_2} \xrightarrow[\text{មីតូកុងទ្រី}]{} \underset{\text{ឧស្ម័នកាបូនិច}}{6CO_2} + \underset{\text{ទឹក}}{6H_2O} + \text{ថាមពល}$$

យើងឃើញថា រូបធាតុដើមសម្រាប់ដង្ហើមរុក្ខជាតិគឺស្ករនិងអុកស៊ីសែន ($O_2$) ។ រុក្ខជាតិបៃតងធ្វើរស្មីសំយោគដោយផលិតស្ករ ឬគ្លុយកូស ($C_6H_{12}O_6$) របស់វាផ្ទាល់ ។ គ្លុយកូសនៅក្នុងសារពាង្គកាយសត្វនិងមនុស្សបានមកពីអាហារដែលវាស៊ី ។ អុកស៊ីសែន ($O_2$) ប្រើប្រាស់ក្នុងដង្ហើមរុក្ខជាតិបានមកពីខ្យល់ឬទឹកដែលនៅក្នុងបរិយាកាស ។

## 1.2. កត្តាខាងក្រៅដែលជះឥទ្ធិពលទៅលើដំណើរដង្ហើមរុក្ខជាតិ

សីតុណ្ហភាពសមស្របដល់ដំណើរដង្ហើមរុក្ខជាតិគឺចន្លោះពី 25-35°C ។ សីតុណ្ហភាពខ្ពស់ពេកឬទាបពេកធ្វើឱ្យមានការប៉ះពាល់ដល់ដំណើរដង្ហើមរុក្ខជាតិ ព្រោះពេលនោះសកម្មភាពរបស់រុក្ខជាតិខ្សោយឬត្រូវបំផ្លាញ ។ ដូចនេះយើងគួរបំប៉នដីនិងស្រោចទឹករុក្ខជាតិឱ្យបានគ្រប់គ្រាន់ ។

បរិមាណអុកស៊ីសែន ($O_2$) និងឧស្ម័នកាបូនិច ($CO_2$) ក្នុងបរិយាកាសក៏ជះឥទ្ធិពលដល់ដំណើរដង្ហើមរុក្ខជាតិដែរ ។

ចំពោះសរីរាង្គរុក្ខជាតិដែលនៅលើដី កង្វះបរិមាណអុកស៊ីសែន ($O_2$) មិនជះឥទ្ធិពលទៅលើដំណើរដង្ហើមទេ ព្រោះសរីរាង្គទាំងនេះនឹងទទួលអុកស៊ីសែនបានមកវិញពីដំណើររស្មីសំយោគ ។

ចំណែកឫសរុក្ខជាតិដែលជាសរីរាង្គនៅក្នុងដីអាចខ្វះអុកស៊ីសែនដូចនេះយើងត្រូវឧស្សាហ៍ជ្រាយដីដំណាំឱ្យធូរជានិច្ច ។

បរិមាណឧស្ម័នកាបូនិច ($CO_2$) នៃបរិយាកាសកើន ធ្វើឱ្យដំណើរដង្ហើមរុក្ខជាតិថយចុះ ជាពិសេសនៅពេលយប់ ។

## 2. ទំនាក់ទំនងថាមពល

ដំណើររស្មីសំយោគជាលំនាំផ្ទុយពីដំណើរដង្ហើម ប៉ុន្តែវាអាស្រ័យគ្នាទៅវិញទៅមក ។ ក្នុងដំណើររស្មីសំយោគ ឧស្ម័នកាបូនិច($CO_2$) និងទឹក ($H_2O$) ត្រូវបានប្រើប្រាស់ដើម្បីផលិតស្ករ($C_6H_{12}O_6$ ) និងអុកស៊ីសែន ($O_2$) ។ ក្នុងដំណើរដង្ហើម ស្ករ($C_6H_{12}O_6$ )និងអុកស៊ីសែន ($O_2$) ត្រូវបានប្រើប្រាស់សម្រាប់ផលិតឧស្ម័នកាបូនិច ($CO_2$) និងទឹក ($H_2O$) ។ ក្នុងដំណើររស្មីសំយោគ ថាមពលព្រះអាទិត្យត្រូវបំប្លែងទៅជាថាមពលគីមី ។ គ្លុយកូសត្រូវបានប្រើប្រាស់ក្នុងរុក្ខជាតិផ្ទាល់ ឬត្រូវផ្ទេរទៅឱ្យភាវៈរស់ផ្សេងៗទៀតតាមរយៈខ្សែអាហារ ។

ក្នុងសារពាង្គកាយរុក្ខជាតិ គ្លុយកូសត្រូវបំបែកដោយដង្ហើមដើម្បីបញ្ចេញថាមពល ។ ផលិតផលដែលទទួលបានពីដង្ហើម គឺឧស្ម័នកាបូនិច ទឹក និងថាមពលគីមី ។ ផលិតផលចុងក្រោយនេះត្រូវប្រើប្រាស់សារជាថ្មីដើម្បីបង្កើតគ្លុយកូសតាមដំណើររស្មីសំយោគ ។

ដំណើរការទាំងពីរនេះរួមគ្នា បង្កើតបានជាវដ្តមួយដែលរក្សាស្ថិរភាពនៃកម្រិតអុកស៊ីសែន($O_2$) និងឧស្ម័នកាបូនិច($CO_2$) នៅក្នុងបរិយាកាសនៃផែនដី មានន័យថាភាវៈរស់ទាំងអស់ប្រើប្រាស់ឧស្ម័នទាំងពីរនេះម្តងហើយម្តងទៀត ។

## 3. ការផ្ទេរថាមពល

នៅពេលធ្វើរស្មីសំយោគ រុក្ខជាតិបៃតងបំប្លែងថាមពលពន្លឺព្រះអាទិត្យជាថាមពលគីមីស្តុកទុកក្នុងអាហារដែលវាផលិតបាន ។ កាលណាសត្វផ្សេងៗស៊ីរុក្ខជាតិបៃតង វាទទួលថាមពលបានមកពីអាហារទាំងនោះ ដូចនេះសត្វទាំងអស់ស៊ីរុក្ខជាតិជាអាហារ ។ បើគ្មានរុក្ខជាតិ ជីវិតក៏គ្មាននៅលើផែនដីដែរ ។ គេអាចនិយាយថា គ្រប់ភាវរស់អាស្រ័យថាមពលពន្លឺព្រះអាទិត្យ ដើម្បីផលិតអាហារដោយហេតុថា រុក្ខជាតិប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ ដើម្បីបង្កើតអាហាររបស់វា ។

*ឧទាហរណ៍ :* នៅក្នុងចំការដំណាំហូបផ្លែមួយ សត្វដង្កូវបានស៊ីបំផ្លាញស្លឹកដំណាំជាច្រើន ។ បន្ទាប់មកទៀតបក្សីមកចិកស៊ីដង្កូវទាំងនោះ ។ ទាំងសត្វដង្កូវ ទាំងសត្វបក្សីត្រូវការចិញ្ចឹមជីវិតដូច

គ្នា ។ ពួកវាទទួលបានថាមពលពីអាហារដែលវាស៊ី ។ ដូចនេះភាវៈរស់នីមួយៗត្រូវការថាមពល ។ កោសិកាទាំងអស់ក៏ត្រូវការថាមពលដែរ ដើម្បីផលិតសារធាតុចិញ្ចឹមផ្សេងៗដូចជាប្រូតេអ៊ីន ជាដើម ។ ឯបក្សីក៏ត្រូវការថាមពលសម្រាប់ដឹកនាំសារធាតុចូលទៅក្នុងកោសិការបស់វាដែរ ។ ឯដំណាំហូបផ្លែក៏ផ្តល់ថាមពលទៅឱ្យកោសិការបស់សត្វដង្កូវដែរ ។ សារពាង្គកាយទាំងនេះប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ ដើម្បីផលិតអាហាររបស់ខ្លួន ។ ភាវៈរស់ស្ទើរទាំងអស់ទទួលបានថាមពលដោយផ្ទាល់ ឬដោយប្រយោលពីថាមពលពន្លឺព្រះអាទិត្យក្នុងពេលធ្វើរស្មីសំយោគ ។ ដំណាំហូបផ្លែ ប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យដោយផ្ទាល់ ពីព្រោះវាផលិតអាហារនៅពេលរស្មីសំយោគ ។ នៅពេលសត្វដង្កូវស៊ីស្លឹកដំណាំ វាទទួលបានថាមពលដែលស្តុកទុកនៅក្នុងស្លឹកដំណាំនោះ ។ សត្វបក្សីទទួលបានថាមពលដែលស្តុកទុកក្នុងសាច់ដង្កូវ ។ សត្វទាំងពីរនេះទទួលបានថាមពលពន្លឺព្រះអាទិត្យដោយប្រយោល ពីថាមពលដែលដំណាំទទួលបានដោយសារដំណើររស្មីសំយោគ ។

ដូចនេះថាមពលដែលដំណាំហូបផ្លែទទួលបានពីពន្លឺព្រះអាទិត្យត្រូវផ្ទេរទៅឱ្យដង្កូវ បន្ទាប់មកបក្សីនិងអ្នកស៊ីបន្ទាប់ទៀត ។




*រូបទី 3.1 : ការទទួលថាមពលរបស់ភាវៈរស់*




*រូបទី 3.2 : ការផ្ទេរថាមពល*

## មេរៀនសង្ខេប

- ដង្ហើមជាដំណើរការដែលរុក្ខជាតិទទួលបានថាមពលពីការបំបែកម៉ូលេគុលគ្លុយកូស ។
- ដង្ហើមកោសិកាមានពីរដំណាក់កាល ។ ដំណាក់កាលទី 1 កើតមាននៅក្នុងស៊ីតូប្លាសរបស់កោសិកា គ្លុយកូសត្រូវបំបែកតែបន្តិចបន្តួចប៉ុណ្ណោះដោយមិនទាន់ប្រើប្រាស់អុកស៊ីសែន ហើយបញ្ចេញបរិមាណថាមពលតិចតួច ។ ដំណាក់កាលទី 2 កើតមាននៅក្នុងមីតូកុងទ្រី គ្លុយកូសត្រូវបានបំបែកជាបន្តទៀតដោយប្រើប្រាស់អុកស៊ីសែនព្រមទាំងបញ្ចេញបរិមាណថាមពលយ៉ាងច្រើន ។
- ប្រតិកម្មសង្ខេបនៃដំណើរដង្ហើមរបស់រុក្ខជាតិ :

$$\underset{\text{ស្ករ}}{C_6H_{12}O_6} + \underset{\text{អុកស៊ីសែន}}{6O_2} \xrightarrow[\text{មីតូកុងទ្រី}]{} \underset{\text{ឧស្ម័នកាបូនិច}}{6CO_2} + \underset{\text{ទឹក}}{6H_2O} + \text{ថាមពល}$$

- ភាវៈរស់ស្ទើរតែទាំងអស់ទទួលបានថាមពលដោយផ្ទាល់ឬដោយប្រយោលពីថាមពលពន្លឺព្រះអាទិត្យដែលចាប់យកក្នុងដំណើររស្មីសំយោគ ។

## សំណួរ

1. ដូចម្ដេចហៅថាដង្ហើមរុក្ខជាតិ ?
2. ចូរពណ៌នាពីដំណាក់កាលទី 1 របស់ដង្ហើមរុក្ខជាតិ ។
3. ចូរពណ៌នាពីដំណាក់កាលទី 2 របស់ដង្ហើមរុក្ខជាតិ ។
4. តើដង្ហើមរុក្ខជាតិមានទំនាក់ទំនងជាមួយដំណើររស្មីសំយោគយ៉ាងដូចម្ដេចខ្លះ ?
5. តើដំណើរដង្ហើមនិងដំណើររស្មីសំយោគខុសគ្នាដូចម្ដេចខ្លះ ?
6. តើកត្តាខាងក្រៅអ្វីខ្លះដែលជះឥទ្ធិពលដល់ដំណើរដង្ហើមរបស់រុក្ខជាតិ ?
7. ចូរសរសេរប្រតិកម្មនៃដំណើរដង្ហើមរបស់រុក្ខជាតិ ។
8. ចូរឱ្យឧទាហរណ៍ពីភាវរស់ដែលបានទទួលថាមពលពន្លឺព្រះអាទិត្យដោយផ្ទាល់និងដោយប្រយោល ។
9. តើវិធីអ្វីខ្លះដែលយើងអាចបង្កើតសំណើមនៅលើដីស្រទាប់លើរបស់ដីដំណាំ ? ហេតុអ្វី ?

## ? សំណួរបញ្ចប់ជំពូកទី១

I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវ :

1. ទឹក ឧស្ម័នកាបូនិច និងថាមពលជាផលិតផលរបស់

☐ ក. ដំណុះគ្រាប់ ☐ ខ. រស្មីសំយោគ ☐ គ. ការលូតលាស់ ☐ ឃ. ដង្ហើមរុក្ខជាតិ

2. ធាតុកោសិកាដែលជាកន្លែងធ្វើរស្មីសំយោគគឺ

☐ ក. មីតូកុងទ្រី ☐ ខ. ណ្វៃយ៉ូ ☐ គ. វ៉ាគុយអូល ☐ ឃ. ក្លរ៉ូប្លាស

3. ដង្ហើមកោសិការុក្ខជាតិកើតមាននៅក្នុង

☐ ក. ណ្វៃយ៉ូ ☐ ខ. ក្លរ៉ូប្លាស ☐ គ. មីតូកុងទ្រី ☐ ឃ. វ៉ាគុយអូល

4. កត្តាខាងក្រៅដែលជះឥទ្ធិពលទៅលើដំណើររស្មីសំយោគគឺ

☐ ក. ពន្លឺព្រះអាទិត្យ ទឹក ឧស្ម័នកាបូនិច និងឧស្ម័នអុកស៊ីសែន

☐ ខ. ពន្លឺព្រះអាទិត្យ សីតុណ្ហភាព ឧស្ម័នអុកស៊ីសែន និងដី

☐ គ. ពន្លឺព្រះអាទិត្យ ទឹក ឧស្ម័នកាបូនិច និងសីតុណ្ហភាព

☐ ឃ. ពន្លឺព្រះអាទិត្យ ជី ដី និងទឹក

5. កត្តាខាងក្រៅជះឥទ្ធិពលទៅលើដំណើរដង្ហើមរបស់រុក្ខជាតិមាន

☐ ក. ទឹក ពន្លឺព្រះអាទិត្យ ឧស្ម័នកាបូនិច និងឧស្ម័នអុកស៊ីសែន

☐ ខ. ទឹក ពន្លឺព្រះអាទិត្យ ឧស្ម័នកាបូនិច និងឧស្ម័នអាសូត

☐ គ. សីតុណ្ហភាព បរិមាណអុកស៊ីសែន បរិមាណឧស្ម័នកាបូនិចក្នុងបរិយាកាស

☐ ឃ. ចម្លើយ ក និង ខត្រូវរួមគ្នា

II. ចូរបំពេញចន្លោះនៃឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ

1. ស្រទាប់ក្រៅបង្អស់នៃផ្ទៃកខាងក្រោមនិងខាងលើផ្ទៃស្លឹកមានសារធាតុម្យ៉ាងភ្លឺរលោងមានឈ្មោះថា .............................. ។

2. ស្រទាប់របស់ស្លឹកដែលកើតឡើងពីកោសិកាក្រាស់តែមួយស្រទាប់ ហើយមានលក្ខណៈថ្លាដោយសារវាមានជាតិពណ៌តិចឬគ្មានមានឈ្មោះថា .............................. ។

3. តាមធម្មតានៅផ្ទៃក្រោមស្លឹកមាន ............ ច្រើនជាងផ្ទៃលើស្លឹក ។ វាជាកន្លែងបណ្ដូរឧស្ម័នកាបូនិចនិងអុកស៊ីសែនរវាងជាលិកាខាងក្នុងស្លឹកនិងមជ្ឈដ្ឋានខាងក្រៅនិង ............ ក៏ប្រព្រឹត្តតាមរយៈកន្លែងនេះដែរ ។

4. នៅចន្លោះអេពីឌែមលើនិងក្រោមនៃស្លឹកមានស្រទាប់ជាលិកា ........ សម្រាប់ធ្វើរស្មីសំយោគ ។

5. ជាលិកាដែលកើតពីកោសិកាក្រាស់រាងទ្រវែងមួយឬពីរស្រទាប់ ហើយស្ថិតនៅកៀកជិតគ្នាយ៉ាងខ្លាំងនិងផ្ទុកក្លរ៉ូប្លាសហៅថា .............................. ។

6. នៅក្រោមស្រទាប់បាំលីសាតមាន .......... ដែលស្រទាប់ទាំងនេះកើតពីកោសិកាជាច្រើនមានទ្រង់ទ្រាយមិនទៀងទាត់និងនៅចន្លោះកោសិកាទាំងនេះកើតមានលំហធំៗ ។

7. នៅក្នុងស្រទាប់មេសូភីលមាន ................................................ ដែលកើតឡើងពីជាលិកានាំ ។

8. លំហធំៗនៅក្នុងស្រទាប់មេសូភីលស្ពោតមានមុខងារផ្ទុក ............................................ ។

III. សំណួរ

1. ហេតុអ្វីបានជាគេតែងតែដាក់សារាយនៅក្នុងអាងចិញ្ចឹមត្រី (*ឧទាហរណ៍* ត្រីប្រាំពីរពណ៌ ត្រីក្រឹមត្រីកន្ទុយបី ...) ?

2. ហេតុអ្វីបានជានៅពេលយប់យើងមិនគួរដាក់ផ្កាឬរុក្ខជាតិលំអយ៉ាងច្រើននៅក្នុងបន្ទប់ដេកដោយបិទទ្វារនិងបង្អួចជិតនោះទេ ?

3. តើផ្នែកណាមួយនៃរុក្ខជាតិគ្មានស្លឹក (*ឧទាហរណ៍* ដើមដំបងយក្ស) មានមុខងារធ្វើរស្មីសំយោគ ?

4. ហេតុអ្វីបានជាដំណើររស្មីសំយោគនិងដំណើរដង្ហើមជាដំណើរពីរផ្ទុយគ្នា ប៉ុន្តែមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ?

5. ហេតុអ្វីបានជាយើងមិនគួរដាំដំណាំញឹកកៀកជិតគ្នាប្រសិនបើយើងចង់បានផលច្រើន ?

6. ហេតុអ្វីបានជារុក្ខជាតិមួយចំនួនដែលដាំដាក់ផើង ហើយយកទៅតាំងលំអក្នុងផ្ទះ វានៅតែលូតលាស់ល្អដដែល ? ចូររកឧទាហរណ៍ពីឈ្មោះរុក្ខជាតិប្រភេទនេះឱ្យបានបី ។

7. ដើម្បីឱ្យដំណាំលូតលាស់បានល្អ ហេតុអ្វីបានជាយើងត្រូវស្រោចទឹក ធ្វើរានបាំងដំណាំនៅពេលដែលធាតុអាកាសក្តៅខ្លាំងនិងគ្របគល់ដំណាំនៅពេលដែលធាតុអាកាសត្រជាក់ ?

8. តើសារធាតុសរីរាង្គអ្វីខ្លះដែលផលិតដោយរុក្ខជាតិបៃតងតាមរយៈដំណើររស្មីសំយោគ ?

9. យើងដឹងហើយថាដង្ហើមរបស់ភាវៈរស់និងរាល់សកម្មភាពរបស់មនុស្សបានបញ្ចេញឧស្ម័នកាបូនិច ($CO_2$) ទៅក្នុងបរិយាកាស ។ ហេតុអ្វីបានជាបរិមាណឧស្ម័ននេះមិនកើនឡើង ?

# ជំពូកទី 2 ប្រព័ន្ធប្រសាទ



រូបសញ្ញាទាំងអស់នេះមានលក្ខណៈស្រដៀងគ្នា ។ យើងបានរៀននិងអនុវត្តតាម ប្រសិនបើយើងគ្មានប្រាជ្ញា (ខួរក្បាល) ទេនោះ យើងនឹងគ្មានសមត្ថភាពអានឬស្វែងយល់នូវសញ្ញាទាំងអស់នេះទេ ។ ដបទឹកអប់ដែលបើកគម្របចេញ បានបង្ហើរក្លិនក្រអូបឈ្ងុយឈ្ងប់ដល់យើង ។

ឧបករណ៍ភ្លេងទាំងនេះបានបញ្ចេញសំឡេងពិរោះរណ្ដំ ដែលធ្វើឱ្យយើងមានអារម្មណ៍ធូរស្រាល ។ យើងនឹងមិនអាចបែងចែកបានពីក្លិនទឹកអប់មួយប្រភេទទៅនឹងក្លិនមួយប្រភេទទៀត ឬរវាងសំឡេងមួយទៅនឹងសំឡេងមួយទៀតបានទេ ប្រសិនបើយើងគ្មានខួរក្បាល ។

វាជាការពិត ដែលខួរក្បាលរបស់យើងបកស្រាយប្រាប់យើងបានពីក្លិននិងសំឡេង ។

មេរៀនទី

# 1 ណឺរ៉ូន

**ចប់មេរៀននេះ សិស្សអាច**

- ❑ បង្ហាញពីរូបផ្គុំរបស់ណឺរ៉ូន
- ❑ រាប់ឈ្មោះប្រភេទផ្សេងៗនៃណឺរ៉ូន
- ❑ បកស្រាយពីដំណើរឆ្លងកាត់ស៊ីណាប់នៃអាំងភ្លុចប្រសាទ ។

នៅពេលប៉ះវត្ថុក្តៅ ភ្លាមនោះដៃរបស់អ្នកកន្ត្រាក់ថយក្រោយ ព្រោះមានព័ត៌មានចេញពីខួរឆ្អឹងខ្នង ។ នៅពេលអ្នករត់ សាច់ដុំជើងកន្ត្រាក់យ៉ាងខ្លាំង ពីព្រោះមានព័ត៌មានចេញពីខួរក្បាល ។ ព័ត៌មានទាំងនេះ ធ្វើដំណើរតាមបណ្តោយផ្លូវប្រសាទដែលដឹកនាំទៅពាសពេញសរីរាង្គកាយទាំងមូល ។

## 1. ណឺរ៉ូន



*រូបទី 1.1 : រូបផ្គុំណឺរ៉ូន*

កោសិកាដែលដឹកនាំព័ត៌មានទៅពាសពេញប្រព័ន្ធប្រសាទ ហៅថាកោសិកាប្រសាទឬណឺរ៉ូន ។ ណឺរ៉ូនច្រើនផ្គុំគ្នាជាបាច់ហៅថាបាច់ប្រសាទ ។ បណ្តុំនៃបាច់ប្រសាទ បង្កើតបានជាសរសៃប្រសាទឬផ្លូវប្រសាទ ។ ដោយសារព័ត៌មានដែលណឺរ៉ូនដឹកនាំមានលក្ខណៈជាសញ្ញាអគ្គិសនី ដូចនេះគេហៅថាអាំងភ្លុចប្រសាទ(ឬចរន្តប្រសាទ) ។ នៅពេលដៃរបស់អ្នកប៉ះវត្ថុក្តៅភ្លាម អាំងភ្លុចធ្វើដំណើរតាមបណ្តោយណឺរ៉ូន ទៅកាន់ខួរឆ្អឹងខ្នង ។ បន្ទាប់មកខួរឆ្អឹងខ្នងបញ្ជូនព័ត៌មាននេះតាមបណ្តោយណឺរ៉ូនផ្សេងទៀត ទៅកាន់សាច់ដុំ ហើយបណ្តាលឱ្យសាច់ដុំកន្ត្រាក់ ។ ថ្វីបើណឺរ៉ូនទាំងអស់មានរូបរាងមិនដូចគ្នា ប៉ុន្តែវាមានរូបផ្គុំរួមមួយ និងបំពេញនាទីដូចគ្នា គឺដឹកនាំអាំងភ្លុចប្រសាទ ។ ណឺរ៉ូននីមួយៗមានបីផ្នែកសំខាន់ ដង់ឌ្រីត តួកោសិកា និងអាក់សូន ។ តួកោសិកាមានផ្ទុកណ្វៃយ៉ូនិងធាតុកោសិកាមួយចំនួន ។ នៅចុងម្ខាងនៃតួកោសិកា មានសរសៃឆ្មារៗហើយខ្លីជាច្រើន ហៅថាដង់ឌ្រីត ។ ដង់ឌ្រីតដឹកនាំអាំងភ្លុចចេញពីមជ្ឈដ្ឋានឬពីណឺរ៉ូនផ្សេងៗទៀតចូលទៅក្នុងតួកោសិកា ។ នៅចុងម្ខាងទៀតនៃតួកោសិកា មានពន្លយធំមួយហើយវែង ហៅថាអាក់សូន ។ អាក់សូនទទួលយកព័ត៌មានពីតួកោសិកា ហើយបញ្ជូនទៅកាន់ណឺរ៉ូនផ្សេងទៀតឬទៅកាន់សាច់ដុំនិងក្រពេញ ។ ផ្នែកខាងចុងនៃអាក់សូន មានកំពកតូចៗជាច្រើនហៅថាស្នាញអាក់សូន ឬចុងអាក់សូន ។ ណឺរ៉ូនមានដង់ឌ្រីតច្រើន តែមានអាក់សូនតែមួយទេ ។

# 2. ប្រភេទផ្សេងៗនៃណឺរ៉ូន

នៅក្នុងស្បែកនិងក្នុងសរីរាង្គវិញ្ញាណផ្សេងៗ មានទម្រង់មួយហៅថាធ្នូល។ ធ្នូលជាកោសិកាប្រសាទនៅក្នុងសរីរាង្គវិញ្ញាណ ដែលអាចចាប់យករំញោចបានដូចជា ពន្លឺ សូរសំឡេង កម្តៅពីមជ្ឈដ្ឋានខាងក្រៅសារពាង្គកាយ។ កោសិកាប្រសាទចែកចេញជាបីក្រុមសំខាន់ ដែលទាក់ទងទៅនិងការដឹកនាំអាំងភ្លុចចេញពីរំញោច។

## 2.1. ណឺរ៉ូនវិញ្ញាណនាំ

ណឺរ៉ូនវិញ្ញាណនាំ ដឹកនាំអាំងភ្លុចប្រសាទទៅកាន់ខួរឆ្អឹងខ្នងនិងខួរក្បាល។ ណឺរ៉ូនខ្លះចាប់យកអាំងភ្លុចប្រសាទពីមជ្ឈដ្ឋានខាងក្នុងសារពាង្គកាយ។ ឯណឺរ៉ូនវិញ្ញាណនាំផ្សេងទៀត ចាប់យកអាំងភ្លុចប្រសាទពីមជ្ឈដ្ឋានខាងក្រៅសារពាង្គកាយ។ ណឺរ៉ូនវិញ្ញាណនាំទាំងនេះមាននៅក្នុងសរីរាង្គវិញ្ញាណដូចជាភ្នែក ច្រមុះ អណ្តាត ស្បែក ត្រចៀក។

*ឧទាហរណ៍ :* ណឺរ៉ូនវិញ្ញាណនាំនៅក្នុងស្បែកចាប់យកកម្តៅ ត្រជាក់ ការឈឺចាប់ និងសំពាធ។ ណឺរ៉ូនវិញ្ញាណនាំនៅក្នុងភ្នែកចាប់យកពន្លឺ ណឺរ៉ូនវិញ្ញាណនាំក្នុងច្រមុះចាប់យកក្លិន ក្នុងត្រចៀក ចាប់យកសូរនិងលើអណ្តាតចាប់យករសជាតិ។

## 2.2. ណឺរ៉ូនចលករ

ណឺរ៉ូនចលករ ដឹកនាំអាំងភ្លុចប្រសាទចេញពីខួរក្បាលនិងខួរឆ្អឹងខ្នង។ ណឺរ៉ូនចលករភាគច្រើនដឹកនាំព័ត៌មានដែលធ្វើឱ្យសាច់ដុំនិងក្រពេញធ្វើសកម្មភាព។

## 2.3. ណឺរ៉ូនភ្ជាប់ឬអន្តរណឺរ៉ូន

ណឺរ៉ូនវិញ្ញាណនាំ ដឹកនាំព័ត៌មានទៅកាន់ខួរក្បាលនិងខួរឆ្អឹងខ្នង ចំណែកឯណឺរ៉ូនចលករដឹកនាំព័ត៌មានចេញពីខួរក្បាលនិងខួរឆ្អឹងខ្នងវិញ។ ដើម្បីឱ្យសកម្មភាពនៃណឺរ៉ូនវិញ្ញាណនាំនិងណឺរ៉ូនចលករអាចសម្របសម្រួលគ្នាបានល្អប្រសើរ គឺត្រូវតែមានណឺរ៉ូនមួយប្រភេទទៀតសម្រាប់ភ្ជាប់ណឺរ៉ូនទាំងពីរនេះ។ ណឺរ៉ូននេះជាអន្តរណឺរ៉ូន ដែលភ្ជាប់ណឺរ៉ូនទាំងពីរខាងលើនិងដឹកនាំព័ត៌មានរវាងណឺរ៉ូនទាំងពីរនេះ។ ណឺរ៉ូនភ្ជាប់នេះមាននៅក្នុងខួរក្បាល និងខួរឆ្អឹងខ្នង។ នៅក្នុងខួរក្បាល អន្តរណឺរ៉ូនបង្កើតបានជាតំណដែលអាចបញ្ជូនព័ត៌មានរវាងផ្នែកផ្សេងៗនៃខួរក្បាល។ នៅក្នុងសារពាង្គកាយរបស់អ្នក អន្តរណឺរ៉ូនមានចំនួនប្រហែល 97% នៃចំនួនណឺរ៉ូនទាំងអស់។




*រូបទី 1.2 : ប្រភេទផ្សេងៗនៃណឺរ៉ូន*

## 3. ទិសដៅអាំងភ្លុចប្រសាទ

ណឺរ៉ូនដឹកនាំព័ត៌មានតាមទិសដៅតែមួយគត់ ។ អាំងភ្លុចប្រសាទធ្វើដំណើរតាមណឺរ៉ូនក្នុងទិសដៅតែមួយប៉ុណ្ណោះ ។ ជាលទ្ធផលសរសៃប្រសាទមួយក្រុម បញ្ជូនអាំងភ្លុចប្រសាទទៅកាន់មជ្ឈមណ្ឌលប្រសាទ(ខួរក្បាលនិងខួរឆ្អឹងខ្នង) ។ ឯសរសៃប្រសាទមួយក្រុមទៀត ដឹកនាំអាំងភ្លុចប្រសាទចាកចេញពីមជ្ឈមណ្ឌលប្រសាទត្រឡប់ទៅកាន់ផ្នែកផ្សេងៗនៃសារពាង្គកាយ ។ ដង់ឌ្រីត ទទួលព័ត៌មានពីកោសិកាធ្ទួលឬពីណឺរ៉ូនផ្សេងៗទៀត ។ អាំងភ្លុចប្រសាទធ្វើដំណើរតាមដង់ឌ្រីតទៅកាន់តួកោសិកា ។ ចេញពីតួកោសិកា អាំងភ្លុចប្រសាទធ្វើដំណើរតាមអាក់សូនឆ្ពោះទៅកាន់ណឺរ៉ូនក្បែរគ្នាក្នុងច្រវាក់តែមួយ ។ អាំងភ្លុចប្រសាទ ធ្វើចលនាយឺតជាងចរន្តអគ្គិសនី ។ វាធ្វើចលនាតាមបណ្តោយអាក់សូនក្នុងល្បឿនប្រហែល 120m ក្នុងមួយវិនាទី ។



*រូបទី 1.3 : ទិសដៅអាំងភ្លុចប្រសាទ*

## 4. ស៊ីណាប់

នៅពេលអាំងភ្លុចប្រសាទទៅដល់ផ្នែកខាងចុងនៃអាក់សូន វាមិនអាចធ្វើដំណើរទៅមុខបានទៀតទេ ព្រោះអាក់សូនរបស់ណឺរ៉ូនមួយ មិនអាចប៉ះផ្ទាល់ទៅនឹងដង់ឌ្រីតរបស់ណឺរ៉ូនបន្ទាប់ ។ រវាងអាក់សូននិងដង់ឌ្រីត មានលំហតូចមួយហៅថាស៊ីណាប់ ។ នៅពេលអាំងភ្លុចប្រសាទធ្វើដំណើរទៅដល់ផ្នែកខាងចុងនៃអាក់សូន(ស្នាញអាក់សូន) វាមិនអាចឆ្លងកាត់លំហនោះបានទេ ។ តើអាំងភ្លុចប្រសាទធ្វើដូចម្តេចទើបឆ្លងកាត់ស៊ីណាប់បាន ?

ក្នុងស្នាញអាក់សូនមានពពុះតូចៗជាច្រើន ដែលមានផ្ទុកសារធាតុគីមី ។ នៅពេលអាំងភ្លុចប្រសាទទៅដល់ស្នាញអាក់សូន ពពុះតូចៗក៏ផ្ទុះបែក ហើយបញ្ចេញសារធាតុគីមី ដែលសាយឆ្លងកាត់ស៊ីណាប់ ។ នៅផ្នែកម្ខាងទៀត សារធាតុគីមីនេះបង្កើតអាំងភ្លុចប្រសាទថ្មីមួយនៅក្នុងដង់ឌ្រីតនៃណឺរ៉ូនក្បែរនោះ ។ តាមវិធីនេះ អាំងភ្លុចប្រសាទធ្វើចលនាឆ្លងកាត់ពីណឺរ៉ូនមួយទៅណឺរ៉ូនមួយផ្សេងទៀត ។

ដូចនេះមានតែស្នាញអាក់សូនប៉ុណ្ណោះដែលអាចផលិតសារធាតុគីមី សម្រាប់បង្កើតអាំងភ្លុចប្រសាទជាថ្មីនៅក្នុងដង់ឌ្រីតនៃណឺរ៉ូនបន្ទាប់ ។ ដោយហេតុនេះ អាំងភ្លុចប្រសាទអាចធ្វើដំណើរតាមទិសដៅតែមួយគត់ គឺពីដង់ឌ្រីតនៅផ្នែកខាងចុងនៃអាក់សូន ។




*រូបទី 1.4: ស៊ីណាប់*

## មេរៀនសង្ខេប

- កោសិកាដែលដឹកនាំព័ត៌មានទៅពាសពេញប្រព័ន្ធប្រសាទហៅថាណឺរ៉ូន ។ ណឺរ៉ូនមានបីផ្នែកសំខាន់ គឺតួកោសិកា ដង់ឌ្រីត និងអាក់សូន ។ ដង់ឌ្រីតដឹកនាំព័ត៌មានពីណឺរ៉ូនផ្សេងទៀត ទៅកាន់តួកោសិកា ។ អាក់សូនដឹកនាំព័ត៌មានពីតួកោសិកាទៅកាន់ណឺរ៉ូនផ្សេងទៀត ឬទៅកាន់សាច់ដុំនិងក្រពេញ ។
- ទាក់ទងនិងការទទួលព័ត៌មាន ណឺរ៉ូនមានបីក្រុមសំខាន់គឺ ណឺរ៉ូនវិញ្ញាណនាំ ណឺរ៉ូនចលករ និងអន្តរណឺរ៉ូន ។
- ស៊ីណាប់ ជាលំហនៅចន្លោះអាក់សូនរបស់ណឺរ៉ូនមួយ ជាមួយដង់ឌ្រីតនៃណឺរ៉ូនមួយក្បែរគ្នា ។

## ? សំណួរ

1. តើណឺរ៉ូនមានប៉ុន្មានផ្នែក ? អ្វីខ្លះ ?
2. តើណឺរ៉ូនមានប៉ុន្មានក្រុម ? ចូររៀបរាប់ ។
3. ដូចម្តេចហៅថាស៊ីណាប់ ?
4. តើអាំងភ្លុចប្រសាទឆ្លងកាត់ស៊ីណាប់យ៉ាងដូចម្តេច ?
5. តើស្នាញអាក់សូនមានសារធាតុអ្វី ? តើសារធាតុនេះមាននាទីអ្វី ?

# 2 មជ្ឈមណ្ឌលប្រសាទ

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីនាទីប្រព័ន្ធប្រសាទ
- ❑ ប្រាប់ឈ្មោះផ្នែកសំខាន់ទាំងបីរបស់ខួរក្បាល
- ❑ ពណ៌នាពីនាទីនៃផ្នែកនីមួយៗរបស់ខួរក្បាល
- ❑ ប្រាប់ពីនាទីនៃខួរឆ្អឹងខ្នង ។

នៅពេលឆ្លងកាត់ផ្លូវ អ្នកត្រូវដើរឆ្លងត្រង់កន្លែងមានភ្លើងសញ្ញាចរាចរណ៍ ។ អ្នកឈររង់ចាំភ្លើងសញ្ញាពណ៌បៃតង ទើបអ្នកអាចដើរឆ្លងកាត់ផ្លូវបាន ។ តើសកម្មភាពទាំងអស់នេះ(គំហើញភ្លើងពណ៌បៃតង ការឈររង់ចាំ និងការដើរឆ្លងកាត់ផ្លូវ) កើតឡើងជាបន្តបន្ទាប់យ៉ាងដូចម្តេច ? សកម្មភាពអស់ទាំងនេះកើតឡើងក្រោមការត្រួតពិនិត្យរបស់ប្រព័ន្ធប្រសាទ ។



*រូបទី 2.1 : សកម្មភាពផ្សេងៗ*

ក្នុងជីវភាពប្រចាំថ្ងៃសកម្មភាពរបស់យើងមានលក្ខណៈប្លែកៗពីគ្នាយ៉ាងច្រើន សាច់ដុំរបស់យើងត្រូវតែឆ្លើយតបនឹងស្ថានភាពផ្សេងៗ ។ ប្រព័ន្ធប្រសាទរបស់យើងរាប់រងការបញ្ជាទៅកាន់ សាច់ដុំទាំងអស់នោះ ។

## 1. នាទីប្រព័ន្ធប្រសាទ

ប្រព័ន្ធប្រសាទគ្រប់គ្រងផ្នែកខាងក្នុងសារពាង្គកាយរបស់យើង។ វាមាននាទីត្រួតពិនិត្យនិងសម្របសម្រួលផ្នែកផ្សេងៗនៃសារពាង្គកាយ ដោយធ្វើឱ្យផ្នែកទាំងនេះបំពេញនាទីព្រមៗគ្នា។ ប្រព័ន្ធប្រសាទ សម្របសម្រួលចលនាសាច់ដុំ ដែលអាចឱ្យអ្នកធ្វើសកម្មភាពដោយញាណបានដូចជា ការជិះកង់ ការរាំ។ ប្រព័ន្ធប្រសាទក៏សម្របសម្រួលផងដែរនូវសកម្មភាពណាដែលប្រព្រឹត្តទៅដោយអញ្ញាណ គឺវាត្រួតពិនិត្យសកម្មភាពរបស់សរីរាង្គនៃសារពាង្គកាយដូចជា ការកន្ត្រាក់នៃបេះដូង ការដកដង្ហើម ការរំលាយអាហារ ។



រូបទី 2.2 : រូបផ្គុំប្រព័ន្ធប្រសាទ

## 2. កាយវិភាគវិទ្យាមជ្ឈមណ្ឌលប្រសាទ

ប្រព័ន្ធប្រសាទមនុស្សចែកជាពីរផ្នែកសំខាន់ គឺមជ្ឈមណ្ឌលប្រសាទនិង**បរិមណ្ឌលប្រសាទ**។ មជ្ឈមណ្ឌលប្រសាទជាមជ្ឈមណ្ឌលត្រួតពិនិត្យរបស់សារពាង្គកាយ។ មជ្ឈមណ្ឌលនេះភ្ជាប់ប្រព័ន្ធទាំងអស់នៃសារពាង្គកាយនិងដឹកនាំសញ្ញាពីប្រព័ន្ធមួយទៅប្រព័ន្ធមួយផ្សេងទៀត។ មជ្ឈមណ្ឌលប្រសាទមានខួរក្បាលនិងខួរឆ្អឹងខ្នង។

### 2.1. ខួរក្បាល



រូបទី 2.3 : ខួរក្បាល

ខួរក្បាលជាសរីរាង្គមួយដែលមានលក្ខណៈស្មុគស្មាញខ្លាំងណាស់ ។ វាកើតឡើងពីកោសិកាប្រសាទរាប់ពាន់លាន ។ ចំពោះមនុស្សប្រុស ខួរក្បាលមានទម្ងន់ប្រហែលពី 1200 ទៅ 1350g និងចំពោះមនុស្សស្រីប្រហែលពី 1000 ទៅ 1250g ផ្ទៃក្រឡាខួរក្បាលមានប្រហែលពី 2000 ទៅ 2100cm$^2$ ។ ខួរក្បាលមានបីផ្នែកសំខាន់គឺ ខួរធំ ខួរតូច និងខួរកញ្ចឹងក ។ ជាលិកាសន្ទានបីស្រទាប់ គ្របដណ្តប់ខួរក្បាលនិងខួរឆ្អឹងខ្នង ។ ទឹកខួរ ក៏ស្ថិតនៅព័ទ្ធជុំវិញខួរក្បាលនិងខួរឆ្អឹងខ្នងដែរ ។ ឆ្អឹងលលាដ៍ក្បាលនិងទឹកខួរជួយការពារខួរក្បាលពីការរបួស ឬការប៉ះទង្គិចពីមជ្ឈដ្ឋានខាងក្រៅ ។

### ក. ខួរធំ



*រូបទី 2.4 : ផែនទីខួរធំ*

ផ្នែកធំជាងគេនៃខួរក្បាលជាខួរធំ ។ ខួរធំជាផ្នែកមួយនៃខួរក្បាលដែលត្រួតពិនិត្យការគិតនិងការពិចារណា ។ ខួរធំក៏ស្តុកទុកនូវព័ត៌មានផ្សេងៗផងដែរ ។ ព័ត៌មានដែលស្តុកទុកនេះហៅថា ការចងចាំ ។ ខួរធំទទួលគ្រប់ព័ត៌មានដែលចេញមកពីសរីរាង្គវិញ្ញាណទាំងអស់ ។ ខួរធំមួយផ្នែកអាចបញ្ជូនព័ត៌មានទៅកាន់សាច់ដុំមួយចំនួននៃសារពាង្គកាយ ។ តាមធម្មតា អំពើដែលកើតចេញមកពីការបញ្ជារបស់ខួរក្បាលជាអំពើឆន្ទៈ ។ ស្រទាប់ក្រៅនៃខួរធំជាសំបកខួរដែលមានសភាពជាផ្នត់ៗជាច្រើន ។ ផ្នត់ទាំងនេះបង្កើនផ្ទៃតំបន់នៃសំបកខួរយ៉ាងធំធេង ដែលបង្កើតបំណិនគិតផងដែរ ។ សំបកខួរត្រួតពិនិត្យលក្ខណៈជាច្រើនដូចជា សតិ ប្រឌិតញាណ ការពិចារណា ... ។

ខួរធំចែកចេញជាពីរចំហៀង ហៅថាអឌ្ឍគោលខួរឆ្វេងនិងស្ដាំ(រូបទី 2.3ខ) ។ អឌ្ឍគោលខួរឆ្វេងត្រួតពិនិត្យសាច់ដុំនៃសរពាង្គកាយចំហៀងខាងស្ដាំ ឯអឌ្ឍគោលខួរស្ដាំត្រួតពិនិត្យសកម្មភាពសាច់ដុំចំហៀងខាងឆ្វេង ។ ដោយហេតុនេះខួរក្បាលចំហៀងខាងស្ដាំបញ្ជូន និងទទួលយកព័ត៌មានតែពីសរពាង្គកាយចំហៀងខាងឆ្វេង ។

ប្រសិនបើនរណាម្នាក់ មានរបួសធ្ងន់ធ្ងរនូវខួរក្បាលចំហៀងខាងឆ្វេងនោះ គេនឹងទទួលរងនូវការបាត់បង់សមត្ថភាពផ្នែកនិយាយ ។ បើនរណាម្នាក់រងរបួសធ្ងន់ធ្ងរ នូវខួរក្បាលចំហៀងខាងស្ដាំ នោះគេមិនអាចចាំមុខមនុស្សដែលគេធ្លាប់ស្គាល់បានទេ ។

## ខ. ខួរតូច

ផ្នែកទីពីរនៃខួរក្បាលជាខួរតូច ដែលសណ្ឋិតនៅចំពីខាងក្រោមផ្នែកខាងក្រោយនៃខួរធំ ។ ក៏ដូចជាខួរធំដែរ ខួរតូចចែកជាអឌ្ឍគោលខួរពីរ ហើយនៅលើខួរតូចមានចង្អូរជ្រៅៗជាច្រើន ។ ប៉ុន្តែខួរតូចមានទំហំតូចជាងខួរធំយ៉ាងច្រើន ។ ខួរតូចបញ្ជាចលនាសាច់ដុំឱ្យធ្វើការព្រមគ្នានិងរលូន ។ វាក៏ជួយឱ្យសរពាង្គកាយមានលំនឹងផងដែរ ។ ការខូចខាតខួរតូចបណ្ដាលឱ្យមានចលនាកន្ត្រាក់ៗឬបាត់បង់តុល្យភាព ។



*រូបទី 2.5 : ដែនទីខួរតូច*

*ឧទាហរណ៍* : ដើម្បីចាប់កាន់ខ្មៅដៃមួយ សាច់ដុំភ្នែក ដៃនិងម្រាមដៃត្រូវតែធ្វើការរួមគ្នាតែមួយ ។ ខួរតូចត្រួតពិនិត្យសាច់ដុំទាំងនេះ ដើម្បីឱ្យសកម្មភាពរបស់ពួកវា ដំណើរការជាមួយគ្នាយ៉ាងរលូន ។ ការផឹកគ្រឿងស្រវឹងច្រើនពេកបណ្ដាលឱ្យអ្នកផឹកមានដំណើរទ្រេតទ្រោតនិងសញ្ញាមួយចំនួនទៀតនៃការបាត់បង់លំនឹង ។ លក្ខណៈទាំងនេះ បណ្ដាលមកពីការបាត់បង់នាទីជាបណ្ដោះអាសន្ននៃខួរតូច ។

## គ. ខួរកញ្ចឹងក

ខួរកញ្ចឹងកជាផ្នែកទីបីនិងតូចបំផុតរបស់ខួរក្បាល ។ ខួរកញ្ចឹងកលាតសន្ធឹងចេញពីខួរតូចហើយភ្ជាប់ខួរក្បាលទៅនឹងខួរឆ្អឹងខ្នង ។ ខួរកញ្ចឹងកត្រួតពិនិត្យសកម្មភាពជាច្រើនដែលជួយរក្សាអ្នកឱ្យមានជីវិតរស់នៅ ។



*រូបទី 2.6 : ខួរកញ្ចឹងក*

*ឧទាហរណ៍* : ខួរកញ្ចឹងក ត្រួតពិនិត្យ ការកន្ត្រាក់បេះដូង ចង្វាក់ដង្ហើម សំពាធឈាមនិងការរំលាយអាហារ ។ ខួរកញ្ចឹងក ត្រួតពិនិត្យសកម្មភាពទាំងនេះដោយស្វ័យប្រវត្តិ ។ ការក្អក ការកណ្ដាស់ ការលេបអាហារក៏ត្រួតពិនិត្យដោយខួរកញ្ចឹងកផងដែរ ។

## 2.2. ខួរឆ្អឹងខ្នង

ខួរឆ្អឹងខ្នង ជាផ្នែកបន្តរបស់ខួរកញ្ចឹងកដែលសន្ធឹងចុះមកខាងក្រោមប្រវែងប្រហែល 42-45cm ។ ក៏ដូចជាខួរក្បាលដែរ ខួរឆ្អឹងខ្នងត្រូវបានការពារដោយឆ្អឹងខ្នង ស្រោមខួរ និងទឹកខួរ ។ ខួរឆ្អឹងខ្នងស្ថិតនៅក្នុងប្រហោងនីមួយៗនៃឆ្អឹងកងរបស់ឆ្អឹងខ្នង ។ ខួរឆ្អឹងខ្នងកើតឡើងពីបណ្តុំនៃណឺរ៉ូនដែលដឹកនាំអាំងភ្លុចប្រសាទពីគ្រប់ផ្នែកទាំងអស់នៃសារពាង្គកាយទៅកាន់ខួរក្បាលនិងដឹកនាំអាំងភ្លុចប្រសាទពីខួរក្បាលទៅកាន់ផ្នែកទាំងអស់នៃសារពាង្គកាយ ។



*រូបទី 2.7 : ខួរឆ្អឹងខ្នង*

**ការងារប្រតិបត្តិ**

### លក្ខណៈលុប

1. វត្ថុបំណង
   - កំណត់បាននូវលក្ខណៈលុប
2. រយៈពេល 1 ម៉ោង
3. ដំណើរការ

ចូរអ្នកដាក់ដៃខ្វែងគ្នានៅលើទ្រូង ដោយមិនចាំបាច់គិតថា តើអ្នកដាក់ដៃយ៉ាងដូចម្តេចទេ ? អ្នកឃើញទេថា តើដៃចំហៀងខាងណាដែលខ្ពស់ជាងគេ ? ចម្លើយអាចនឹងបញ្ជាក់ឱ្យអ្នកដឹងថា អឌ្ឍគោលខួរចំហៀងខាងណាដែលមានភាពលុប(អឌ្ឍគោលខួរឆ្វេងឬស្តាំ) ។ ភាពលុបមានន័យថា មានសកម្មភាពលុប ។ *ឧទាហរណ៍* ដៃខាងស្តាំរបស់អ្នកខ្ពស់ជាង(រូបភាពទំព័រទី 189) ។ លក្ខណៈនេះបញ្ជាក់ឱ្យដឹងថា អឌ្ឍគោលខួរចំហៀងខាងឆ្វេងមានភាពលុប ។

ក្រៅពីដៃ មានផ្នែកផ្សេងៗទៀតនៃសារពាង្គកាយដូចជា ប្រអប់ជើង ប្រអប់ដៃ ម្រាមដៃ ម្រាមជើង ភ្នែក ត្រចៀក ...ដែលបង្ហាញឱ្យឃើញថា អឌ្ឍគោលខួរឆ្វេងលុប ឬខួរស្តាំលុប ។

4. ការវិភាគរកលក្ខណៈលុប

ចូរធ្វើការប្រៀបធៀបនូវលក្ខណៈមួយចំនួន : ទំហំប្រអប់ដៃឆ្វេងនិងប្រអប់ដៃស្តាំ ទំហំម្រាមដៃឆ្វេងនិងស្តាំ សកម្មភាពសរសេរដោយដៃឆ្វេងឬដៃស្តាំ ... ចូរធ្វើការប្រៀបធៀបលទ្ធផលរបស់អ្នក ជាមួយមិត្តរួមថ្នាក់ផ្សេងៗទៀត ។

បន្ទាប់មកឆ្លើយទៅនឹងសំណួរខាងក្រោម ៖

1 តើម្រាមដៃឆ្វេងឬស្តាំដែលមានទំហំធំជាង ?

2 តើប្រអប់ដៃចំហៀងណាមួយធំជាង ?

3 តើអ្នកសរសេរដោយដៃស្តាំឬដៃឆ្វេង ?

4 តើអ្នកមានអឌ្ឍគោលខួរខាងចំហៀងណាលុប ?

5 តើមិត្តរួមថ្នាក់របស់អ្នកមានលក្ខណៈលុបដោយ-អឌ្ឍគោលខួរចំហៀងខាងណា ?



## មេរៀនសង្ខេប

- ប្រព័ន្ធប្រសាទមាននាទីគ្រប់គ្រងផ្នែកខាងក្នុងសារពាង្គកាយ ។ វាមាននាទីត្រួតពិនិត្យនិងសម្របសម្រួលផ្នែកផ្សេងៗនៃសារពាង្គកាយដោយធ្វើឱ្យវាបំពេញនាទីព្រមៗគ្នា ។
- ប្រព័ន្ធប្រសាទចែកចេញជាពីរផ្នែក គឺមជ្ឈមណ្ឌលប្រសាទនិងបរិមណ្ឌលប្រសាទ ។ មជ្ឈមណ្ឌលប្រសាទមានខួរក្បាលនិងខួរឆ្អឹងខ្នង ។ ខួរក្បាលមានខួរធំ ខួរតូច និងខួរកញ្ចឹងក ។ ខួរក្បាលនិងខួរឆ្អឹងខ្នងគ្របដណ្តប់ដោយភ្នាសបីស្រទាប់ និងទឹកខួរដែលការពារខួរក្បាលនិងខួរឆ្អឹងខ្នងពីការប៉ះទង្គិចផ្សេងៗ ។
- ខួរធំត្រួតពិនិត្យការគិត ការពិចារណានិងស្តុកទុកនូវព័ត៌មានផ្សេងៗ ។ ខួរធំចាប់យកព័ត៌មានដែលចេញមកពីសរីរាង្គវិញ្ញាណ ។ ខួរតូចជួយក្នុងចលនាសាច់ដុំឱ្យធ្វើការព្រមគ្នានិងរលូន ។ វាក៏ជួយឱ្យសារពាង្គកាយមានលំនឹងផងដែរ ។ ខួរកញ្ចឹងកត្រួតពិនិត្យចង្វាក់បេះដូង ចង្វាក់ដង្ហើម ។

## ? សំណួរ

1 តើខួរក្បាលបង្កឡើងពីផ្នែកអ្វីខ្លះ ?

2 តើខួរក្បាលនិងខួរឆ្អឹងខ្នងគ្របដណ្តប់ដោយអ្វី ?

3 តើប្រព័ន្ធប្រសាទមាននាទីអ្វីខ្លះ ?

4 ចូរពណ៌នាពីនាទីនៃផ្នែកនីមួយៗរបស់ខួរក្បាល ។

# 3 បរិមណ្ឌលប្រសាទ

**ចប់មេរៀននេះ សិស្សអាច**

- ❑ ប្រាប់ពីឈ្មោះផ្សេងៗដែលបង្កើតបានជាបរិមណ្ឌលប្រសាទ
- ❑ ពណ៌នាពីចលនាតាមឆន្ទៈនិងរេផ្លិច
- ❑ បង្ហាញពីសារធាតុមួយចំនួនដែលមានឥទ្ធិពលលើប្រព័ន្ធប្រសាទ
- ❑ យល់ពីនាទីសំខាន់ និងអត្ថប្រយោជន៍នៃប្រព័ន្ធប្រសាទ ។



*រូបទី 3.1 : សរសៃប្រសាទ*

មជ្ឈមណ្ឌលប្រសាទកើតឡើងពីខួរក្បាលនិងខួរឆ្អឹងខ្នង ។ ដើម្បីឱ្យដំណើរការប្រព្រឹត្តិទៅបានត្រឹមត្រូវ មជ្ឈមណ្ឌលប្រសាទត្រូវតែភ្ជាប់ទៅនិងផ្នែកផ្សេងៗនៃសារពាង្គកាយ ។ បរិមណ្ឌលប្រសាទកើតឡើងពីសរសៃប្រសាទជាច្រើនដែលបង្កើតឡើងពីបាច់នៃអាក់សូន(បាច់ប្រសាទ) ។ អាក់សូននៅក្នុងសរសៃប្រសាទ ហៅថាភីបប្រសាទ (ភីបប្រសាទ ⟶ បាច់ប្រសាទ ⟶ សរសៃប្រសាទ) ។ បរិមណ្ឌលប្រសាទដឹកនាំព័ត៌មានរវាងមជ្ឈមណ្ឌលប្រសាទនិងផ្នែកផ្សេងៗនៃសារពាង្គកាយ ។

## 1. កាយវិភាគវិទ្យានៃបរិមណ្ឌលប្រសាទ

បរិមណ្ឌលប្រសាទ កើតពីសរសៃប្រសាទលលាដ៍ក្បាល 12 គូ ដែលចេញពីខួរក្បាលនិងសរសៃប្រសាទឆ្អឹងខ្នងចំនួន 31 គូដែលចេញពីខួរឆ្អឹងខ្នង ។ សរសៃប្រសាទទាំងនេះភ្ជាប់មជ្ឈមណ្ឌលប្រសាទជាមួយផ្នែកផ្សេងៗនៃសារពាង្គកាយ ។ បរិមណ្ឌលប្រសាទមានទំនាក់ទំនងជាមួយចលនាឆន្ទៈផងនិងចលនាអឆន្ទៈផង ។

សរសៃប្រសាទលលាដ៍ក្បាលស្ទើរទាំងអស់ ប្រើសម្រាប់ទាក់ទងនឹងសរីរាង្គវិញ្ញាណ (ភ្នែក ត្រចៀក ច្រមុះ.. ) និងខម្រង់ផ្សេងៗទៀតរបស់ក្បាលនិងកញ្ចឹងក ។

សរសៃប្រសាទខួរឆ្អឹងខ្នងកើតឡើងពីសរសៃប្រសាទវិញ្ញាណនាំនិងសរសៃប្រសាទចលករ ។ សរសៃប្រសាទវិញ្ញាណនាំបញ្ជូនអាំងភ្លុចប្រសាទ ចេញពីសរីរាង្គវិញ្ញាណ ទៅកាន់មជ្ឈមណ្ឌលប្រសាទ ។ ចំណែកសរសៃប្រសាទចលករបញ្ជូនអាំងភ្លុចប្រសាទចេញពីមជ្ឈមណ្ឌលប្រសាទទៅកាន់សាច់ដុំ ឬក្រពេញ ។



រូបទី 3.2 បរិមណ្ឌលប្រសាទ

បរិមណ្ឌលប្រសាទចែកចេញជាពីរផ្នែក ៖

- ប្រព័ន្ធប្រសាទសូម៉ាទិច មានសរសៃប្រសាទលលាដ៍ក្បាល និងសរសៃប្រសាទខួរឆ្អឹងខ្នងដែលដឹកនាំអាំងភ្លុចប្រសាទពីមជ្ឈមណ្ឌលប្រសាទទៅកាន់សាច់ដុំជាប់ឆ្អឹង ។ សរសៃប្រសាទសូម៉ាទិចត្រួតពិនិត្យចលនាឆន្ទៈដូចជា ការរត់ ការផាត់ពណ៌ ការច្រៀងត្រូវបានសម្របសម្រួលដោយប្រព័ន្ធប្រសាទនេះ ។ ដូចនេះប្រព័ន្ធប្រសាទសូម៉ាទិចត្រួតពិនិត្យ និងសម្របសម្រួលចលនាឆន្ទៈរបស់សារពាង្គកាយ ។
- ប្រព័ន្ធប្រសាទស្វ័យប្រវត្តិតម្រូវចលនាអឆន្ទៈនៃសរីរាង្គខាងក្នុង ។ វាមាននាទីយ៉ាងសំខាន់ក្នុងការតម្រូវចង្វាក់ដង្ហើម ការបញ្ចេញចោល ដំណើររបត់ឈាម ការរំលាយអាហារក៏ដូចជាការចិញ្ចឹម ការបន្តពូជ និងការបន្សាំទៅនឹងលក្ខខណ្ឌប្រែប្រួលនៃមជ្ឈដ្ឋានជុំវិញ ។



រូបទី 3.3 រូបបំប្រួញប្រព័ន្ធប្រសាទទាំងពីរនៃបរិមណ្ឌលប្រសាទ

# 2. ចលនាតាមឆន្ទៈនិងរេផ្លិច

## 2.1. ចលនាតាមឆន្ទៈ

ចលនាតាមឆន្ទៈជាចលនា ដែលកើតឡើងដោយញាណ ដូចជាការមើលសៀវភៅ ការចាប់កាន់អ្វីមួយ ការនិយាយជាដើម ។ ខាងក្រោមនេះបង្ហាញពីចលនាតាមឆន្ទៈ ។




1. ទូរស័ព្ទរោទ៍ ។ សំឡេងរោទ៍នេះជាព័ត៌មាននៃមជ្ឈដ្ឋានជុំវិញដែលណឺរ៉ូនវិញ្ញាណនាំក្នុងត្រចៀកចាប់បាន ហើយបង្កើតបានជាអាំងភ្លុចប្រសាទ ។
2. បន្ទាប់មកណឺរ៉ូនវិញ្ញាណនាំ ដឹកនាំព័ត៌មាន(អាំងភ្លុច) ទៅកាន់ណឺរ៉ូនភ្ជាប់នៅក្នុងខួរក្បាល ។ ពេលនោះក្មេងប្រុសដឹងថាទូរស័ព្ទកំពុងរោទ៍ ។ បន្ទាប់មកខួរក្បាលក្មេងប្រុសសម្រេចចិត្តឱ្យក្មេងប្រុសលើកដៃកាន់ទូរស័ព្ទ ។




3. ណឺរ៉ូនភ្ជាប់នៅក្នុងខួរក្បាលនិងខួរឆ្អឹងខ្នងដឹកនាំព័ត៌មាននៃ "ការលើកទូរស័ព្ទ" ទៅកាន់ណឺរ៉ូនចលករ ។
4. ណឺរ៉ូនចលករ ដឹកនាំព័ត៌មានទៅកាន់សាច់ដុំ ។ ពេលនេះក្មេងប្រុសលើកទូរស័ព្ទ ។

*រូបទី 3.4 : ចលនាតាមឆន្ទៈ*

## 2.2. រេផ្លិច

1. នៅពេលក្មេងស្រីប៉ះបន្លាស្រួច ណឺរ៉ូនវិញ្ញាណនាំទទួលបានព័ត៌មានឈឺចាប់ ។ ណឺរ៉ូននេះដឹកនាំព័ត៌មានទៅកាន់ខួរឆ្អឹងខ្នង ។

2. ណឺរ៉ូនភ្ជាប់នៅក្នុងខួរឆ្អឹងខ្នងដឹកនាំព័ត៌មានទៅកាន់ណឺរ៉ូនចលករ ។




*រូបទី 3.5 : រេផ្លិច*

3. ណឺរ៉ូនចលករដឹកនាំព័ត៌មានទៅកាន់សាច់ដុំមួយចំនួននៃដៃ ។

4. ក្មេងស្រីដកដៃចេញពីបន្លាយ៉ាងរហ័ស ។

5. នៅពេលក្មេងស្រីដកដៃចេញ អាំងភ្លុចប្រសាទធ្វើដំណើរទៅខួរក្បាល ។ ពេលនោះក្មេងស្រីមានអារម្មណ៍ឈឺចាប់ ។

រេផ្លិចជាតំណបស្វ័យប្រវត្តិនិងអឆន្ទៈទៅនឹងរំញោចណាមួយ ។ សកម្មភាពធម្មតាជាច្រើនរបស់សារពាង្គកាយ ត្រូវបានត្រួតពិនិត្យដោយរេផ្លិច រួមមានការព្រិចភ្នែក ការក្អកធ្វើឱ្យបំពង់ខ្យល់ស្អាត ចលនាដង្ហើម ចង្វាក់បេះដូង រន្ធប្រស្រីរួមតូចពេលមានពន្លឺខ្លាំង ហើយបើកធំនៅពេលមានពន្លឺខ្សោយ ។ល ។ តើការដកដៃចេញពីវត្ថុក្ដៅឬស្រួចនិងការចាប់កាន់វត្ថុអ្វីមួយមានលក្ខណៈខុសគ្នាយ៉ាងដូចម្ដេច ? ការដកដៃចេញពីវត្ថុក្ដៅ ឬស្រួចជាចលនារេផ្លិច ។ ចលនានេះប្រព្រឹត្តទៅដោយស្វ័យប្រវត្តិនិងដោយអឆន្ទៈ ។ ចំណែកឯការចាប់កាន់វត្ថុអ្វីមួយ គឺជាចលនាតាមឆន្ទៈ ។ ចលនានេះអាចធ្វើទៅបានដោយមានការហាត់រៀននិងដោយញាណ ។ ចលនាឆ្លើយតបដោយរេផ្លិចជាចលនាលឿនជាទីបំផុត ព្រោះអាំងភ្លុចប្រសាទធ្វើដំណើរឆ្លងកាត់តាមសរសៃប្រសាទមួយជួរប៉ុណ្ណោះ ហៅថាធ្នូរេផ្លិច ។

វេជ្ជបណ្ឌិតបានប្រើប្រាស់វេធ្លិចនៃការកន្ត្រាក់ជង្គង់និងវេធ្លិចប្តូរទំហំរន្ធប្រស្រីភ្នែកក្នុងតំណាបទៅនិងពន្លឺ ដើម្បីត្រួតពិនិត្យលក្ខខណ្ឌនៃប្រព័ន្ធប្រសាទ ។ ប្រសិនបើគ្មានតំណាបទៅនិងវេធ្លិចឬតំណាបយឺតបង្ហាញថាប្រព័ន្ធប្រសាទមានភាពមិនប្រក្រតី ។

## 3. សារធាតុញៀននិងប្រព័ន្ធប្រសាទ


រូបទី 3.6 : មនុស្សញៀនស្រា

សារធាតុញៀនមួយចំនួន មានគ្រោះថ្នាក់ខ្លាំងចំពោះសុខភាព ពីព្រោះវាមានឥទ្ធិពលភ្លាមៗទៅលើប្រព័ន្ធប្រសាទ ។ នីកូទីនជាសារធាតុញៀននៅក្នុងថ្នាំជក់ ។ វាបង្កើនអត្រាចង្វាក់បេះដូង សម្ពាធឈាម អត្រាដង្ហើម ធ្វើឱ្យបញ្ញាធ្លាក់ចុះដូចជាមិនសូវមានការចងចាំ មិនហ៊ានធ្វើការសម្រេចចិត្ត ឬការវិនិច្ឆ័យមានការយឺតយ៉ាវ ខួរក្បាលហាក់ដូចជាស្ពឹកស្រពន់ ។

អាល់កុលជាសារធាតុញៀននៅក្នុងស្រា ។ នៅពេលផឹក អាល់កុលជ្រាបចូលដោយផ្ទាល់ទៅក្នុងចរន្តឈាមតាមភ្នាសពោះវៀនតូច ។ ប្រសិនបើផឹកច្រើន អាល់កុលបន្ថយសកម្មភាពនៃមជ្ឈមណ្ឌលប្រសាទ ការវិនិច្ឆ័យ ការពិចារណា និងការប្រមូលអារម្មណ៍ត្រូវថយចុះ ។ ការផឹករយៈពេលយូរអាចប៉ះពាល់ដល់សុខភាពដូចជា បាត់បង់ការចងចាំ វង្វេងវង្វាន់ បាត់បង់លំនឹង និងកើតជំងឺមហារីកនៅលើសរីរាង្គជាច្រើន ។

ភេសជ្ជៈមួយចំនួនមានក្លិនឈ្ងុយឆ្ងាញ់ដូចជាកាហ្វេ តែជាដើម ។ ប្រសិនបើយើងផឹកវាក្នុងបរិមាណតិចតួចគឺ 1 ឬ 2 ពែងក្នុងមួយថ្ងៃ កាហ្វេ និងតែ នឹងភ្ញោចប្រព័ន្ធប្រសាទដោយជួយសម្រួលការគិតផ្នែកបញ្ញា ។ ប៉ុន្តែប្រសិនបើយើងផឹកហួសកំណត់ វានឹងបណ្តាលឱ្យមានវិបត្តិផ្នែកប្រព័ន្ធប្រសាទដូចជាដេកមិនលក់ បង្កើនអត្រាចង្វាក់បេះដូង បណ្តាលឱ្យរសាប់រសល់ ដំណើរញ័រៗ ។ កាហ្វេអ៊ីនជាសារធាតុភ្ញោចប្រព័ន្ធប្រសាទយ៉ាងខ្លាំង ។ សារធាតុនេះមាននៅក្នុងភេសជ្ជៈដូចជា កាហ្វេ តែ កូកាកូឡា ហើយធ្វើឱ្យមានបញ្ហាដល់សុខភាព ។

## 4. ជំងឺប្រព័ន្ធប្រសាទ

ជំងឺគ្រុនស្វិតដៃជើង ជាជំងឺមួយដែលបង្កឡើងដោយវីរុសគ្រុនស្វិតដៃជើង ។ វីរុសនេះមាននៅក្នុងខ្យល់ ជាពិសេសនៅកន្លែងគ្មានអនាម័យ ។ ភាគច្រើន ជំងឺនេះតែងកើតឡើងនៅលើកុមារ ។ មនុស្សអាចឆ្លងជំងឺនេះបានតាមរយៈការប៉ះពាល់គ្នា ។ វីរុសគ្រុនស្វិតដៃជើងចូលទៅក្នុងឈាមតាមអាហារនិងផ្លូវដង្ហើម ហើយទៅបំផ្លាញមជ្ឈមណ្ឌលប្រសាទ ។ នៅទីនោះជាពិសេសនៅក្នុងខួរឆ្អឹងខ្នង វាបំផ្លាញណឺរ៉ូនចលករ ដែលបញ្ជាសាច់ដុំឱ្យធ្វើចលនា ។ ក្រោយពេលបំផ្លាញហើយ ណឺរ៉ូននេះមិន

អាចកើតឡើងវិញម្តងទៀតបានទេ ហើយសាច់ដុំនោះក៏មិនអាចធ្វើចលនាបានឡើយ ។ ក្នុងករណីបែបនេះ វីរុសគ្រុនស្វិតដៃជើង អាចបណ្តាលឱ្យស្លាប់អវយវៈ ។ ប្រសិនបើវាបំផ្លាញណឺរ៉ូនដែលបញ្ជាសាច់ដុំសន្ទះទ្រូងនោះ ប្រដាប់ដង្ហើមនឹងមិនអាចធ្វើចលនាបាន ហើយកុមារនឹងត្រូវស្លាប់ភ្លាមៗ ។ ជំងឺគ្រុនស្វិតដៃជើងមិនអាចព្យាបាលបានទេ ព្រោះគ្មានថ្នាំដែលមានប្រសិទ្ធភាពសម្រាប់ព្យាបាល ។ ដូចនេះដើម្បីបង្ការជំងឺគ្រុនស្វិតដៃជើង មានតែចាក់វ៉ាក់សាំងជំងឺនេះទេទើបកុមារចៀសផុតពីការកើតជំងឺនេះ ។

**មេរៀនសង្ខេប**

- បរិមណ្ឌលប្រសាទបង្កឡើងដោយសរសៃប្រសាទលលាដ៍ក្បាលចំនួន 12 គូនិងសរសៃប្រសាទខួរឆ្អឹងខ្នងចំនួន 31 គូ ។ សរសៃប្រសាទទាំងនេះ ភ្ជាប់មជ្ឈមណ្ឌលប្រសាទ ជាមួយផ្នែកផ្សេងៗទៀតនៃសារពាង្គកាយ ។
- ចលនាឆន្ទៈ ជាចលនាដែលកើតឡើងដោយញាណដូចជា ការអាន ការលើកវត្ថុអ្វីមួយ ការរាំជាដើម ។ រេផ្លិចជាចលនាដែលកើតឡើងដោយអញ្ញាណ ។ ចលនានេះ កើតឡើងដោយស្វ័យប្រវត្តិដូចជា ការក្អក ការកន្ត្រាក់នៃបេះដូងជាដើម ។
- សារធាតុមួយចំនួនមានគ្រោះថ្នាក់ចំពោះសុខភាពដូចជា នីកូទីន អាល់កុល កាហ្វេអ៊ីនជាដើម ដោយវាមានឥទ្ធិពលទៅលើប្រព័ន្ធប្រសាទ ។

## ? សំណួរ

1. តើបរិមណ្ឌលប្រសាទកើតឡើងពីអ្វី ?
2. តើសកម្មភាពឆន្ទៈជាអ្វី ?
3. តើសកម្មភាពរេផ្លិចជាអ្វី ?
4. តើរេផ្លិចរបស់អ្នកមានលក្ខណៈលឿននិងស្វ័យប្រវត្តិ មានអំណោយផលដូចម្តេចចំពោះអ្នក ?
5. ការធ្វើតេស្តគោះជង្គង់ជាវិធីសង្កេតលើលក្ខណៈរាងកាយរបស់មនុស្ស ។ តើការធ្វើតេស្តនេះមានគោលបំណងដូចម្តេច ? ប្រសិនបើមនុស្សដែលត្រូវគេធ្វើតេស្តនោះ មានលក្ខណៈមិនប្រក្រតី តើការធ្វើតេស្តនោះផ្តល់លទ្ធផលដូចម្តេច ?
6. តើសកម្មភាពឆន្ទៈនិងអឆន្ទៈខុសគ្នាដូចម្តេច ?

# ការងារប្រតិបត្តិ : ចលនារេផ្លិច

## 1. ទស្សនៈ

បង្ហាញពីចលនារេផ្លិច

## 2. រយៈពេល 1ម៉ោង

## 3. ដំណើរការ



- ឱ្យមិត្តអ្នកអង្គុយគងអន្ទាក់ខ្លា
- អ្នកយកចំហៀងដៃ(ដូចបង្ហាញក្នុងរូប)វាយទៅលើសាច់ទន់ៗដែលនៅពីក្រោមអង្គញរបស់ជើងអ្នកដែលគងពីលើ ។

## 4. វិភាគ

- ចូរសង្កេតតំណាបជើងដែលអ្នកវាយ ។
- តើអ្វីជារំញោច ?
- តើចម្លើយជាអ្វី ?
- នៅពេលអ្នកវាយក្បាលជង្គង់មិត្តរបស់អ្នកលើកទីមួយ តើជើងមានសកម្មភាពដូចម្តេច ?
- នៅពេលអ្នកវាយក្បាលជង្គង់លើកទី 2 តើជើងមានសកម្មភាពដូចម្តេច ?
- តើគោលបំណងពីរយ៉ាងនៃតំណាបរេផ្លិចជាអ្វី ?
- តើតំណាបនេះអាចផ្លាស់ប្តូរឬទេ ប្រសិនបើដៃគូរបស់អ្នកសាកល្បងត្រួតពិនិត្យតំណាបនេះ ? ចូរពន្យល់ ។

## ? សំណួរបញ្ចប់ជំពូកទី២

I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវ

1. អាំងភ្លុចធ្វើដំណើរឆ្លងកាត់ស៊ីណាប់តាមរយៈ

☐ ក. អូស្សូស ☐ ខ. តួកោសិកា ☐ គ. ណឺរ៉ូនភ្ជាប់ ☐ ឃ. សារធាតុគីមី

2. ណឺរ៉ូនដែលចាប់រំញោចនៅក្នុងស្បែកនិងភ្នែកជា

☐ ក. ណឺរ៉ូនភ្ជាប់ ☐ ខ. ណឺរ៉ូនចលករ ☐ គ. ស៊ីណាប់ ☐ ឃ. ណឺរ៉ូនវិញ្ញាណនាំ

3. លំហរវាងណឺរ៉ូនពីរហៅថា

☐ ក. ដង់ឌ្រីត ☐ ខ. តួកោសិកា ☐ គ. ស៊ីណាប់ ☐ ឃ. អាក់សូន

4. ផ្នែកដែលទាក់ទងនិងចលនាវេទ្ធិចជា

☐ ក. ខួរធំ ☐ ខ. ខួរតូច ☐ គ. ខួរឆ្អឹងខ្នង ☐ ឃ. ខួរកញ្ចឹងក

II. ចូរបំពេញចន្លោះនៃឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ

1. ដង់ឌ្រីតទទួលនិងបញ្ជូន ............................ ទៅកាន់ .................. ។

2. បរិមណ្ឌលប្រសាទ មានសរសៃប្រសាទ ............................ និង .......... ។

3. ខួរក្បាលភ្ជាប់ទៅនិងខួរឆ្អឹងខ្នងដោយ ............................................ ។

4. សញ្ញាអគ្គិសនីដែលធ្វើដំណើរតាមបណ្តោយណឺរ៉ូនហៅថា .......................... ។

5. ផ្នែកសំខាន់ពីរនៃប្រព័ន្ធប្រសាទជា ............................ និង .................. ។

III. ចូរឆ្លើយនិងសំណួរខាងក្រោមនេះ

1. ចូរប្រៀបធៀបមជ្ឈមណ្ឌលប្រសាទនិងបរិមណ្ឌលប្រសាទ ។

2. ចូរប្រៀបធៀបណឺរ៉ូនវិញ្ញាណនាំនិងណឺរ៉ូនចលករ ។

3. ចូរពណ៌នាពីចលនាវេទ្ធិចនៅពេលអ្នកប៉ះនឹងវត្ថុមុតស្រួច ។

4. ចូរប្រាប់ពីប្រភេទណឺរ៉ូននីមួយៗនូវទីតាំងនិងនាទីរបស់វា ។

5. តើវេទ្ធិចការពារដូចម្តេច ?

6. ចូរពណ៌នាពីដំណើរអាំងភ្លុចនៅត្រង់ស៊ីណាប់ ។

7. ប្រសិនបើសត្វរុយទុំនៅលើមុខនិងខ្នងរបស់អ្នក ។ តើនៅទីតាំងណាមួយដែលអ្នកទទួលអារម្មណ៍មុនគេ ? ចូរពន្យល់ ។

8. តើរំញោចជាអ្វី ? ចូរឱ្យឧទាហរណ៍បានបី ។

# ជំពូកទី 3 ប្រព័ន្ធស៊ាំ





តាមធម្មតា មនុស្សម្នាក់ៗសុទ្ធតែធ្លាប់ឆ្លងជំងឺ ជាពិសេសជំងឺគ្រុនផ្ដាសាយ ។ ជំងឺនេះងាយឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ព្រោះវាងាយឆ្លងតាមខ្យល់នៅក្នុងបរិយាកាស ។

នៅពេលគ្រុនឬក្ដៅខ្លួន សារពាង្គកាយយើងស្ថិតក្នុងស្ថានភាពប្រយុទ្ធតតាំងជាមួយវីរុសផ្ដាសាយ ។ ជំងឺផ្សេងៗទៀតជាច្រើន បណ្ដាលមកពីវីរុស ឬបាក់តេរី ដែលជ្រៀតចូលទៅក្នុងសារពាង្គកាយ ។ តើសារពាង្គកាយរបស់យើង ប្រយុទ្ធទល់នឹងការជ្រៀតចូលរបស់ភ្នាក់ងារបង្កជំងឺតាមរបៀបណា ?

# 1 កិច្ចការពារសារពាង្គកាយ

**ចប់មេរៀននេះ សិស្សអាច**

- ពណ៌នាពីរបាំងការពារទីមួយប្រឆាំងនិងមេរោគ
- បង្ហាញថាតំណបរលាកជារបាំងការពារទីពីរ
- រៀបរាប់ពីរបាំងការពារទីបីនៃសារពាង្គកាយ ។

ភ្នាក់ងារបង្កជំងឺ ឬមេរោគ (វីរុសនិងបាក់តេរី) មាននៅគ្រប់ទីកន្លែងដូចជា ក្នុងខ្យល់ លើដី ក្នុងទឹក នៅលើស្បែករបស់យើង លើសម្ភារះប្រើប្រាស់ផ្សេងៗ លើម្ហូបអាហារ លើសត្វចិញ្ចឹម ។ ប៉ុន្តែជាសំណាងល្អ យើងនៅតែមានសុខភាពល្អ ស្ទើរគ្រប់ពេល ពីព្រោះសារពាង្គកាយរបស់យើង មានរបាំងការពារទល់នឹងការជ្រៀតចូលនៃភ្នាក់ងារបង្កជំងឺទាំងនោះ ។

តាមធម្មតាសារពាង្គកាយរបស់យើង មានរបាំងការពារសំខាន់បី ដែលការពារយើងមិនឱ្យឆ្លងជំងឺបានស្ទើរទាំងអស់ ។ របាំងការពារទីមួយ រារាំងមិនឱ្យភ្នាក់ងារបង្កជំងឺជ្រៀតចូលសារពាង្គកាយបាន ។ របាំងការពារទីពីរនិងទីបី ធ្វើសកម្មភាពនៅពេលភ្នាក់ងារបង្កជំងឺបានជ្រៀតចូលទៅក្នុងសារពាង្គកាយ ។

## 1. របាំងការពារទីមួយ

របាំងការពារទីមួយប្រៀបដូចជាអាវក្រោះ ។ វាជារបាំងការពារដំបូងដែលរារាំងភ្នាក់ងារបង្កជំងឺភាគច្រើន មិនឱ្យចូលទៅក្នុងសារពាង្គកាយបាន ។ របាំងការពារទីមួយមានស្បែក ទឹកភ្នែក ស្លេស្មរោមល្អិតៗ ទឹកមាត់ ជាតិអាស៊ីតក្នុងក្រពះ ។ របាំងការពារទាំងនេះទាក់យកនិងសម្លាប់មេរោគ នៅពេលវាចូលទៅប៉ះផ្ទាល់ ។

### 1.1. ស្បែក



*រូបទី 1.1 : ស្បែក*

ស្បែកគ្មានរបួសរារាំង មិនឱ្យភ្នាក់ងារបង្កជំងឺផ្សេងៗ ជ្រៀតចូលទៅក្នុងសារពាង្គកាយបាន ។ នៅលើស្បែកមេរោគត្រូវបានបំផ្លាញដោយសារធាតុគីមីដែលមាននៅក្នុងប្រេងឬញើស ។ មេរោគអាចជ្រៀតចូលបាន លុះត្រាតែស្បែកមានរបួស ។

## 1.2. ទឹកភ្នែក

ក្រពេញទឹកភ្នែក ដែលស្ថិតនៅក្នុងភ្នែកមាននាទីផលិតទឹកភ្នែក ។ ទឹកភ្នែកលាងសំអាតធូលីកខ្វក់ដែលមានផ្ទុកមេរោគចេញពីភ្នែក ។ ទឹកភ្នែកមានផ្ទុកសារធាតុគីមីដែលសម្លាប់មេរោគដោយបំផ្លាញភ្នាសគ្រោងរបស់វា ។



*រូបទី 1.2 : ទឹកភ្នែក*

## 1.3. ស្លេស្ម

ស្លេស្មជាជាតិរំអិលនៃស្រទាប់ភ្នាសសើម ដែលគ្របដណ្តប់ប្រហោងច្រមុះនិងបំពង់ក ។ ស្លេស្មជាអន្ទាក់ចាប់យកកម្ទេចកំទីធូលីនិងមេរោគពីក្នុងខ្យល់ដង្ហើមរបស់យើង ។

*ឧទាហរណ៍* : ស្លេស្ម បំពង់ក ។



*រូបទី 1.3 : ស្រទាប់ស្លេស្ម*

## 1.4. រោមល្អិតៗ

រោមល្អិតៗនៅក្នុងរន្ធច្រមុះ ក៏មាននាទីចាប់យកកម្ទេចកំទីធូលីនិងមេរោគផងដែរ ។ ទម្រង់មួយផ្សេងទៀតស្នារៗដូចសរសៃសក់ នៅក្នុងបំពង់ខ្យល់ហៅថា រោមញ័រ ។ វាចាប់យកបំណែកតូចៗនៅក្នុងខ្យល់ដង្ហើមចូលមិនឱ្យចូលទៅក្នុងសួតបាន ។ យើងបញ្ចេញវាមកក្រៅខ្លួនវិញ នៅពេល ញើស សំបោរ ឬក្អក ។

## 1.5. ប្រដាប់រំលាយអាហារ

ភ្នាក់ងារបង្កជំងឺខ្លះទៀត មាននៅក្នុងអាហារ ។ ធាតុរាវនៅក្នុងមាត់ជាទឹកមាត់ ។ ទឹកមាត់មានផ្ទុកសារធាតុគីមីដែលអាចសម្លាប់ភ្នាក់ងារបង្កជំងឺបានមួយចំនួន ។

នៅក្នុងប្រដាប់រំលាយអាហារ មានអង់ស៊ីមរបស់ក្រពះ ថ្លើមនិងលំពែងដែលមាននាទីបំផ្លាញភ្នាក់ងារបង្កជំងឺ ។ ម្យ៉ាងទៀត ជាតិអាស៊ីតនៅក្នុងក្រពះខ្លាំងគ្រប់គ្រាន់ អាចសម្លាប់មេរោគជាច្រើនជ្រៀតចូលតាមអាហារដែលយើងបរិភោគ ។

# 2. របាំងការពារទីពីរ

ប្រសិនបើភ្នាក់ងារបង្កជំងឺ អាចឆ្លងកាត់របាំងការពារទីមួយបាន សារពាង្គកាយនៅមានវិធីផ្សេងទៀត សម្រាប់សម្លាប់មេរោគ ។ មេរោគជ្រៀតចូលទៅក្នុងសារពាង្គកាយបាន តាមរយៈស្បែកមានរបួស ។ មេរោគបានទៅបំផ្លាញកោសិកានៃសារពាង្គកាយ ហើយកោសិកាឆ្លងរោគនេះ បញ្ចេញសារធាតុគីមី ដែលធ្វើឱ្យកើតមានតំណបរលាក គឺជារបាំងការពារទីពីររបស់សារពាង្គកាយ ។

## 2.1. គោលិកាស

នៅក្នុងប្រដាប់របស់ឈាម មានគោលិកាសច្រើនប្រភេទ ។ គ្រប់គោលិកាសទាំងអស់មាននាទីប្រឆាំងជាមួយភ្នាក់ងារបង្កជំងឺ ។ នៅទីនេះគោលិកាសដែលពាក់ព័ន្ធក្នុងតំណាបរលាក ជាផាកូស៊ីត ។ ផាកូស៊ីតជាគោលិកាសមួយបែប ដែលក្ដោបនិងបំផ្លាញភ្នាក់ងារបង្កជំងឺនោះ ។



*រូបទី 1.4 : សរសៃឈាម*

## 2.2. តំណាបរលាក

ក្នុងរយៈពេលតំណាបរលាក សារធាតុគីមីដែលផលិតដោយកោសិកាឆ្លងមេរោគ ធ្វើឱ្យសរសៃឈាមនៅត្រង់កន្លែងមានរបួសហើមនិងរីកធំ ។ នៅពេលនោះ ឈាមហូរយ៉ាងច្រើនទៅកាន់កន្លែងមានរបួស ។ ជាលទ្ធផល មានគោលិកាសប្រឆាំងនឹងមេរោគជាច្រើន ត្រូវបានបញ្ជូនទៅកាន់កន្លែងនោះ ។ នៅក្នុងតំណាបរលាកនេះ ធាតុរាវនិងគោលិកាសជ្រៀតចេញតាមចន្លោះកោសិកានៃភ្នាសសរសៃប្ញូរ ដែលធ្វើឱ្យកន្លែងមានមេរោគឆ្លងនោះឡើងក្រហម និងហើមប៉ោង ។ គោលិកាងាប់ កោសិកាងាប់ខូចខាតរបស់សារពាង្គកាយនិងមេរោគងាប់ផ្សំជាមួយធាតុរាវបង្កើតបានជាសារធាតុពណ៌លឿងរាវឬពណ៌ស ហៅថាខ្ទុះ ។ ជារឿយៗ ខ្ទុះប្រមូលផ្ដុំនៅត្រង់មុខរបួស ។ ប្រសិនបើយើងយកដៃទៅពាល់កន្លែងហើមនោះយើងមានអារម្មណ៍ក្ដៅជាងពេលធម្មតា ។

## 2.3. ការឡើងកម្ដៅ

ក្នុងករណីមួយចំនួន សារធាតុគីមីដែលផលិតឡើងក្នុងពេលតំណាបរលាក បណ្ដាលឱ្យឡើងកម្ដៅ ។ ថ្វីបើការឡើងកម្ដៅនៃសារពាង្គកាយ ធ្វើឱ្យយើងមានអារម្មណ៍មិនល្អ ប៉ុន្តែវាជួយឱ្យសារពាង្គកាយរបស់យើងប្រឆាំងជាមួយការឆ្លងមេរោគនេះ ។ ភ្នាក់ងារបង្កជំងឺមួយចំនួន មិនអាចលូតលាស់និងបន្តពូជបានល្អនៅក្នុងសីតុណ្ហភាពខ្ពស់ទេ ។ ការឡើងកម្ដៅ ជាសញ្ញាមួយបង្ហាញថា សារពាង្គកាយកំពុងប្រយុទ្ធប្រឆាំងជាមួយភ្នាក់ងារបង្កជំងឺ ។ ប៉ុន្តែប្រសិនបើ ក្ដៅខ្លាំងពេកក៏បណ្ដាលឱ្យមានគ្រោះថ្នាក់បានដែរ ។ សីតុណ្ហភាពខ្ពស់ជាង 40°C អាចចាត់ទុកថាគ្រោះថ្នាក់ បើខ្ពស់ជាង 45°C អាចបណ្ដាលឱ្យស្លាប់បាន ។

នៅពេលភ្នាក់ងារបង្កជំងឺជាវីរុស កោសិកាដែលត្រូវបានវីរុសឆ្លង ផលិតសារធាតុគីមីម្យ៉ាងហៅថា **អាំងទែផេរ៉ុង** ។ សារធាតុនេះ ភ្ជាប់ទៅនឹងកោសិកាដែលមិនបានបង្ករោគ ហើយការពារមិនឱ្យវីរុសនោះបន្តពូជលើកោសិកានេះបាន ។

## 3. របាំងការពារទី ៣

នៅពេលដែលតំណាបរលាកគ្មានសមត្ថភាពរារាំង ភ្នាក់ងារបង្កជំងឺក្លាយជាគោលដៅសំខាន់ក្នុងការតាមបំផ្លាញពីប្រព័ន្ធស៊ាំដែលជារបាំងការពារទីបី ។ ប្រព័ន្ធស៊ាំទទួលស្គាល់ ប្រយុទ្ធតតាំង សម្លាប់ និងរំលឹកឡើងវិញនូវប្រភេទនីមួយៗនៃភ្នាក់ងារបង្កជំងឺ ឬសារធាតុចម្លែកដែលជ្រៀតចូលមកក្នុងសារពាង្គកាយ ។ ក្នុងករណីនេះប្រព័ន្ធស៊ាំនិងផលិតអង់ទីករនិងកោសិកាពិសេសសម្រាប់ភ្ជាប់និងធ្វើឱ្យភ្នាក់ងារបង្កជំងឺ ចុះខ្សោយហើយសម្លាប់វា ។ ប្រព័ន្ធស៊ាំផលិតអង់ទីករ ឬកោសិកាពិសេសសម្រាប់ប្រឆាំងនិងភ្នាក់ងារបង្កជំងឺប្រភេទនីមួយៗ ។

**មេរៀនសង្ខេប**

- ស្បែក ទឹកភ្នែក ស្លេស្ម រោមល្អិតៗ ទឹកមាត់ ជាតិអាស៊ីតក្នុងក្រពះជារបាំងការពារទីមួយដែលរារាំងភ្នាក់ងារបង្កជំងឺមិនឱ្យជ្រៀតចូលទៅក្នុងសារពាង្គកាយ ។
- តំណាបរលាកជារបាំងការពារទីពីរ ប្រឆាំងទល់នឹងភ្នាក់ងារបង្កជំងឺ ។ គោលិកាសដែលពាក់ព័ន្ធក្នុងតំណាបរលាកនេះជា ផាកូស៊ីត ។ ផាកូស៊ីតជាកោលិកាសមួយបែបដែលត្លេបនិងសម្លាប់មេរោគ ។
- របាំងការពារទីបី ជាប្រព័ន្ធស៊ាំរបស់សារពាង្គកាយ ។ ប្រព័ន្ធស៊ាំ ផលិតអង់ទីករនិង កោសិកាពិសេសៗសម្រាប់ភ្ជាប់និងធ្វើឱ្យភ្នាក់ងារបង្កជំងឺ ចុះខ្សោយហើយសម្លាប់វា ។

## ? សំណួរ

1 តើរបាំងការពារទីមួយមានអ្វីខ្លះ ? ចូររៀបរាប់ ។

2 តើតំណាបរលាកចាប់ផ្តើមកើតឡើងដោយសារអ្វី ?

3 តើផាកូស៊ីតមាននាទីអ្វីនៅក្នុងការការពារសារពាង្គកាយ ?

4 តើរបាំងការពារទីបីជាអ្វី ?

5 តាមធម្មតា តើភ្នាក់ងារបង្ករជំងឺជ្រៀតចូលក្នុងសារពាង្គកាយយ៉ាងដូចម្តេច ?

6 តើអាំងទែផេរ៉ុងជាអ្វី ? តើវាផលិតឡើងនៅពេលណា ?

7 ហេតុអ្វីបានជាមុខរបួសយើងក្តៅហើម ហើយក្រហម ?

# 2 ប្រព័ន្ធស៊ាំ

**ចប់មេរៀននេះ សិស្សអាច**

- ❑ បង្ហាញពីតំណបស៊ាំប្រឆាំងនឹងភ្នាក់ងារបង្កជំងឺ
- ❑ ប្រៀបធៀបភាពស៊ាំសកម្មនិងភាពស៊ាំអកម្ម
- ❑ ពណ៌នាពីការបង្ការនៃវ៉ាក់សាំងចំពោះជំងឺឆ្លង
- ❑ ពន្យល់ពីឥទ្ធិពលនៃវីរុស HIV លើប្រព័ន្ធស៊ាំ ។

ប្រសិនបើភ្នាក់ងារបង្កជំងឺ មានសមត្ថភាពឆ្លងកាត់កិច្ចការពាររបស់សារពាង្គកាយ ប្រព័ន្ធស៊ាំមានប្រតិកម្មតបទៅនឹងភ្នាក់ងារបង្កជំងឺនោះ ។ សារធាតុដែលចាប់ផ្តើម ធ្វើឱ្យកើតមានកិច្ចការពារពិសេស ឬតំណបស៊ាំ គឺអង់ទីសែន ។ តំណបស៊ាំត្រូវបានត្រួតពិនិត្យដោយប្រព័ន្ធស៊ាំ ដែលជាប្រព័ន្ធប្រឆាំងនឹងជំងឺនៃសារពាង្គកាយ ។

## 1. តំណបស៊ាំ




*រូបទី 2.1 : តំណបស៊ាំ*

តំណបស៊ាំអាចចែកចេញជាបួនដំណាក់កាល :

- ដំណាក់កាលទទួលស្គាល់ : គោលិកាសព័ទ្ធជុំវិញភ្នាក់ងារបង្កជំងឺនិងឱ្យសញ្ញាទៅឡាំផូស៊ីត T ។ ឡាំផូស៊ីត T ជាច្រើនត្រូវបានផលិត ។ ឡាំផូស៊ីត T ជំនួយឱ្យសញ្ញាទៅឡាំផូស៊ីត B ។
- ដំណាក់កាលប្រើប្រាស់ : ឡាំផូស៊ីត B ដុះដាលជាច្រើន ។ ឡាំផូស៊ីតខ្លះក្លាយជាប្លាស្មូស៊ីត ខ្លះទៀតរក្សាជាឡាំផូស៊ីត B លំនឹក ។
- ដំណាក់កាលបំផ្លាញ : អង់ទីករធ្វើឱ្យអង់ទីសែនចុះខ្សោយឬបង្អាក់សកម្មភាព ។ អង់ទីសែនដែលចុះខ្សោយត្រូវបានបំផ្លាញដោយឡាំផូស៊ីត T សម្លាប់ឬដោយជាកូស៊ីត ។

- ភាពស៊ាំ : ឡាំផូស៊ីត T លំនឹកនិងឡាំផូស៊ីត B លំនឹកមានសកម្មភាពយ៉ាងរហ័ស នៅពេលដែលអង់ទីសែនប្រភេទដូចគ្នាចូលក្នុងសារពាង្គកាយលើកទី 2 ។

ប្រព័ន្ធស៊ាំជាបណ្តុំកោសិកា និងជាលិកាទាំងអស់ ដែលជួយសារពាង្គកាយ ក្នុងការប្រឆាំងទៅនិងភ្នាក់ងារបង្កជំងឺ ។ ខួរឆ្អឹង គោលិកាសជាពិសេស ជាកូស៊ីត និងឡាំផូស៊ីត ព្រមទាំងជាលិកាប្រភេទផ្សេងៗនៃប្រព័ន្ធទឹករងៃ(កូនកណ្តុរទឹករងៃ អាមីដាល់ ទីមុស និងជាល) បង្កើតបានជាប្រព័ន្ធស៊ាំ ។

ប្រព័ន្ធស៊ាំ ផ្តល់ឱ្យយើងនូវភាពស៊ាំ ដែលជាសមត្ថភាពរបស់សារពាង្គកាយ ប្រឆាំងទល់និងការបង្កជំងឺ តាមរយៈការផលិតអង់ទីករ ដើម្បីបង្អាក់សកម្មភាពរបស់សារធាតុចម្លែក ឬកោសិកាចម្លែក ។

នៅពេលសារពាង្គកាយប្រឆាំងនិងជំងឺ គឺជាការប្រឆាំងទៅនិងអង់ទីសែន ។ អង់ទីសែនជាប្រូតេអ៊ីន ឬសារធាតុគីមី ដែលមិនមែនជារបស់សារពាង្គកាយ ។ អង់ទីសែន ស្ថិតនៅលើផ្ទៃខាងក្រៅរបស់វីរុស បាក់តេរី និងភ្នាក់ងារបង្កជំងឺផ្សេងៗទៀត ។ កាលណាប្រព័ន្ធស៊ាំ ទទួលស្គាល់អង់ទីសែន វាក៏បង្កើតអង់ទីករយថាប្រភេទ ។ អង់ទីករជាប្រូតេអ៊ីនដែលបង្កើតឡើងក្នុងសារពាង្គកាយ ដើម្បីឆ្លើយតបទៅនិងអង់ទីសែនយថាប្រភេទ ។ បន្ទាប់មក អង់ទីករចងភ្ជាប់ទៅនិងអង់ទីសែន ហើយបង្កើតបានជាបណ្តុំមួយ ដែលងាយស្រួលបំផ្លាញដោយជាកូស៊ីត ។

## 2. ប្រភេទនៃភាពស៊ាំ

សមត្ថភាពធន់ទៅនិងជំងឺពិសេសណាមួយ ជាភាពស៊ាំទៅនិងជំងឺនោះ ។ សមត្ថភាពរបស់សារពាង្គកាយ ធន់ទៅនិងជំងឺតាមរយៈការអភិវឌ្ឍភាពស៊ាំ គឺរស់នៅប្រកបដោយសុខភាពល្អ ។ ភាពស៊ាំមានពីរប្រភេទ ភាពស៊ាំអកម្ម និងភាពស៊ាំសកម្ម ។ ភាពស៊ាំអកម្ម ជាភាពស៊ាំដែលសារពាង្គកាយទទួលបានអង់ទីករ ពីឈាមរបស់មនុស្សម្នាក់ផ្សេងទៀត ឬពីសត្វណាមួយ ។ អាចនិយាយផ្សេងទៀតជាភាពស៊ាំអកម្មជាភាពស៊ាំខ្ចីពីគេ ។ ចំណែកភាពស៊ាំសកម្ម ជាភាពស៊ាំដែលសារពាង្គកាយផលិតអង់ទីករផ្ទាល់របស់ខ្លួន ដើម្បីប្រឆាំងទល់និងអង់ទីសែនពិសេសណាមួយ ។

### 2.1. ភាពស៊ាំអកម្ម

ភាពស៊ាំអកម្ម ជាភាពស៊ាំដែលកើតមានជាបណ្តោះអាសន្នតែប៉ុណ្ណោះ ។ តាមធម្មតា វត្តមាននៃភាពស៊ាំនេះមានរយៈពេលខ្លី ពីព្រោះក្រោយមកសារពាង្គកាយនិងបំផ្លាញអង់ទីករនេះ ។ ថ្វីបើសារពាង្គកាយមានភាពស៊ាំអកម្ម ក្នុងរយៈពេលខ្លីក៏ដោយ ប៉ុន្តែភាពស៊ាំនេះមានសកម្មភាពរហ័សណាស់ ។ អង់ទីកររបស់ម្តាយ ចូលទៅក្នុងឈាមរបស់ទារកមុនកំណើត ហើយផ្តល់ឱ្យទារកនូវភាពស៊ាំអកម្ម ។ អង់ទីករមាននៅក្នុងទឹកដោះម្តាយ ។ ភាពស៊ាំរបស់ម្តាយ



រូបទី 2.2 ទឹកដោះម្តាយផ្តល់ភាពស៊ាំអកម្មដល់ទារក

ការពារទារក ដោយប្រឆាំងទល់នឹងជំងឺឆ្លងភាគច្រើន ក្នុងរយៈពេល 2-3 ខែដំបូងនៃជីវិតរបស់ទារក។ មានភាពស៊ាំអកម្មមួយប្រភេទទៀត ***ឧទាហរណ៍*** កាលណាមនុស្សម្នាក់មានជំងឺធ្ងន់ធ្ងរ ដូចជាជំងឺរលាកថ្លើម គេត្រូវតែចាក់បញ្ចូលអង់ទីករ ដើម្បីជួយសារពាង្គកាយមនុស្សនោះឱ្យមានសមត្ថភាពប្រឆាំងនឹងជំងឺរលាកថ្លើមនេះបាន។ អង់ទីករនេះត្រូវបានយកចេញពីឈាមរបស់មនុស្សម្នាក់ផ្សេងទៀតដែលអាចប្រឆាំងទៅនឹងជំងឺរលាកថ្លើមនោះ។ ភាពស៊ាំអកម្មនេះក៏ត្រូវបង្កើតឡើងដោយវ៉ាក់សាំងផងដែរដូចជាវ៉ាក់សាំងបង្ការជំងឺតេតាណូសដែលផលិតចេញពីសត្វសេះ។

## 2.2. ភាពស៊ាំសកម្ម



*រូបទី 2.3 : ការចាក់ថ្នាំបង្ការ(វ៉ាក់សាំង)*

ភាពស៊ាំសកម្មជាភាពធន់ទៅនឹងមេរោគ ដោយសារពាង្គកាយអភិវឌ្ឍនូវភាពស៊ាំ តាមរយៈការប៉ះពាល់ផ្ទាល់ជាមួយភ្នាក់ងារបង្កជំងឺ។ ប្រសិនបើភ្នាក់ងារបង្កជំងឺជ្រៀតចូលទៅក្នុងសារពាង្គកាយ ភ្លាមនោះសារពាង្គកាយនឹងចាប់ផ្ដើមបង្កើតអង់ទីករ ដើម្បីបង្អាក់សកម្មភាពអង់ទីសែនរបស់មេរោគ។ បន្ទាប់មកអង់ទីករទាំងនោះមិនរលាយបាត់ទៅវិញទេ វាស្ថិតនៅក្នុងឈាម ដើម្បីត្រៀមបំពេញភារកិច្ច។ វានឹងក្លាយជាសកម្មឡើងវិញ នៅពេលសារពាង្គកាយជួបប្រទះជាមួយនឹងមេរោគបង្កជំងឺនេះម្ដងទៀត។ ស្ថិតក្រោមលក្ខខណ្ឌទាំងអស់នេះ សារពាង្គកាយមានភាពស៊ាំ សកម្មទៅនឹងជំងឺពិសេសណាមួយ។

មានវិធីមួយបែបទៀត ដើម្បីអភិវឌ្ឍភាពស៊ាំសកម្មទៅនឹងជំងឺពិសេសណាមួយ គឺការទទួលថ្នាំបង្ការរោគ។ ថ្នាំបង្ការរោគឬវ៉ាក់សាំងផ្ដល់ឱ្យយើងនូវភាពស៊ាំសកម្ម ប្រឆាំងទល់នឹងជំងឺពិសេសណាមួយ ហើយអ្នកទទួលវ៉ាក់សាំងនឹងមិនមានជំងឺនេះទៀតទេ។

ប្រភេទផ្សេងៗនៃភាពស៊ាំនិងប្រភពអង់ទីករ

| ប្រភេទនៃភាពស៊ាំ | ប្រភពអង់ទីករ | រយៈពេលបង្ការ |
|---|---|---|
| • ភាពស៊ាំសកម្មដោយធម្មជាតិ | • លូតលាស់ចេញពីការប៉ះផ្ទាល់ជាមួយភ្នាក់ងារបង្កជំងឺ | • មួយជីវិត |
| • ភាពស៊ាំសកម្មសិប្បនិមិត្ត | • លូតលាស់ចេញពីតំណបទៅនឹងវ៉ាក់សាំង | • មួយជីវិត |
| • ភាពស៊ាំអកម្មដោយធម្មជាតិ | • ទទួលបានពីទឹកដោះម្ដាយ | • បណ្ដោះអាសន្ន |
| • ភាពស៊ាំអកម្មសិប្បនិមិត្ត | • ទទួលបានពីមនុស្សផ្សេងទៀត ឬសត្វណាមួយ | • បណ្ដោះអាសន្ន |

## 3. វ៉ាក់សាំង (ឬថ្នាំបង្ការរោគ)



រូបទី 2.៤ : ប្រភេទវ៉ាក់សាំងផ្សេងៗ

ជំងឺឆ្លងត្រូវបានចម្លងតាមការប៉ះពាល់ផ្ទាល់ជាមួយសារពាង្គកាយដែលមានជំងឺឆ្លង តាមរយៈទឹកឬអាហារមិនស្អាត ប៉ះពាល់វត្ថុកខ្វក់និងសត្វមានជំងឺឆ្លង ។ដើម្បីបង្ការជំងឺឆ្លង គេប្រើវ៉ាក់សាំងសម្រាប់បង្កើតភាពស៊ាំ របស់សារពាង្គកាយប្រឆាំងនិងជំងឺឆ្លង ។

សារពាង្គកាយអាចបង្កើតភាពស៊ាំ តាមរយៈជំងឺមួយចំនួនដែលសារពាង្គកាយធ្លាក់ខ្លួនឈឺ ។ ក្នុងករណីនេះ កោលិកាសផលិតអង់ទីករប្រឆាំងទៅនិងជំងឺនោះ ។ ការធ្លាក់ខ្លួនឈឺជាវិធីមួយបែបដែលសារពាង្គកាយអាចបង្កើតភាពស៊ាំបាន ។

កាលពីសម័យមុន វីរុសដែលបង្កជំងឺកញ្ជ្រឹល ធ្វើឱ្យកុមារទាំងអស់មានជំងឺកញ្ជ្រឹល ។ តាមពិតជំងឺកញ្ជ្រឹលច្រើនកើតនៅវ័យកុមារ ។ សព្វថ្ងៃនេះ គេបានបង្កើតវ៉ាក់សាំងជំងឺកញ្ជ្រឹល ។ វ៉ាក់សាំងភាគច្រើនត្រូវបានចាក់បញ្ចូលទៅក្នុងសារពាង្គកាយ ។ វ៉ាក់សាំងខ្លះទៀតអាចចូលទៅក្នុងសារពាង្គកាយតាមរយៈការផឹក ឬការលេប ។

តាមធម្មតាវ៉ាក់សាំងមានផ្ទុកអង់ទីសែនងាប់ឬខ្សោយ ។ ក្នុងដំណាក់កាលអង់ទីសែនខ្សោយ ជួនកាលវាមិនធ្វើឱ្យសារពាង្គកាយឈឺឡើយ តែជួនកាលអាចឈឺក្នុងរយៈពេលខ្លី ។ ក្នុងពេលនោះវាបណ្តាលឱ្យកោលិកាសរបស់សារពាង្គកាយ ត្រៀមខ្លួនដើម្បីផលិតអង់ទីករ ប្រឆាំងនិងជំងឺ ថ្វីបើសារពាង្គកាយមិនមានជំងឺពិតប្រាកដក៏ដោយ ។ តាមធម្មតា អង់ទីករត្រូវបានផលិតជាលើកទីមួយតែមួយដងប៉ុណ្ណោះ ។ បន្ទាប់មកវាអាចបង្កើតយ៉ាងរហ័សនិងគ្រប់ពេលដែល អង់ទីសែននៃភ្នាក់ងារបង្កជំងឺនោះជ្រៀតចូលក្នុងសារពាង្គកាយម្តងទៀត ។

*ឧទាហរណ៍* កុមារម្នាក់បានចាក់វ៉ាក់សាំងជំងឺកញ្ជ្រឹល ។ បន្ទាប់មកប្រសិនបើសារពាង្គកាយរបស់កុមារនោះ ត្រូវបានវីរុសកញ្ជ្រឹលជ្រៀតចូលម្តងទៀត កុមារនោះនឹងមិនឈឺទៀតទេ ។

ព្រោះដោយសារសារពាង្គកាយបានត្រៀមហើយជាស្រេច ដើម្បីផលិតអង់ទីករប្រឆាំងនិងវីរុសកញ្ជ្រឹលយ៉ាងរហ័ស ។ ជាការពិត អង់ទីករប្រឆាំងនិងវីរុសកញ្ជ្រឹល មិនអាចប្រឆាំងនិងមេរោគដទៃទៀតទេ វ៉ាក់សាំងកញ្ជ្រឹល អាចឱ្យសារពាង្គកាយផលិតបានត្រឹមតែភាពស៊ាំនៃជំងឺកញ្ជ្រឹលតែប៉ុណ្ណោះ ។ វាមិនអាចជួយសារពាង្គកាយប្រឆាំងនិងជំងឺផ្សេងៗទៀតបានឡើយ ។ សព្វថ្ងៃនេះនៅប្រទេសកម្ពុជា កុមារបានទទួលការចាក់ថ្នាំបង្ការជំងឺមួយចំនួន ដូចជាជំងឺ កញ្ជ្រឹល ក្អកមាន់ ខាន់ស្លាក់ តេតាណូស របេង គ្រុនស្វិតដៃជើង ជំងឺរលាកសួត រលាកស្រោមខួរ និងជំងឺរលាកថ្លើមប្រភេទ B ជាដើម ។

# 4. អេដស៍និងប្រព័ន្ធស៊ាំ

អេដស៍ (AIDS) មានន័យថាប្រជុំរោគសញ្ញាដែលកើតមានឡើងដោយសារការចុះខ្សោយនៃប្រព័ន្ធស៊ាំរបស់មនុស្ស ។ ជំងឺនេះបង្កឡើងដោយវីរុសហ៊ីវ HIV ( H = Human I = Immunodeficiency V = Virus)




*រូបទី 2.5 : វីរុស HIV*




*រូបទី 2.6 : សកម្មភាពវីរុស*

1. វីរុសជ្រៀតចូលទៅក្នុងណ្វៃយ៉ូនៃឡាំផូស៊ីត
2. ឡាំផូស៊ីតត្រូវបានបំផ្លាញ
3. វីរុសបង្កើនចំនួន ហើយបំផ្លាញឡាំផូស៊ីតថ្មីៗទៀតជាច្រើន
4. កិច្ចការពារទប់ទល់នឹងជំងឺបាន (Seropositive)
5. កិច្ចការពារទប់ទល់និងជំងឺមិនសូវមានប្រសិទ្ធភាព : សារពាង្គកាយមានជំងឺ

វីរុសហ៊ីវ (HIV)មានលក្ខណៈខុសប្លែកពីវីរុសដទៃទៀត ។ វាវាយប្រហារកោសិកានៃប្រព័ន្ធស៊ាំ គឺឡាំផូស៊ីត T ។ ឡាំផូស៊ីត T ជាគោលិកាសមួយប្រភេទដែលមាននាទីភ្ញោចគោលិកាសប្រភេទផ្សេងទៀត(ឡាំផូស៊ីត B)ឱ្យផលិតអង់ទីករ ដើម្បីបំផ្លាញអង់ទីសែនរបស់ភ្នាក់ងារបង្កជំងឺ ។ វីរុស HIV បរាសិតនៅក្នុងកោសិកាឡាំផូស៊ីត T ។ វីរុសនេះជ្រៀតចូលទៅក្នុងឡាំផូស៊ីត T ហើយបន្តពូជ ។ ឡាំផូស៊ីត T ដែលឆ្លងមេរោគ ត្រូវបានបំផ្លាញ ។ វីរុស HIV សាយភាយនៅក្នុងឈាម ហើយចម្លងមេរោគនៅក្នុងឡាំផូស៊ីត T ថ្មីៗទៀត ។ អង់ទីករអាចធ្វើឱ្យវីរុស HIV គ្មានសកម្មភាព នៅពេលដែលវីរុសនេះស្ថិតនៅក្នុងឈាម ។ ប៉ុន្តែវាគ្មានប្រសិទ្ធភាពទៅវិញនៅពេលវីរុសនេះនៅក្នុងឡាំផូស៊ីត T ។ កាលណាវីរុស HIV នៅក្នុងកោសិកា T វាបន្តពូជយ៉ាងសកម្ម ហើយបំផ្លាញកោសិកា T យ៉ាងច្រើន ។ យើងដឹងហើយថាឡាំផូស៊ីត T មាននាទីយ៉ាងសំខាន់ក្នុងកិច្ចការពារសារពាង្គកាយ ។ ដរាបណាឡាំផូស៊ីត T មានចំនួនមិនគ្រប់គ្រាន់ ប្រព័ន្ធស៊ាំរបស់សារពាង្គកាយ មិនអាចការពារទប់ទល់ទៅនឹងការបង្កជំងឺបានទេ ។ នៅពេលចំនួនឡាំផូស៊ីតកាន់តែខ្សត់ទៅៗ កិច្ចការពារមិនមានប្រសិទ្ធភាពឡើយ ដូចនេះគេនឹងមានជំងឺអេដស៍ ។ ឆ្លៀតពេលកិច្ចការពាររបស់សារពាង្គកាយចុះខ្សោយ ភ្នាក់ងារបង្កជំងឺជាច្រើន មានបាក់តេរី វីរុស ... តាំងលំនៅក្នុងសារពាង្គកាយអ្នកជំងឺ នេះជាជំងឺឱកាសនិយម ដូចជាជំងឺរលាកសួត ជំងឺរបេង ... ។ ជំងឺមហារីកច្រើនកើតជាញឹកញាប់ចំពោះអ្នកជំងឺអេដស៍ ។ ដូចនេះអ្នកជំងឺអេដស៍ក៏ច្រើនតែស្លាប់ដោយសារតែជំងឺឱកាសនិយមនេះផងដែរ ។

# 5. វិធីថែរក្សាសុខភាពឱ្យបានល្អ

យើងអាចមានទម្លាប់ឬឥរិយាបថមួយចំនួនដែលបង្ការខ្លួនយើងពីជំងឺឆ្លងជាច្រើន ។ ឥរិយាបថជាច្រើនអាចជួយយើងឱ្យឆាប់ជាសះស្បើយពីជំងឺ ប្រសិនបើយើងឈឺ ។ ឥរិយាបថទាំងនោះមាន ការបរិភោគអាហារដែលមានសារធាតុចិញ្ចឹមគ្រប់គ្រាន់និងទៀងទាត់ ការហាត់ប្រាណ ការសម្រាកនិងដេកឱ្យបានគ្រប់គ្រាន់ ។



រូបទី 27 : ដេក

## 5.1. អាហារមានសារធាតុចិញ្ចឹមគ្រប់គ្រាន់

កោសិកានៃសារពាង្គកាយ ត្រូវការសារធាតុចិញ្ចឹមដើម្បីលូតលាស់ ជួសជុលជាលិកាខូចខាត និងចាស់រេចរិល ព្រមទាំងបំពេញនាទីផ្សេងៗទៀត ។ ការបរិភោគគ្រាប់ធញ្ញជាតិផ្ដល់នូវថាមពល ជាតិសរសៃ(សែលុយឡូស) និងសារធាតុខនិជ ។ ផ្លែឈើនិងបន្លែផ្ដល់ឱ្យយើងនូវវីតាមីននិងសារធាតុខនិជ សម្រាប់ជួយសារពាង្គកាយប្រឆាំងទៅនិងជំងឺផ្សេងៗ ។ សាច់គ្មានខ្លាញ់ សាច់មាន់និងត្រីផ្ដល់នូវប្រូតេអ៊ីនសម្រាប់ការលូតលាស់និងជួសជុលកោសិកា ។ ផលិតផលទឹកដោះគោផ្ដល់នូវវីតាមីន កាល់ស្យូម(Ca)និងសារធាតុខនិជផ្សេងៗទៀត ។ ដើម្បីរក្សាសុខភាពឱ្យបានល្អប្រសើរ យើងត្រូវប្រើប្រាស់ខ្លាញ់ ស្ករ និងអំបិលក្នុងបរិមាណតិចតួចនៅក្នុងរបបអាហារ ។

## 5.2. ការហាត់ប្រាណ

អ្នកជំនាញផ្នែកបេះដូង បានខូន្មានថាយុវវ័យត្រូវការហាត់ប្រាណ យ៉ាងតិចក៏ 30នាទីដែរជារៀងរាល់ថ្ងៃ ។ ការធ្វើលំហាត់ប្រាណជួយឱ្យយើងមានទម្ងន់សមស្របនិងធ្វើឱ្យបេះដូង សួត ឆ្អឹង និងសាច់ដុំរឹងមាំ ។

## 5.3. សម្រាកនិងដេកឱ្យបានគ្រប់គ្រាន់

សម្រាកជាដំណាក់កាលមួយនៃ ការបន្ធូរអារម្មណ៍ ។ ដេកជាការបន្ធូរអារម្មណ៍មួយយ៉ាងយូរ ។ នៅពេលដេក យើងមិនបានដឹងថាមានអ្វីកើតឡើងនៅជុំវិញខ្លួនយើងទេ ។ យុវវ័យត្រូវការដេករៀងរាល់យប់ប្រហែលពី 9-10ម៉ោង ។ ការដេកលក់ផ្ដល់ឱកាសឱ្យសរីរាង្គទាំងឡាយសម្រាកនិងជួសជុលដោយខ្លួនឯង ។

## ៥.៤. ឥរិយាបថនាំឱ្យមានសុខភាពល្អ

ការអនុវត្តនូវទម្លាប់ដែលផ្តល់សុខភាពល្អ ដើម្បីចៀសវាងភ្នាក់ងារបង្កជំងឺ និងកាត់បន្ថយគ្រោះថ្នាក់នៃជំងឺ ។ ទម្លាប់មួយចំនួនមានដូចខាងក្រោមនេះ :

- លាងសំអាតដៃឱ្យបានញឹកញាប់
- មិនត្រូវប្រើកន្សែងសម្រាប់ជូតមុខ ជូតខ្លួន និងក្រាសរួមគ្នាទេ
- មិនត្រូវប្រើ កែវ កំប៉ុង ដប បំពង់បឺត ស្លាបព្រា ចាន និងប្រដាប់ប្រដាហូបចុកផ្សេងៗទៀតរួមគ្នាទេ ។
- កុំប៉ះពាល់ឬបរិភោគសាច់មិនឆ្អិនល្អ ឬសាច់ឆៅ
- ខ្ទប់ច្រមុះ ឬមាត់ដោយក្រដាសអនាម័យ នៅពេលក្អក ឬកណ្តាស់ បន្ទាប់មកបោះវាចោលក្នុងធុងសំរាម ហើយលាងដៃនិងសាប៊ូ
- ត្រូវមានការប្រុងប្រយ័ត្នជានិច្ច នៅពេលយើងនៅក្បែរធាតុរាវរបស់សារពាង្គកាយ(ឈាម ទឹករងៃ ស្លេស្ម ...) ។

### មេរៀនសង្ខេប

- សមត្ថភាពរបស់សារពាង្គកាយធន់ទៅនឹងជំងឺពិសេសណាមួយ ហៅថាភាពស៊ាំ ។ ភាពស៊ាំមានពីរប្រភេទ គឺភាពស៊ាំអកម្មនិងភាពស៊ាំសកម្ម ។ ភាពស៊ាំអកម្មគឺសារពាង្គកាយទទួលបានអង់ទីករពីឈាមរបស់មនុស្សម្នាក់ផ្សេងទៀត ឬពីរបស់សត្វណាមួយ ។ ភាពស៊ាំសកម្មគឺជាភាពស៊ាំដែលសារពាង្គកាយផលិតអង់ទីករផ្ទាល់របស់ខ្លួន ដើម្បីប្រឆាំងទល់និងអង់ទីសែនរបស់មេរោគ ។
- វ៉ាក់សាំងជាសារធាតុដែលបង្កើតភាពស៊ាំរបស់សារពាង្គកាយ ។ តាមធម្មតាវ៉ាក់សាំងមានផ្ទុកអង់ទីសែនងាប់ឬខ្សោយ ដែលភ្ញោចគោលិកាសឱ្យផលិតអង់ទីករប្រឆាំងនឹងវា ។ តាមធម្មតាអង់ទីករត្រូវបានផលិតជាលើកទីមួយ តែមួយដងប៉ុណ្ណោះ ។ បន្ទាប់មកវាអាចបង្កើតយ៉ាងរហ័សនិងគ្រប់ពេលដែលអង់ទីសែននៃភ្នាក់ងារបង្កជំងឺនោះ ជ្រៀតចូលក្នុងសារពាង្គកាយម្តងទៀត ។
- វីរុស HIV បំផ្លាញប្រព័ន្ធស៊ាំរបស់សារពាង្គកាយ ។ ដូចនេះនៅពេលភ្នាក់ងារបង្កជំងឺផ្សេងៗជ្រៀតចូលក្នុងសារពាង្គកាយ ប្រព័ន្ធស៊ាំគ្មានសមត្ថភាពប្រឆាំងទេ ហើយសារពាង្គកាយធ្លាក់ខ្លួនឈឺដោយសារមេរោគឱកាសនិយម ។

## ? សំណួរ

1 តើប្រព័ន្ធស៊ាំបង្កឡើងពីអ្វីខ្លះ ?

2. តើភាពស៊ាំគឺជាអ្វី ?

3 តើភាពស៊ាំអកម្មនិងភាពស៊ាំសកម្មខុសគ្នាដូចម្ដេច ?

## ? សំណួរបញ្ចប់ជំពូកទី៣

I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវ

1 វ៉ាក់សាំងផ្ដល់ឱ្យនូវ

☐ ក. ភាពស៊ាំសកម្ម ☐ ខ. ផាកូស៊ីត

☐ គ. ភាពស៊ាំអកម្ម ☐ ឃ. ឡាំផូស៊ីត

2. ភ្នាក់ងារបង្កជំងឺបណ្ដាលឱ្យប្រព័ន្ធស៊ាំផលិត

☐ ក. អង់ទីសែន ☐ ខ. អង់ទីករ

☐ គ. ប្លាកែត ☐ ឃ. ប្លាស្មា

3 របាំងការពារទី ៣ជា

☐ ក. ស្បែក ☐ ខ. ភ្នាសស្លេស្ម

☐ គ. រោមញ័រ ☐ ឃ. អង់ទីករ

4 សារធាតុដែលបង្កើតភាពស៊ាំរបស់សារពាង្គកាយជា

☐ ក. អង់ទីករ ☐ ខ. អង់ទីប៊្យូទិច

☐ គ. វ៉ាក់សាំង ☐ ឃ. អង់ទីសែន

II. ចូរបំពេញចន្លោះនៃឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ

1 របាំងការពារទីពីរជា ............ ។

2. អង់ទីសែនបណ្ដាលឱ្យសារពាង្គកាយផលិត ............ ។

3. សារធាតុគីមីមួយចំនួនជា ............ ត្រូវបានប្រើប្រាស់ដើម្បីបង្កើតភាពស៊ាំនៃសារពាង្គកាយសម្រាប់ប្រឆាំងនិង ............ ។

4. ភាពស៊ាំដែលកើតឡើងក្រោយកំណើតជា ............ ។

**III. ចូរឆ្លើយនិងសំណួរខាងក្រោម**

1. តើមានអ្វីកើតឡើងនៅពេលមានតំណបរលាក ? ចូរពណ៌នា ។
2. នៅក្នុងសារពាង្គកាយរបស់មនុស្ស តើអង់ទីករកើតឡើងយ៉ាងដូចម្ដេច ?
3. ហេតុអ្វីបានជាអ្នកត្រូវសំអាតនិងរុំកំណាត់នៅពេលមានរបួស ?
4. ហេតុអ្វីបានជាអ្នកមិនត្រូវទៅសាលារៀននៅពេលអ្នកមានជំងឺផ្ដាសាយ ?
5. ឧបមាថារោមញ៉ូវត្រូវបំផ្លាញ ។ តើបញ្ហានេះមានឥទ្ធិពលលើសារពាង្គកាយយ៉ាងដូចម្ដេចដែរ ?
6. ហេតុអ្វីបានជាអ្នកមានជំងឺកញ្រ្ជិលតែម្ដងគត់ក្នុងមួយជីវិត ?
7. ប្រសិនបើអ្នកបរិភោគអាហារដែលមានផ្ទុកមេរោគ តើសារពាង្គកាយអាចមានតំណបដូចម្ដេចដែរ ?
8. រវាងភាពស៊ាំអកម្មសិប្បនិមិត្តនិងភាពស៊ាំសកម្មសិប្បនិមិត្តតើមានលក្ខណៈខុសគ្នាដូចម្ដេចខ្លះ ?
9. ចូរពិពណ៌នាពីលក្ខណៈខុសគ្នារវាងអង់ទីករនិងអង់ទីសែន ។
10. តើវីរុស HIV វាយប្រហារប្រព័ន្ធស៊ាំយ៉ាងដូចម្ដេច ?
11. ការទទួលថ្នាំបង្ការនិងការរង់ចាំរហូតដល់មានភាពស៊ាំ តើមួយណាប្រសើរជាង ?
12. រវាងទារកបៅដោះម្ដាយនិងទារកបៅទឹកដោះគោ តើមានអត្ថប្រយោជន៍ដូចគ្នាឬទេ ? ព្រោះអ្វី ?
13. តើវ៉ាក់សាំងជួយបង្ការជំងឺដូចម្ដេចដែរ ?

# ជំពូកទី 4 ភ្នាក់ងារបង្ករោគនិងជំងឺ



*រូបនេះបង្ហាញពីកោសិកាមហារីកមួយ*

សារពាង្គកាយរបស់យើងច្រើនទទួលការបង្ករោគពីមីក្រូសារពាង្គកាយទាំងឡាយដែលនៅជុំវិញខ្លួន។ ក្រោយពេលដែលមីក្រូសារពាង្គកាយ(ឬមេរោគ) ឆ្លងចូលក្នុងខ្លួនមនុស្សណាម្នាក់ វាបង្កជំងឺដល់មនុស្សនោះ។ មីក្រូសារពាង្គកាយទាំងនោះគេហៅថា ភ្នាក់ងារបង្ករោគ ចំណែកជំងឺហៅថា ជំងឺឆ្លង ប៉ុន្តែនៅមានជំងឺជាច្រើនទៀតដែលមិនបណ្ដាលមកពីមេរោគទាំងនោះទេ។ គេហៅជំងឺទាំងនោះជាជំងឺមិនឆ្លង ដូចនេះ តើភ្នាក់ងារបង្ករោគជាអ្វី ?

មេរៀនទី

# 1 ភ្នាក់ងារបង្ករោគ

**ចប់មេរៀននេះ សិស្សអាច**

- ❑ ពន្យល់ពាក្យភ្នាក់ងារបង្ករោគ ព្រមទាំងឱ្យឧទាហរណ៍
- ❑ បង្ហាញពីរូបផ្ដុំរបស់វីរុស និងបាក់តេរី និងរៀបរាប់ពីប្រូទីសមួយចំនួនដែលបង្កជំងឺ
- ❑ ពន្យល់បានពីរបៀបចម្លង និងវិធីបង្ការជំងឺដែលបង្កដោយភ្នាក់ងារបង្ករោគ ។

សារពាង្គកាយតូចល្អិត ដែលបណ្ដាលឱ្យមានជំងឺហៅថា ភ្នាក់ងារបង្ករោគ ។ ប្រសិនបើវាជ្រៀតចូលក្នុងខ្លួនយើង ហើយបន្តពូជ វានឹងធ្វើឱ្យយើងមានជំងឺ ។ សារពាង្គកាយតូចល្អិតភាគច្រើនបណ្ដាលឱ្យមានជំងឺ ដែលយើងអាចមើលឃើញវាបានតែនៅក្រោមមីក្រូទស្សន៍ប៉ុណ្ណោះ ។ គេហៅវាថា មីក្រូសារពាង្គកាយ ។ វាស្ថិតនៅគ្រប់ទីកន្លែងទាំងអស់ក្នុងធម្មជាតិ មានវីរុសទាំងអស់ បាក់តេរីផ្សិត ប្រូទីសមួយចំនួន ។

## 1. វីរុស

វីរុសជាភាគល្អិតតូចបំផុត ដែលគេមិនអាចមើលឃើញវាដោយភ្នែកទទេ ឬដោយមីក្រូទស្សន៍ធម្មតាបានឡើយ ។ តែគេអាចមើលឃើញវាដោយមីក្រូទស្សន៍អេឡិចត្រូនិច ។ វីរុសមានទំហំ 100ដងតូចជាងបាក់តេរីភាគច្រើន ។ វីរុសប្រភេទនីមួយៗអាចរស់នៅតែជាបរាសិតក្នុងសារពាង្គកាយសត្វ ឬរុក្ខជាតិប៉ុណ្ណោះ ដោយវាបំផ្លាញកោសិការបស់សារពាង្គកាយធ្មលនោះ ។ ក្រៅពីក្នុងសារពាង្គកាយធ្មល វាមិនអាចរស់នៅបានទេ ។ វីរុសទាំងឡាយសុទ្ធតែជាភ្នាក់ងារបង្កជំងឺកាចសាហាវជាច្រើន ។ ប៉ុន្តែសព្វថ្ងៃនេះ គេបានបំរែបំរួលលក្ខណៈចង្រៃរបស់វា ដើម្បីឱ្យវាចុះខ្សោយ ហើយយកវាទៅប្រើប្រាស់ដោយធ្វើជាវ៉ាក់សាំងសម្រាប់បង្ការជំងឺផ្សេងៗ ។ វីរុសមិនមែនជាកោសិកា ព្រោះវាមិនមានធាតុកោសិកាសម្រាប់ចិញ្ចឹមជីវិតនិងការលូតលាស់ ។ វីរុសអាចបន្តពូជបានដោយប្រើប្រាស់កោសិការស់ ដើម្បីបង្កើតវីរុសដ៏ច្រើនថែមទៀតតែប៉ុណ្ណោះ ។ វីរុសប្រភេទខុសៗគ្នា បង្កជំងឺលើកោសិកាប្រភេទខុសៗគ្នា ។ *ឧទាហរណ៍ :* វីរុសដែលបង្កជំងឺនៅលើកោសិកាច្រមុះ មាត់ បំពង់ក អាចឱ្យយើងមានជំងឺផ្ដាសាយ ។ ជំងឺដែលបង្កឡើងដោយវីរុសគ្មានថ្នាំព្យាបាលទេ ប៉ុន្តែគេអាចបង្ការជំងឺនេះបានដោយចាក់វ៉ាក់សាំង ។

## 1.1. រូបផ្គុំ



*រូបទី 1.1 : រូបផ្គុំវីរុស (បាក់តេរីយ៉ូផាស)*

វីរុសតូចជាងកោសិកា។ វាមានរូបរាងនិងទំហំខុសៗគ្នា។ ទោះបីជាវាមានរូបរាងខុសៗគ្នាក្តី ប៉ុន្តែគ្រប់វីរុសទាំងអស់ មានរូបផ្គុំប្រហាក់ប្រហែលគ្នា ហើយងាយបំផុត គឺស្នូលជាសម្ភារៈតំណពូជសម្រាប់បង្កើតវីរុសថ្មីៗ និងសំបកប្រូតេអ៊ីនរុំព័ទ្ធពីក្រៅសម្រាប់ការពារ។



*រូបទី 1.2 : រូបរាងផ្សេងៗរបស់វីរុស*

## 1.2. ការបន្តពូជ



*រូបទី 1.3 : វដ្តតំណពូជរបស់វីរុស (បាក់តេរីយ៉ូផាស)*

គ្រប់វីរុសទាំងអស់មានការបន្តពូជដូចបាក់តេរីយ៉ូផាស ។ កាលណាបាក់តេរីយ៉ូផាសជួបប្រទះបាក់តេរីដែលត្រូវនឹងវា វាភ្ជាប់ខ្លួនទៅនឹងភ្នាសកោសិការបស់បាក់តេរី ដោយបញ្ចេញអង់ស៊ីមរំលាយភ្នាសត្រង់ចំណុចភ្ជាប់(1) នោះ ។ វីរុសក៏បញ្ចូលសម្ភារៈតំណពូជរបស់វា ចូលទៅក្នុងកោសិការបស់បាក់តេរី ឯចំណែកសំបកប្រូតេអ៊ីន ទុកនៅខាងក្រៅ(2) ។ លុះចូលទៅក្នុងកោសិការបស់បាក់តេរីបានហើយ សម្ភារៈតំណពូជនិងប្រូតេអ៊ីនរបស់វីរុស ត្រូវបានសំយោគ(3) ។ បន្ទាប់មកសម្ភារៈតំណពូជនិងប្រូតេអ៊ីនដែលបានសំយោគនោះ ទៅផ្គុំបានជាវីរុសថ្មីៗជាច្រើននៅពេញក្នុងកោសិការបស់បាក់តេរី ។ វីរុសថ្មីៗទាំងនេះមានសម្ភារៈតំណពូជ និងសំបកប្រូតេអ៊ីនដូចៗគ្នា ហើយដូចទៅនឹងវីរុសមេ(4) ។ ពេលកោសិកាបាក់តេរីត្រូវបំផ្លាញអស់ កោសិកានោះក៏ផ្ទុះ ហើយបញ្ចេញវីរុសថ្មីៗជាច្រើនដែលឆ្លងទៅបំផ្លាញកោសិកាបាក់តេរីផ្សេងៗទៀត(5) ។

## 1.3. វីរុសនិងជំងឺ

វីរុសទាំងអស់បង្កជំងឺ ។ វីរុសខ្លះទៀតបង្កជំងឺក្នុងរយៈពេលខ្លី ហើយឆាប់ជាសះស្បើយដូចជាជំងឺគ្រុនផ្តាសាយ ។ វីរុសខ្លះបង្កជំងឺយ៉ាងធ្ងន់ធ្ងរដល់រាងកាយដូចជាជំងឺអេដស៍ ។ តើវីរុសផ្តាសាយបង្កជំងឺយ៉ាងដូចម្តេច ?

នៅពេលមនុស្សម្នាក់មានជំងឺផ្តាសាយ ហើយកណ្តាស់ ឬក្អកលើមនុស្សម្នាក់ទៀត ឬចាប់ដៃ វីរុសអាចឆ្លងពីអ្នកជំងឺទៅមនុស្សជាបានដោយចូលតាមមាត់ឬច្រមុះ ។ វីរុសផ្តាសាយចូលទៅរាគត្បាតកោសិកាបំពង់ក ឬវាធ្វើដំណើរឆ្លងកាត់ផ្លូវដង្ហើម ។ វីរុសដែលបានទៅដល់កោសិកាណាមួយ វានឹងចូលទៅក្នុងកោសិកានោះ ហើយចាប់ផ្តើមបន្តពូជ កើតជាវីរុសថ្មីៗជាច្រើន ។

វីរុសច្រើនប្រភេទ ដែលបំផ្លាញកោសិកានៃផ្នែកផ្សេងៗរបស់ខ្លួនមនុស្សគឺបង្កជំងឺផ្សេងៗដែរ ។

*ឧទាហរណ៍ :*

- វីរុសគ្រុនស្វិតដៃជើង បានបំផ្លាញខួរឆ្អឹងខ្នងនិងប្រព័ន្ធប្រសាទខួរក្បាល ។ វាបន្តពូជដោយបំផ្លាញកោសិកាប្រសាទដែលធ្វើឱ្យសាច់ដុំពុំអាចទទួលបញ្ជាពីខួរក្បាលបាន ។ ដូចនេះសាច់ដុំនោះមិនអាចកម្រើកបាន ហើយមិនអាចធ្វើចលនាបាន ។
- វីរុសសលាទែនបំផ្លាញក្រពេញទឹកមាត់ ដែលបង្កឱ្យគ្រុន ។
- វីរុសអាចបង្កជំងឺដល់រុក្ខជាតិ និងសត្វចិញ្ចឹម មានឆ្កែនិងឆ្មា ។ ឆ្កែនិងឆ្មាអាចងាប់ដោយសារជំងឺដែលបណ្តាលមកពីវីរុសដូចជា ជំងឺឆ្កែឆ្កួត ។ ដើមប៉េងប៉ោះរាគត្បាតដោយវីរុស ម៉ូសាអ៊ិច ដែលធ្វើឱ្យមានផ្លែតិច ។ល ។

ជំងឺបណ្ដាលមកពីវីរុស

| ជំងឺ | ភ្នាក់ងារបង្ករោគ | របៀបចម្លង |
|---|---|---|
| គ្រុនផ្ដាសាយធំ | វីរុសច្រើនប្រភេទ | ចរន្តខ្យល់និងការប៉ះពាល់ផ្ទាល់ជាមួយអ្នកជំងឺ |
| សណ្ដែង | វីរុសមួយប្រភេទ | រាលដាលនិងប៉ះពាល់ផ្ទាល់ជាមួយអ្នកជំងឺ |
| គ្រុនស្វិតដៃជើង | វីរុសគ្រុនស្វិតដៃជើង ប្រភេទ 1-2 និង 3 | ប៉ះពាល់ផ្ទាល់ជាមួយអ្នកជំងឺ |
| រលាកសួត | ប្រភេទវីរុសមួយចំនួន | ចរន្តទឹកមាត់អ្នកជំងឺ |
| អុតស្វាយ | វីរុសមួយប្រភេទ | ចរន្តខ្យល់និងការប៉ះពាល់ផ្ទាល់ជាមួយអ្នកជំងឺ |
| កញ្ជ្រឹល | វីរុសមួយប្រភេទ | ចរន្តខ្យល់និងការប៉ះពាល់ផ្ទាល់ជាមួយអ្នកជំងឺ |
| អេដស៍ | វីរុសមួយប្រភេទ | ការរួមភេទ ការប្រើម្ជុលរួមគ្នា ឆ្លងពីម្ដាយទៅកូន |

## 2. បាក់តេរី

បាក់តេរីមាននៅគ្រប់ទីកន្លែង ក្នុងខ្យល់ដែលអ្នកដកដង្ហើម ក្នុងអាហារដែលអ្នកបរិភោគ ក្នុងទឹកដែលអ្នកផឹក។ ក្នុងដីមួយប៉ែលមានផ្ទុកបាក់តេរីរាប់ពាន់លាន។ បាក់តេរីពីរាប់រយទៅរាប់ពាន់រស់នៅលើនិងក្នុងសារពាង្គកាយរបស់អ្នក។ បាក់តេរីភាគច្រើនមានប្រយោជន៍ចំពោះមនុស្ស។ ប៉ុន្តែក៏មានបាក់តេរីជាច្រើនដែលជាភ្នាក់ងារបង្កជំងឺចំពោះមនុស្ស សត្វ និងរុក្ខជាតិដែរ។

### 2.1. រូបផ្គុំ

បាក់តេរីមានទំហំតូចពី 0.001mm ដល់ 0.005mm ។ ផ្អែកតាមរូបរាងបាក់តេរី គេចែកបាក់តេរីជាបីប្រភេទ គឺបាក់តេរីមានរាងស្វ៊ែរហៅថាកុកស៊ី រាងដំបងហៅថាបាស៊ី និងរាងស្ពៀហៅថាស្ពៀរីឡូម។

បាក់តេរីមានស៊ីតូប្លាសដែលព័ទ្ធជុំវិញដោយភ្នាសស៊ីតូប្លាស និងភ្នាសគ្រោង។ សម្ភារៈតំណពូជមានសភាពជាខ្សែនៅចំកណ្ដាលស៊ីតូប្លាស។ បាក់តេរីជាច្រើនរស់នៅដោយសេរីក្នុងបរិស្ថាន ជុំវិញខ្លួនយើង(ខ្យល់ ទឹក ដី) និងក្នុងសារពាង្គកាយមនុស្ស សត្វ និងរុក្ខជាតិ។ បាក់តេរីភាគច្រើនអាចផ្លាស់ទីបាន។ បាក់តេរីខ្លះអាចវារឬលូន ហើយខ្លះទៀតធ្វើចលនាដោយរំកិលខ្លួន។ បាក់តេរីខ្លះប្រើប្រាស់ផ្លាសែលក្នុងការធ្វើចលនា។




ក. រូបផ្គុំបាក់តេរី　*រូបទី ១.៤ : បាក់តេរី*　ខ. រូបរាងផ្សេងៗរបស់បាក់តេរី

## ២.២. បាក់តេរីនិងជំងឺ

### ក. របៀបចម្លង

បាក់តេរីដែលបង្កជំងឺឆ្លងមានរបៀបចម្លងច្រើនបែប ។ ជំងឺកាមរោគ ជាជំងឺដែលបង្កដោយបាក់តេរី ។ វាចម្លងតាមការរួមភេទ ដូចជាជំងឺស្វាយ ជំងឺប្រមេះទឹកបាយ ជំងឺប្រមេះទឹកថ្លា ជំងឺសិរមាន់ ជំងឺសង់មូ... ។ បាក់តេរីខ្លះចម្លងតាមចរន្តខ្យល់ក្រោមទម្រង់ជាតំណក់តូចៗ ដែលកើតពីការក្អក ឬកណ្តាស់ ។ បាក់តេរីខ្លះទៀតចម្លងតាមទឹកឬភេសជ្ជៈផ្សេងៗ ។ បាក់តេរីមួយចំនួនទៀតអាចចម្លងតាមការប៉ះពាល់ផ្ទាល់ ដូចជាការចាប់ដៃ ឬការប្រើប្រាស់សម្ភារៈរួមជាមួយអ្នកជំងឺ ។

### ខ. របៀបបង្ករោគ

បាក់តេរីឱ្យទោស ជាបាក់តេរីដែលបង្កជំងឺឆ្លងដល់មនុស្ស សត្វ និងរុក្ខជាតិ ។ បាក់តេរីទាំងនេះបង្ករោគតាមរបៀបពីរបែបគឺ :

- វាបំផ្លាញកោសិការបស់សរីរាង្គណាមួយនៃសារពាង្គកាយ ។ *ឧទាហរណ៍* ជំងឺរបេងជាជំងឺដែលបង្កឡើងដោយបាក់តេរីបំផ្លាញកោសិកាសួត ។
- វាផលិតជាតិពុល ហៅថា តុកស៊ីន ។ បាក់តេរីផលិតជាតិពុលនៅក្នុងអាហារដែលធ្វើឱ្យអាហារមានជាតិជូរ ហៅថា ផ្អូម ហើយបង្កទុក្ខទោសនៅពេលបរិភោគ ។ *ឧទាហរណ៍* បាក់តេរីមួយប្រភេទឈ្មោះ ក្លូស្ទ្រីឌីយ៉ូមបុយលីនូម ជាបាក់តេរីដែលផលិតជាតិពុល(តុកស៊ីន)យ៉ាងសាហាវដល់ចំណីគ្រប់ប្រភេទ ។ បាក់តេរីនេះអាចលូតលាស់ក្នុងម្ហូបអាហារដែលគេពុំបានកម្តៅឱ្យឆ្អិនល្អនៅពេលគេបញ្ចូលក្នុងកំប៉ុង ។

វិធីពីរយ៉ាងដែលជួយបន្ថយល្បឿនកុំឱ្យអាហារឆាប់ផ្អូមគឺការដាក់អាហារក្នុងទូរទឹកកក ឬក្លាសេទឹកកក និងការកម្តៅម្ហូប ។

ជំងឺមួយចំនួនបណ្ដាលមកពីបាក់តេរី

| ជំងឺ | ទម្រង់ភ្នាក់ងារបង្ករោគ | របៀបឆ្លង |
|---|---|---|
| • ខាន់ស្លាក់ | • រាងដំបង | • ប៉ះពាល់អ្នកជំងឺ ចំណីអាហារ |
| • រលាកបំពង់ក | • រាងស៊្វែតម្រៀបជាច្រវាក់ | • ចរន្តខ្យល់ ប៉ះពាល់អ្នកជំងឺ ចំណីអាហារ |
| • រលាកសួត | • រាងស៊្វែតម្រៀបជាគូៗ | • ចរន្តខ្យល់ ចរន្តទឹកមាត់របស់អ្នកជំងឺ |
| • រលាកស្រោមខួរ | • រាងស៊្វែ | • ប៉ះពាល់ដោយផ្ទាល់ជាមួយអ្នកជំងឺ |
| • តេតាណូស | • រាងដំបង | • មុខរបួស |
| • របេង | • រាងដំបង | • ចរន្តខ្យល់ ចំណីអាហារ |
| • ក្អកមាន់ | • រាងដំបង | • ចរន្តខ្យល់ |

## 2.3. ការបន្តពូជ

នៅពេលបាក់តេរីមានអាហារគ្រប់គ្រាន់ក្នុងសីតុណ្ហភាពត្រឹមត្រូវនិងលក្ខខណ្ឌផ្សេងៗទៀតសមស្រប វាធំធាត់ និងបន្តពូជយ៉ាងរហ័ស ។ ក្នុងលក្ខខណ្ឌអំណោយផល បាក់តេរីខ្លះអាចបន្តពូជរៀងរាល់ 20 នាទីម្ដង ។ បាក់តេរីទាំងអស់បន្តពូជដោយឥតភេទ ។

បាក់តេរីភាគច្រើនបន្តពូជដោយឥតភេទ ឬដោយចែកខ្លួនជាពីរ ។ មុនដំបូងស្បៀយ៉ូចែកខ្លួនជាពីរ ។ បន្ទាប់មក ស៊ីតូប្លាសក៏ចែកខ្លួនជាពីរដែរ ហើយទីបញ្ចប់កើតបានជាកោសិកាថ្មីពីរដែលកោសិកានីមួយៗបានចម្លងសម្ភារៈតំណពូជយ៉ាងត្រឹមត្រូវពីកោសិកាមេ មានន័យថា កោសិកាកូនទាំងពីរមានរូបផ្ដុំដូចគ្នា ហើយដូចទៅនឹងកោសិកាមេ ។

បាក់តេរីខ្លះបន្តពូជដោយភេទដែរ ។ ក្នុងដំណើរនេះ បាក់តេរីពីរបានផ្លាស់ប្ដូរសម្ភារៈតំណពូជគ្នាទៅវិញទៅមក ។ បន្ទាប់មកកោសិកានីមួយៗមានសម្ភារៈតំណពូជថ្មីមួយ ។




រូបទី 1.5 : ការបន្តពូជដោយចែកខ្លួនជាពីររបស់បាក់តេរី

# 3. ប្រូតូសូអ៊ែ (ប្រូទីស)

ប្រូតូសូអ៊ែជាសារពាង្គកាយឯកកោសិកាបរជីព ។ វារស់នៅក្នុងទឹកសាប ទឹកប្រៃ ក្នុងដី ឬក្នុងសារពាង្គកាយផ្សេងៗទៀត ។ ប្រូតូសូអ៊ែមួយចំនួនជាភ្នាក់ងារបង្ករោគដូចជា :

## 3.1. ប្រូតូសូអ៊ែ ផ្លាស់ទីដោយជើងបញ្ឆោត : អាមីប

អាមីបជាសារពាង្គកាយឯកកោសិកាដែលមានរូបរាងមិនកំណត់ ហើយរស់នៅក្នុងកន្លែងមិនស្អាតដូចជា ភក់ ទឹកកខ្វក់ជាដើម ។ អាមីបប្រើជើងបញ្ឆោតសម្រាប់ផ្លាស់ទី និងចាប់យកអាហារ ។ ការបន្តពូជរបស់អាមីបប្រព្រឹត្តទៅដោយឥតភេទគឺដោយការចែកខ្លួនជាពីរ ហើយកើតបានជាអាមីបថ្មីពីរ ។



*រូបទី 1.6 : រូបផ្ដុំរបស់អាមីប*

អាមីបអាចរស់នៅជាបរាសិតក្នុងខ្លួនមនុស្ស ហើយបង្កជារោគរាកមូល ។

អាមីបរស់នៅក្នុងទម្រង់ជាគីស ដែលអាចធន់នឹងសីតុណ្ហភាពខ្ពស់ មជ្ឈដ្ឋានអាស៊ីត បាស... ហើយអាចផ្អាកសកម្មភាពរបស់វាក្នុងរយៈពេលយូរ ។ គីស ត្រូវបានបញ្ចេញមកក្រៅសារពាង្គកាយតាមលាមក ។ មនុស្សឆ្លងជំងឺនេះកាលណាគេបរិភោគអាហារ ឬផឹកទឹកដែលមានគីស ។

## 3.2. ប្រូតូសូអ៊ែផ្លាស់ទីដោយផ្លាសែល : សាឌីយ៉ា GIARDIA

ប្រូតូសូអ៊ែប្រភេទនេះមានផ្លាសែលមួយឬផ្លាសែលច្រើន ។ វាប្រើផ្លាសែលសម្រាប់ធ្វើចលនា ។ ប្រូតូសូអ៊ែខ្លះមានប្រយោជន៍ ខ្លះទៀតចង្រៃ ។

*ឧទាហរណ៍ :* សាឌីយ៉ារស់នៅក្នុងទឹកសាប ដូចជាទឹកជ្រោះ ទន្លេ បឹងបួ ។ នៅពេលបរិភោគទឹកមិនស្អាត វាចូលទៅក្នុងសារពាង្គកាយដោយភ្ជាប់ខ្លួនទៅនឹងពោះវៀន ហើយចិញ្ចឹមជីវិតនិងបន្តពូជនៅទីនោះ ។ សាឌីយ៉ាបង្កឱ្យកើតជំងឺសាឌីយ៉ូស ដែលធ្វើឱ្យការរំលាយអាហារនិងថ្លើមមានដំណើរការមិនល្អ ។



*រូបទី 1.7 : សាឌីយ៉ា*

## 3.3. ប្រូតូសូអ៊ែបន្តពូជតាមរយៈស្ប៉ : ស្ប៉រ៉ូសូអ៊ែ

ស្ប៉រ៉ូសូអ៊ែជាប្រភេទប្លាយនៃប្រូតូសូអ៊ែ ដែលរស់នៅជាបរាសិតលើមនុស្សនិងសត្វ ។ ការបន្តពូជរបស់វាធ្វើឡើងតាមរយៈស្ប៉ ។

*ឧទាហរណ៍* ប្លាស្មូដ្យូមជាស្ប៉ូរ៉ូសូអ៊ែមួយប្រភេទដែលបង្កជំងឺគ្រុនចាញ់ដល់មនុស្ស ។ បរាសិតនេះឆ្លងមកមនុស្សតាមរយៈមូសដែកគោលញី ។ វដ្តជីវិតរបស់ប្លាស្មូដ្យូមពឹងពាក់លើមជ្ឈដ្ឋានពីរគឺ ក្នុងសារពាង្គកាយរបស់មូសដែកគោលញីនិងក្នុងសារពាង្គកាយរបស់មនុស្ស ។

## ក. ក្នុងសារពាង្គកាយមូសដែកគោលញី

មូសដែកគោលញីខាំមនុស្សដែលមានជំងឺគ្រុនចាញ់ គឺវាចុចទំលុះស្បែកដើម្បីបឺតយកឈាមដែលមានកាម៉ែតរបស់ប្លាស្មូដ្យូម ។ ក្នុងបំពង់អាហាររបស់មូស កាម៉ែតរបស់ប្លាស្មូដ្យូមបង្កកំណើតហើយក្លាយជាស៊ុតបង្កកំណើត(ឬស៊ីកូត) ។ ស៊ីកូតក្លាយទៅជាគីស ដែលក្នុងនោះមានស្ប៉ជាច្រើនធ្វើដំណើរទៅកាន់ក្រពេញទឹកមាត់របស់មូសញី ។

## ខ. ក្នុងសារពាង្គកាយមនុស្ស




*រូបទី ១.៤ វដ្តជីវិតរបស់ប្លាស្មូដ្យូម*

នៅពេលមូសដែកគោលញីដែលមានផ្ទុកស្ប៉ររបស់ប្លាស្មូដ្យូម ខាំមនុស្សណាម្នាក់ វាចម្លងស្ប៉ររបស់ប្លាស្មូដ្យូមទៅឱ្យមនុស្សនោះ ។ ស្ប៉រធ្វើដំណើរតាមចរន្តឈាមទៅកាន់ថ្លើមជនរងគ្រោះ។ ក្នុងកោសិកាថ្លើមស្ប៉របន្តពូជដោយធ្វើចំណែកបានស្ប៉រជាច្រើន(1) ។ បន្ទាប់មកស្ប៉រផ្លាស់ទីឆ្លងចូលទៅក្នុងកោសិកាឈាមក្រហមរបស់ជនរងគ្រោះ ហើយបន្តពូជនៅទីនោះ ដែលធ្វើឱ្យគោលិកាក្រហមផ្ទុះបែក (2)ក្នុងចន្លោះពេលពី 48 ទៅ 72 ម៉ោងយ៉ាងទៀតទាត់ (2) ។

នៅពេលកោសិកាក្រហមផ្ទុះបែកវាបញ្ចេញជាតិពុលនិងមេរោគ ដែលនៅពេលនោះធ្វើឱ្យជនរងគ្រោះមានរោគសញ្ញាគ្រុនចាញ់ដូចជា ឡើងកម្តៅគ្រុនរងា។ គោលិកាក្រហមផ្ទុះបញ្ចេញស្ប៉រមកក្រៅ ហើយស្ប៉រមួយចំនួនផ្លាស់ទីចូលទៅបំផ្លាញគោលិកាក្រហមថ្មីៗផ្សេងៗទៀត(3 និង 4) ។ ចំណែកស្ប៉រមួយចំនួនទៀតផ្តើមវដ្តថ្មីក្នុងសារពាង្គកាយមូសដែកគោលញីផ្សេងទៀត(5) នៅពេលបានខាំអ្នកជំងឺគ្រុនចាញ់ ។

ជំងឺគ្រុនចាញ់ជាជំងឺដ៏កាចសាហាវមួយដែលអាចបង្កគ្រោះថ្នាក់ដល់ស្លាប់បាន ។ គេអាចព្យាបាលជំងឺនេះដោយប្រើថ្នាំពេទ្យ ប៉ុន្តែប្រការដែលសំខាន់ជាងគេ គឺត្រូវបំផ្លាញជម្រកមូសដែកគោលនិងគេងក្នុងមុងជានិច្ច ។

## 4. ផ្សិត

ផ្សិតមួយចំនួនបង្កជំងឺដល់មនុស្ស ។ ជំងឺដែលបង្កដោយផ្សិតអាចព្យាបាលជាមួយថ្នាំប្រភេទអង់ទីផ្សិត ។

*ឧទាហរណ៍ :* ជំងឺផ្សិតកើតមាននៅត្រង់ចន្លោះម្រាមជើង ។ វាមានលក្ខណៈសើមបណ្តាលឱ្យរមាស់ និងកន្ទួលក្រហល់ក្រហាយ ។ ជំងឺស្រែងនិងជំងឺផ្សិតផ្សេងទៀតបណ្តាលឱ្យរមាស់និងកន្ទួលនៅលើស្បែក ព្រោះផ្សិតដែលបង្កជំងឺទាំងនេះ ផលិតស្ប៉រចំកន្លែងមានរបួស ឬដំបៅ ។ ជំងឺនេះអាចឆ្លងរាលដាលយ៉ាងរហ័ស ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ។ ជំងឺពោះវៀនដុះផ្សិតឈ្មោះកង់ឌីដា (CAN DIDA ) បណ្តាលឱ្យឈឺរ៉ាំរ៉ៃគ្មានមូលហេតុ ។



*រូបទី 1.9 : ផ្សិតពោះវៀនកង់ឌីដា CANDIDA*

ផ្សិតមួយចំនួនជាបរាសិតដែលបណ្តាលឱ្យមានជំងឺយ៉ាងធ្ងន់ធ្ងរចំពោះរុក្ខជាតិ ។ ជំងឺផ្សិតរុក្ខជាតិមានឥទ្ធិពលទៅលើកសិផលផ្សេងៗទៀតដែរដូចជា ស្រូវ កប្បាស និងសណ្តែកសៀងដែលនាំមកនូវការខូចខាតយ៉ាងសម្បើមជារៀងរាល់ឆ្នាំ ។

## មេរៀនសង្ខេប

- សារពាង្គកាយតូចល្អិតដែលបណ្ដាលឱ្យមានជំងឺហៅថាភ្នាក់ងារបង្ករោគ ។ ភ្នាក់ងារបង្ករោគមាន វីរុសទាំងអស់ បាក់តេរី ប្រូតូស៊ូអ៊ែ(ប្រូទីស)ដូចជា អាមីប សាឌីយ៉ា ប្លាស្មូដ្យូម និងផ្សិតមួយចំនួន ។
- គ្រប់វីរុសទាំងអស់បង្កឡើងដោយផ្នែកពីរសំខាន់គឺ ស្រោមខាងក្រៅ ជាប្រូតេអ៊ីនសម្រាប់ការពារវីរុស និងស្នូលខាងក្នុងជាសម្ភារៈតំណពូជ ។
- ជំងឺផ្សេងៗដែលបង្កដោយវីរុសមាន ជំងឺផ្ដាសាយ កញ្ជ្រិល សលាទែន អេដស៍ជាដើម ។
- បាក់តេរីជាសារពាង្គកាយឯកកោសិកា ហើយគ្មានណ្វៃយ៉ូពិតប្រាកដ ។
- បាក់តេរីចែកជាបីក្រុមគឺ កុកស៊ី បាស៊ី និងស្ពៀរីឡូម ។
- បាក់តេរីខ្លះបន្តពូជដោយឥតភេទ ដោយធ្វើចំណែក និងខ្លះទៀតប្ដូរសម្ភារៈតំណពូជគ្នា ។
- បាក់តេរីភាគច្រើនជាភ្នាក់ងារបង្កជំងឺដល់មនុស្ស សត្វ និងរុក្ខជាតិ ។
- ជំងឺមួយចំនួនដែលបង្កឡើងដោយបាក់តេរីមាន ជំងឺខាន់ស្លាក់ រលាកបំពង់ក រលាកស្រោមខួរ តេតាណូស របេង ក្អកមាន់ជាដើម ។
- ប្រូទីសមួយចំនួនជាភ្នាក់ងារបង្កជំងឺដល់មនុស្ស ដូចជា អាមីបបង្កជំងឺរាកមូល សាឌីយ៉ាបណ្ដាលឱ្យដំណើររំលាយអាហារប្រព្រឹត្តទៅមិនល្អ ប្លាស្មូដ្យូមបង្កជំងឺគ្រុនចាញ់ ។
- ផ្សិតមួយចំនួនជាភ្នាក់ងារបង្ករោគដែរ ដូចជា ជំងឺផ្សិតកើតឡើងនៅត្រង់ចន្លោះម្រាមជើង ជំងឺស្រែង ជំងឺពោះវៀនមានដុះផ្សិត ។

## ? សំណួរ

1. ចូរពន្យល់ពាក្យភ្នាក់ងារបង្ករោគព្រមទាំងរកឧទាហរណ៍ ។
2. តើវីរុសគឺជាអ្វី ?
3. តើផ្នែកសំខាន់ពីររបស់វីរុសគឺជាអ្វី ?
4. ចូររកឧទាហរណ៍ពីជំងឺមួយចំនួនដែលបង្កដោយវីរុស ។
5. តើបាក់តេរីជាអ្វី ?
6. តើបាក់តេរីចែកជាប៉ុន្មានប្រភេទ ? អ្វីខ្លះ ?
7. ចូររកឧទាហរណ៍ពីជំងឺមួយចំនួនដែលបង្កឡើងដោយបាក់តេរី ។
8. ចូររកឧទាហរណ៍ពីប្រូទីសដែលបង្កជំងឺដល់មនុស្ស ។
9. តើផ្សិតបង្កជំងឺអ្វីខ្លះដល់មនុស្ស ?

# 2 ជំងឺឆ្លង

ចប់មេរៀននេះ សិស្សអាច

- ពន្យល់ពាក្យជំងឺឆ្លងនិងមូលហេតុនៃការឆ្លងជំងឺ
- បង្ហាញពីជំងឺកាមរោគ ជំងឺអេដស៍ របៀបឆ្លងនិងរបៀបមិនឆ្លងនៃជំងឺទាំងនោះ
- ពណ៌នាពីការការពារខ្លួនកុំឱ្យភ្នាក់ងារបង្ករោគជ្រៀតចូលក្នុងខ្លួនបានដោយអនុវត្តក្បួនអនាម័យក្នុងការបរិភោគនិងការរស់នៅ
- អប់រំចិត្តខ្លួនឯង និងអ្នកដទៃកុំនាប់ពាក់ព័ន្ធជាមួយសកម្មភាពផ្លូវភេទ
- ពន្យល់ពីផលវិបាកនៃជំងឺឆ្លងនិងកាមរោគ ជាពិសេសជំងឺអេដស៍ហើយចៀសវាងការប្រព្រឹត្តិអំពើណាមួយដែលបណ្តាលឱ្យឆ្លងជំងឺ ។

តើអ្នកធ្លាប់ផឹកភេសជ្ជៈជាមួយមិត្តអ្នកដែរឬទេ ? តើអ្នកនិងមិត្តអ្នកប្រើកែវរួមគ្នាក្នុងការផឹកភេសជ្ជៈឬដូចម្តេច ? ការប្រើប្រាស់កែវ ឬចានរួមគ្នាជាវិធីមួយដែលមេរោគជាច្រើនត្រូវបានឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ។

## 1. ជំងឺឆ្លង

ជំងឺដែលឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតហៅថា **ជំងឺឆ្លង** ។ ជំងឺឆ្លងបណ្តាលមកពីភ្នាក់ងារបង្ករោគ ដូចជាវីរុស បាក់តេរី ផ្សិត និងប្រូទីស ។

**ជំងឺមួយចំនួនដែលបណ្តាលមកពីភ្នាក់ងារបង្ករោគ**

| ភ្នាក់ងារបង្ករោគ | វីរុស | បាក់តេរី | ប្រូទីស | ផ្សិត |
|---|---|---|---|---|
| ប្រភេទជំងឺ | ផ្តាសាយធំ | តេតាណូស | គ្រុនចាញ់ | ទិកស៊ីជើង |
| | អេដស៍ | របេង | ជំងឺងងុយដេក | ស្រែង |
| | កញ្ជ្រិល | គ្រុនពោះវៀន | រាកមួល | ជ្រាំងមាត់ |

| | | | | |
|---|---|---|---|---|
| | សណាទែន | | រលាកបំពង់ក | ជំងឺពោះវៀនធ្ងន់ធ្ងរ |
| | ស្វិតដៃជើង | | អំបៅអំបែក | |
| | អុតស្វាយ | | ការពុលអាហារ | |
| | រលាកថ្លើម | | ប៉េស្ត | |
| | ផ្ដាសាយបក្សី | | | |
| | ផ្ដាសាយថ្មី | | | |

## 1.1. រោគសញ្ញានៃជំងឺឆ្លងមួយចំនួន

ជំងឺឆ្លងមួយចំនួនដែលប្រទះឃើញញឹកញាប់ជាងគេមាន

| ជំងឺ | របៀបឆ្លង | រោគសញ្ញា |
|---|---|---|
| កញ្ជ្រិល | ចរន្តខ្យល់ | ក្រហមលើស្បែក ឡើងកម្ដៅ គិង ច្រមុះ និងឈឺបំពង់ក |
| អុតស្វាយ | ចរន្តខ្យល់ | ស្នាមកន្ទួលលើស្បែក |
| រលាកថ្លើម | ឆ្លងតាមឈាម ចំណីអាហារ ទឹក ការរួមភេទ | គ្រុនរងា ក្អួតចង្អោរ ហើមថ្លើម ស្បែកលឿង និងឈឺសន្លាក់ |
| គ្រុនស្វិតដៃជើង | ចំណីអាហារនិងទឹក | ឈឺក្បាល គិងកញ្ចឹងក និងសាច់ដុំ កម្រើកលែងរួច |
| ផ្ដាសាយបក្សី | -ការប៉ះពាល់ ឬបរិភោគបក្សីឈឺ ឬងាប់<br>-ទៅកន្លែងដែលមានបក្សីឈឺ ឬងាប់<br>-មុជទឹកត្រពាំងឬស្រះដែលមានបក្សីហែលលេង | ឈឺក្បាល ឈឺសាច់ដុំ ថប់ដង្ហើម ក្ដៅលើសពី 38°C (ក្រោយពីការប៉ះពាល់បក្សីឈឺ ឬងាប់ រយៈពេល 7 ថ្ងៃ) |

## 1.2. វិធីការពារកុំឱ្យឆ្លងជំងឺ

វិធីខាងក្រោមនេះជួយយើងកុំឱ្យឆ្លងមេរោគបាន :

- ត្រូវដុះសំអាតធ្មេញជាមួយច្រាស់និងថ្នាំដុសធ្មេញ រាល់ពេលយប់មុនចូលដំណេក ពេលព្រឹកក្រោយពីដំណេក និងក្រោយពេលបរិភោគអាហាររួច ។
- ត្រូវលាងសំអាតដៃជាមួយទឹកស្អាតនិងសាប៊ូ ឬផេះមុនពេលចូលដំណេក និងក្រោយពីប៉ះពាល់វត្ថុមិនស្អាត ។ ក្រោយពេលលាងសំអាត ត្រូវជូតជើងឱ្យស្អាតដោយកំណាត់ស្ងួតជាពិសេសចន្លោះម្រាមនីមួយៗ ។
- ត្រូវបោកសម្លៀកបំពាក់ និងសម្ភារៈដំណេកជាមួយសាប៊ូ រួចហាលឱ្យត្រូវពន្លឺថ្ងៃខ្លាំង ហើយអ៊ុតឱ្យស្ងួតជាទៀងទាត់ និងត្រូវផ្លាស់សម្លៀកបំពាក់ឱ្យបានញឹកញាប់ ។
- ត្រូវងូតទឹកច្រើនដង ជាពិសេសពេលអាកាសធាតុក្តៅ ។ ការងូតទឹកច្រើនដងជួយឱ្យស្បែកយើងចាកផុតពីជំងឺសើស្បែក ប៉ុន្តែមិនត្រូវងូតទឹករយៈពេលយូរទេ ដើម្បីចៀសវាងការត្រាំស្បែកដែលអាចឱ្យមេរោគជ្រៀតចូលដោយសារស្បែករីក ។
- ត្រូវលាងសំអាតមុខឱ្យស្អាតជានិច្ច ជាពិសេសនៅពេលយប់ជាមួយសាប៊ូដែលមានគុណភាពល្អត្រូវនឹងស្បែកមុខរបស់យើង ។
- ត្រូវទុកដាក់អាហារនៅនិងឆ្អិនដាច់ដោយឡែកពីគ្នា ព្រោះក្នុងអាហារនៅមានមេរោគដែលបង្កគ្រោះថ្នាក់ ហើយឆ្លងចូលក្នុងអាហារឆ្អិនបាន ។ អាហារត្រូវចំអិនឱ្យបានឆ្អិនល្អ ដែលអាចសម្លាប់មេរោគបានទាំងអស់ ។ ម្យ៉ាងទៀតអាហារត្រូវបរិភោគភ្លាមៗកុំទុកយូរពេក ព្រោះការទុកដាក់អាហារឆ្អិនស្រាប់នៅសីតុណ្ហភាពធម្មតា លើសពី 2 ម៉ោង មេរោគអាចបន្តពូជបានយ៉ាងឆាប់រហ័ស ។ ដូចនេះបើចង់ទុកបានយូរ ត្រូវរក្សាអាហារក្នុងទូរទឹកកក ទូរកម្តៅ ឬកន្លែងស្អាត ។
- ទឹកសម្រាប់បរិភោគត្រូវដាំឱ្យពុះល្អ និងរក្សាទឹកទុកប្រើក្នុងពាងដែលបានលាងសំអាត និងគ្របឱ្យបានជិតល្អ ។



*រូបទី 2.1 : រក្សាទឹកទុកប្រើក្នុងពាងដែលបានលាងសំអាតនិងគ្របឱ្យបានជិតល្អ*



*រូបទី 2.2 : បរិភោគទឹកដាំពុះជានិច្ច*

### 1.3. ឥរិយាបថនៃការឆ្លងជំងឺ

ឥរិយាបថដែលអាចបណ្ដាលឱ្យឆ្លងជំងឺមាន :

- ជំងឺមួយចំនួនដូចជាជំងឺអុតស្វាយនិងកញ្ជ្រិលជាជំងឺអាចឆ្លងពីមនុស្សម្នាក់ទៅម្នាក់ទៀតបានតាមការប៉ះពាល់អ្នកជំងឺដោយផ្ទាល់ ។ ដូចនេះបើយើងប៉ះពាល់អ្នកជំងឺ ឬប្រើប្រាស់វត្ថុរួមជាមួយអ្នកជំងឺ មានកន្សែងជូតខ្លួន ក្រាសសិតសក់ កែវទឹក សម្លៀកបំពាក់ នោះយើងនឹងអាចឆ្លងមេរោគពីអ្នកជំងឺបាន ។
- ជំងឺផ្ដាសាយ ហើមសួត របេង សុទ្ធតែឆ្លងតាមរយៈខ្យល់ដង្ហើម ។ ការដកដង្ហើមនៅក្បែរអ្នកជំងឺ អាចនាំយកមេរោគពីអ្នកជំងឺ ពិសេសនៅពេលដែលគេក្អក ឬកណ្ដាស់ ។ ដូចនេះនៅពេលក្អកឬកណ្ដាស់ អ្នកជំងឺគួរតែយកកន្សែងដៃទៅខ្ទប់មាត់ ឬច្រមុះកុំខាន ។
- ការបរិភោគអាហារព្រមទាំងភេសជ្ជៈមានផ្ទុកមេរោគនៅពេលមនុស្សក្អកឬកណ្ដាស់លើវា កាន់វាដោយដៃកខ្វក់ មានរុយឬមេរោគ ឬសត្វដទៃទៀតស៊ី ឬក៏វារកាត់អាចកើតជំងឺបាន ជាពិសេសអាហារផ្អូមដែលបណ្ដាលឱ្យកើតជំងឺរាគមួល ។

## 2. ជំងឺកាមរោគ

ជំងឺកាមរោគជាជំងឺមួយបែបដែលភាគច្រើនឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត តាមរយៈការរួមភេទជាមួយដៃគូមានជំងឺកាមរោគ ដោយមិនបានប្រើប្រាស់មធ្យោបាយបង្ការ ។

### 2.1. ព័ត៌មានទូទៅស្ដីពីជំងឺកាមរោគ

- ជំងឺកាមរោគ គឺជាជំងឺដែលឆ្លងតាមការរួមភេទ ហើយកើតមានតាមផ្លូវភេទ ។ ជំងឺកាមរោគមិនមែនជាជំងឺតពូជទេ ។
- ជំងឺកាមរោគ មិនមែនសុទ្ធតែជាជំងឺដែលឆ្លងតាមការរួមភេទនោះទេ មានជំងឺខ្លះអាចកើតមានតាមផ្លូវភេទ ដែលបណ្ដាលមកពីមេរោគមានស្រាប់នៅក្នុងប្រដាប់ភេទតែម្ដង ហើយខ្លះទៀតឆ្លងតាមការប៉ះពាល់និងឈាម ។
- ជំងឺកាមរោគបណ្ដាលមកពីមេរោគច្រើនប្រភេទ អាចជាពួកបាក់តេរី វីរុស បរាសិត និងពពួកផ្សិត ។
- ជំងឺកាមរោគមិនមែនជាជំងឺធ្ងន់ធ្ងរទេ ប៉ុន្តែបើមិនព្យាបាលទេនោះ ឬព្យាបាលមិនបានត្រឹមត្រូវវានឹងបង្កឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ហើយអាចបណ្ដាលឱ្យស្លាប់បាន ។

• អ្នកជំងឺកាមរោគមិនមែនសុទ្ធសឹងតែជាមនុស្សរួមភេទច្រើនពេកនោះទេ ព្រោះជំងឺកាមរោគមួយចំនួនអាចកើតឡើងដោយសារមូលហេតុផ្សេងៗទៀតក្រៅពីការរួមភេទ ។
• ជំងឺកាមរោគភាគច្រើនមិនបង្កឱ្យមានជារោគសញ្ញាទេ អាស្រ័យហេតុនេះហើយទើបយើងពិបាកនឹងដឹងថា តើនរណាម្នាក់មាន ឬគ្មានជំងឺកាមរោគឬអត់ ។

## 2.2. ប្រភេទផ្សេងៗនៃជំងឺកាមរោគ

ជំងឺកាមរោគដែលប្រទះឃើញញឹកញាប់ជាងគេមាន ជំងឺប្រមេះទឹកបាយ ប្រមេះទឹកថ្លា ជំងឺសិរមាន់ ជំងឺស្វាយ ជំងឺសង់ម្វ ជំងឺទាមឡា ។

### ក. ជំងឺប្រមេះទឹកបាយ



ប្រដាប់បន្តពូជបុរស ប្រដាប់បន្តពូជនារី

*រូបទី 2.3 : ជំងឺប្រមេះទឹកបាយ*

ជំងឺប្រមេះទឹកបាយបណ្ដាលមកពីបាក់តេរីមួយប្រភេទឈ្មោះ នេសេរីយ៉ា ហ្គោណូរេ Neisseria Gonorrhoeae ។ ជំងឺនេះឆ្លងតាមរយៈការរួមភេទជាមួយដៃគូដែលមានផ្ទុកមេរោគនេះ ឬម្ដាយដែលមានជំងឺនេះចម្លងទៅឱ្យកូនក្នុងផ្ទៃ ។

ចំពោះមនុស្សប្រុស ជំងឺនេះធ្វើឱ្យពិបាកនោម នោមឈឺ មានចេញខ្ទុះពណ៌ស ឬបែតងភាវពីបង្ហូរនោម ។ បើអ្នកជំងឺបណ្ដោយខ្លួនដោយពុំទៅទទួលការព្យាបាលទេនោះ ជំងឺនេះអាចបណ្ដាលឱ្យរលាកក្រពេញប្រូស្តាត រលាកពងស្វាស ដែលជាមូលហេតុបណ្ដាលឱ្យអារ(គ្មានកូន) ។ ចំពោះមនុស្សស្រីជំងឺនេះធ្វើឱ្យពិបាកនោម នោមឈឺ ឈឺតាមបង្ហូរនោម ប្រដាប់បន្តពូជ និងឈឺរន្ធគូថ ។ បើទុកយូរទៅអាចបណ្ដាលឱ្យរលាកប្រដាប់បន្តពូជ ហើយធ្វើឱ្យស្ត្រីនោះមិនអាចមានកូនបានឡើយ(អារ) ។ ចំណែកទារកវិញពេលកើតចេញពីផ្ទៃម្ដាយដែលមានជំងឺនេះ ខ្ទុះអាចហូរចូលភ្នែកទារកដែលធ្វើឱ្យមានការរលាកភ្នែក ។ ប្រសិនបើគ្មានការព្យាបាលទេនោះ ទារកអាចនឹងខ្វាក់ភ្នែកបាន ។ ម្យ៉ាងទៀតជំងឺប្រមេះទឹកបាយ បណ្ដាលឱ្យកើតជំងឺផ្សេងៗទៀតដូចជាជំងឺបេះដូង ជំងឺរលាកសន្លាក់ ឬជំងឺងងឹតភ្នែក ។

### ខ. ជំងឺប្រមេះទឹកថ្លា



ប្រដាប់បន្តពូជបុរស ប្រដាប់បន្តពូជនារី

*រូបទី 2.4 : ជំងឺប្រមេះទឹកថ្លា*

ជំងឺប្រមេះទឹកថ្លាបណ្ដាលមកពីបាក់តេរី ក្លាមីឌីយ៉ាត្រាកូម៉ាទីស (Chlamydia Trachomatis) ។ ជំងឺនេះឆ្លងតាមការរួមភេទជាមួយដៃគូដែលមានផ្ទុកមេរោគនេះ ។ ចំពោះមនុស្សប្រុសជំងឺនេះធ្វើឱ្យឈឺ

ចាប់ឬក្រហាយពេលនោម នោមញឹក មានចេញទឹករាវថ្លាពីបង្ហួរនោម ជួនកាលក៏អាចមានហូរខ្ទុះចេញដែរ ពេលខ្លះជំងឺនេះមិនចេញជារោគសញ្ញាអ្វីតូចឱ្យកត់សម្គាល់ឡើយ ។ ចំណែកមនុស្សស្រីវិញភាគច្រើនគ្មានរោគសញ្ញាអ្វីទាំងអស់នៅពេលដំបូង ប៉ុន្តែបើទុកយូរ ជំងឺនេះអាចបណ្តាលឱ្យរលាកដល់ប្រដាប់បន្តពូជ ហើយនិងធ្វើឱ្យស្ត្រីអារ ។

## គ. ជំងឺសិរមាន់



ប្រដាប់បន្តពូជបុរស ប្រដាប់បន្តពូជនារី

*រូបទី 2.5 : ជំងឺសិរមាន់*

ជំងឺសិរមាន់ ជាជំងឺមួយដែលបង្កឡើងដោយវីរុស ឈ្មោះ យូមេន ប៉ាពីឡូម៉ា HUMAN PAPILLOMA ។ ជំងឺនេះឆ្លងតាមរយៈការរួមភេទជាមួយដៃគូដែលមានផ្ទុកមេរោគ ។ ចំពោះអ្នកកើតជំងឺនេះ គេកត់សម្គាល់ឃើញមានដុះសាច់ពកដែលមានទំហំប្រែប្រួល ពីតូចប៉ុនចុងចូប រហូតដល់ប៉ុនម្រាមដៃ ។ សាច់នេះមានរាងប្លែកៗខ្លះមូល ខ្លះមានរាងដូចផ្កាស្ពៃ ហើយផ្ទៃខាងលើមានរាងគគ្រាត ពកជាបន្លា ។ ជំងឺសិរមាន់អាចកើតនៅគ្រប់ទីកន្លែងទាំងអស់ នៃប្រដាប់បន្តពូជរបស់បុរស ឬប្រដាប់បន្តពូជរបស់ស្ត្រី កន្លែងដែលស្ថិតជិតប្រដាប់បន្តពូជ ដូចជាស្បែកម្ដុំក្រលៀន និងជុំវិញរន្ធគូថជាដើម ។ បើទុកយូរទៅ ដុំពកនោះអាចរីករាលដាលកាន់តែធំឡើងៗ ។ ក្រៅពីនេះជំងឺសិរមាន់អាចបង្កឱ្យមានជំងឺមហារីក ជាពិសេសជំងឺមហារីកប្រដាប់បន្តពូជ ។ ដូចនេះការសំខាន់គឺត្រូវព្យាបាលជំងឺនេះ ដើម្បីកុំឱ្យចម្លងទៅមនុស្សដទៃ តាមរយៈការរួមភេទនិងចម្លងទៅទារកទើបកើតចេញពីផ្ទៃម្តាយដែលមានជំងឺនេះ ។

## ឃ. ជំងឺស្វាយ



ប្រដាប់បន្តពូជបុរស ប្រដាប់បន្តពូជនារី

*រូបទី 2.6 : ជំងឺស្វាយ*

ជំងឺស្វាយបណ្តាលមកពីបាក់តេរី ត្រេប៉ូណេម៉ា ប៉ាលីដូម (TREPONEMA PALLIDUM) ឆ្លងតាមរយៈការរួមភេទជាមួយដៃគូដែលមានផ្ទុកមេរោគនេះ និងតាមរយៈម្តាយមានជំងឺឆ្លង ហើយចម្លងទៅឱ្យកូន ។ ដំណាក់កាលដំបូង គេសង្កេតឃើញអ្នកជំងឺមានដំបៅនៅលើប្រដាប់បន្តពូជ និងនៅកន្លែងដទៃទៀតដូចជាដំបៅរលួយលើម្រាមដៃម្រាមជើងឬកន្ទួលក្រហមលើដងខ្លួន និងអវយវៈទាំងមូល ។ ដំបៅនេះមិនបង្កឱ្យមានការឈឺចាប់ទេ ហើយអាចជាសះស្បើយដោយឯកឯង ។

បើគ្មានការព្យាបាលទេនោះ មេរោគស្វាយនិងបន្តរាលដាលហើយធ្វើឱ្យខូចសរីរាង្គសំខាន់ៗរបស់សារពាង្គកាយ ដូចជាបេះដូង សរសៃឈាម ខួរក្បាល ហើយអាចបណ្តាលឱ្យស្លាប់ទៀតផង ។ ចំណែកទារកដែលឆ្លងមេរោគនេះពីម្តាយអាចស្លាប់ តែជួនកាលបើមានទារកខ្លះកើតមក ទារកនោះនឹងឆែបមាត់ ក្រហាតច្រមុះ ថ្លង់ ខ្វាក់ភ្នែកក៏មាន ហើយក្នុងករណីខ្លះទៀតទារកមានឆ្អឹងខ្នងមិនធម្មតា ឬក៏ដុះធ្មេញខុសធម្មតា ។ នៅដំណាក់កាលចុងក្រោយ ជំងឺនេះអាចបណ្តាលឱ្យសន្លាក់មានទ្រង់ទ្រាយខុសធម្មតា សាច់ដុំស្វិតមិនអាចកម្រើកបាន ឬនាំឱ្យឆ្កួតវង្វេង ។

ង. ជំងឺសង់មូ

ជំងឺសង់មូបណ្តាលមកពីបាក់តេរីឈ្មោះអេម៉ូភីលុស ឌុយក្រេ (HAEMOPHILUS DUCREY) ហើយឆ្លងតាមរយៈការរួមភេទជាមួយដៃគូដែលមានផ្ទុកមេរោគនេះ ។

បីទៅប្រាំថ្ងៃក្រោយមេរោគជ្រៀតចូល គេប្រទះឃើញអ្នកកើតជំងឺមានពងតូច ជួនមានទឹកថ្លា ជួនមានខ្ទុះនៅខាងក្នុងលេចចេញត្រង់ចំណុចដែលមេរោគជ្រៀតចូល ដូចជាប្រដាប់ភេទ។ ពងទឹកតូចៗទាំងនោះបែកក្នុងរយៈពេលខ្លី ហើយបង្កើតជាដំបៅ។ ដំបៅនោះមានសភាពទន់ តែឈឺខ្លាំងណាស់និងអាចចេញឈាមយ៉ាងងាយ ។ ដំបៅនេះអាចជាដោយឯកឯង ប៉ុន្តែបន្ទាប់មកលេចកូនកណ្តុរនៅត្រង់ក្រលៀន ហើម ហើយដរជាអាប់សែ ។ នៅពេលអាប់សែបែក វានឹងរីកកាន់តែធំឡើងៗ ។

## 2.3. ការព្យាបាលជំងឺកាមរោគ

ជំងឺកាមរោគភាគច្រើនទាមទារការព្យាបាលធម្មតា ប្រសិនបើយើងបានទទួលការព្យាបាលតាំងពីដំបូង ហើយអាចជាបានយ៉ាងរហ័សដោយគ្មានបន្សល់នូវបញ្ហាធំដុំឡើយ ។ ប៉ុន្តែអ្នកជំងឺមិនបានទទួលការព្យាបាលទាល់តែសោះ វាអាចនឹងមានផលវិបាកធ្ងន់ធ្ងរដូចជាបណ្តាលឱ្យមានកូនក្រៅស្បូន គ្មានកូន បង្ករនោមរួមតូច កូនស្លាប់ក្នុងពោះ ឬកើតមិនធម្មតា(ចំពោះម្តាយកំពុងកើតជំងឺស្វាយ) កូនកើតមកខ្វាក់ភ្នែកពីកំណើត(នៅពេលម្តាយមានជំងឺប្រមេះទឹកបាយ) ។

ធ្ងន់ធ្ងរជាងនេះទៅទៀត ការរលាកឬដំបៅនៅប្រដាប់បន្តពូជ ដែលបណ្តាលមកពីជំងឺកាមរោគជួយដល់ការជ្រៀតចូលនៃមេរោគអេដស៍។ ប្រសិនបើឆ្លងមេរោគអេដស៍ហើយ គ្មានថ្នាំព្យាបាលឱ្យជាសះស្បើយឡើយ គឺមានតែសេចក្តីស្លាប់។ ដោយឡែក យើងអាចចម្លងមេរោគនេះទៅអ្នកដទៃដោយមិនដឹងខ្លួន ព្រោះនៅពេលឆ្លងមេរោគអេដស៍ចូលទៅក្នុងខ្លួន ពុំមានរោគសញ្ញាអ្វីទាំងអស់ ។

ដូចនេះយើងមិនត្រូវបណ្តែតបណ្តោយឱ្យជំងឺដែលអាចព្យាបាលជា ប្រែក្លាយទៅជាជំងឺដែលមិនអាចព្យាបាលជានោះទេ ។

ដើម្បីចៀសវាងនូវគ្រោះថ្នាក់ទាំងនេះ :

- ត្រូវរួសរាន់រកការព្យាបាលពីគ្រូពេទ្យឯកទេសដែលធ្វើរោគវិនិច្ឆ័យនិងព្យាបាលឱ្យបានត្រឹមត្រូវបំផុត ។
- ត្រូវគោរពតាមការណែនាំស្ដីអំពីការព្យាបាលរបស់គ្រូពេទ្យ ។
- ត្រូវនាំដៃគូរួមភេទមកទទួលការព្យាបាលជាមួយ ។
- ត្រូវប្រើស្រោមអនាម័យនៅរាល់ពេលរួមភេទជាមួយដៃគូ ដែលមិនមែនជាដៃគូប្រចាំជីវិត ។
- មិនត្រូវស្វែងរកការព្យាបាលដោយខ្លួនឯង តាមរយៈការលេបថ្នាំ ឬចាក់ថ្នាំដោយគ្មានវេជ្ជបញ្ជាទេនិងការស្វែងរកការព្យាបាលពីគ្រូឱសថបុរាណ ព្រោះថាការព្យាបាលទាំងនោះពុំអាចឱ្យជាសះស្បើយទេ ។
- មិនត្រូវបន្តការរួមភេទនៅមុនពេលជំងឺជាសះស្បើយ ។

## 3. ជំងឺអេដស៍ AIDS

រហូតមកដល់បច្ចុប្បន្ននេះ គ្មានប្រទេសណាមួយដែលចៀសផុតពីការឆ្លងរាលដាលនៃមេរោគអេដស៍ឡើយ គ្រាន់តែកម្រិតនៃការរាលដាលមានទំហំខុសគ្នាប៉ុណ្ណោះ ។ ប្រទេសដែលរងគ្រោះថ្នាក់ដោយការរាលដាលខ្លាំងជាងគេគឺ ប្រទេសក្រីក្រ ។ ដូចនេះដើម្បីចូលរួមទប់ស្កាត់នូវការរាលដាលនៃមេរោគអេដស៍ យើងត្រូវមានចំណេះដឹងមូលដ្ឋានពីមេរោគអេដស៍និងជំងឺអេដស៍ ។

### 3.1. និយមន័យនៃជំងឺអេដស៍

AIDS ជាអក្សរកាត់នៃភាសាអង់គ្លេស

A : Acquired កើតក្រោយពីការឆ្លង

I : Immune ភាពស៊ាំ

D : Deficiency ចុះខ្សោយ

S : Syndrome ចង្កោមរោគសញ្ញា

SIDA ជាអក្សរកាត់នៃភាសាបារាំង: Syndrome d'Immuno déficience Acquise

ជំងឺអេដស៍ AIDS (Acquised Immune Deficiency Syndrome) មានឥទ្ធិពលទៅលើប្រព័ន្ធស៊ាំ ។ ដូចនេះជំងឺអេដស៍មានន័យថា ប្រជុំរោគសញ្ញាដែលកើតឡើងក្រោយពេលប្រព័ន្ធស៊ាំចុះខ្សោយ ។

មូលហេតុបង្កឱ្យមានជំងឺអេដស៍ គឺជាវីរុស HIV (Human Immuno deficiency virus ) ។ HIV ជាវីរុសដែលធ្វើឱ្យប្រព័ន្ធស៊ាំចុះខ្សោយ ។

## ៣.២. ការវិវត្តរបស់ជំងឺអេដស៍

តើមានអ្វីកើតឡើងក្រោយពីមេរោគអេដស៍ចូលក្នុងខ្លួន ? មានដំណាក់កាលបីសំខាន់ មុននិងវិវត្តទៅដល់ជំងឺអេដស៍ ។ ដំណាក់កាលទាំងនោះគឺ

- **ដំណាក់កាលចំហ** : គឺការឆ្លងដំបូង ។ អ្នកផ្ទុកមេរោគអេដស៍មួយចំនួនតូចមានរោគសញ្ញាបន្តិចបន្តួចដូចជាផ្តាសាយមិនគួរឱ្យចាប់អារម្មណ៍ ហើយអ្នកផ្ទុកមេរោគអេដស៍មួយចំនួនធំមានសុខភាពល្អជាធម្មតា ពុំមានរោគសញ្ញាអ្វីទាំងអស់ ។ នៅពេលឆ្លងមេរោគអេដស៍ភ្លាម បើអ្នកនោះធ្វើតេសឈាមគឺមិនអាចមើលឃើញទេ ដោយសារតែអ្នកនោះត្រូវស្ថិតនៅក្នុងដំណាក់កាលចំហ ។ នៅដំណាក់កាលចំហប្រព័ន្ធស៊ាំរបស់សារពាង្គកាយត្រូវការពេលមួយដែលមានរយៈពេលពី 3-6 ខែដើម្បីផលិតអង់ទីករប្រឆាំងនឹងមេរោគអេដស៍ ។
- **ដំណាក់កាលតេស្តឈាមវិជ្ជមាន** : ក្នុងដំណាក់កាលនេះ អ្នកផ្ទុកមេរោគអេដស៍ភាគច្រើនមានសុខភាពល្អ ។ គេពិនិត្យឃើញអ្នកផ្ទុកមេរោគអេដស៍មួយចំនួនតូចមានចេញកូនកណ្តុរនៅគៀក នៅក ។ ពេលនោះការធ្វើតេស្តឈាមផ្តល់លទ្ធផលវិជ្ជមាន ។
- **ដំណាក់កាលជំងឺអេដស៍** : ភាគច្រើននៃអ្នកផ្ទុកមេរោគអេដស៍នឹងវិវត្តទៅរកជំងឺអេដស៍ក្នុងរយៈពេល 10 ឆ្នាំ តែទោះបីជាយ៉ាងណាក៏ដោយ រយៈពេលអតិបរិមារបស់វានៅតែមិនច្បាស់ ហើយប្រែប្រួលទៅតាមបុគ្គលម្នាក់ៗ ។ ក្នុងរយៈពេលនេះ អ្នកជំងឺទទួលការវាតត្បាតពីមេរោគឱកាសនិយមដូចជា របេង រាក មហារីក ជំងឺសើស្បែក ហើយវិវត្តទៅរកសេចក្តីស្លាប់ក្នុងរយៈពេលពីរឬបីឆ្នាំបន្ទាប់ ។

**ការវិវត្តរបស់មេរោគអេដស៍**



## ៣.៣. បណ្ដុំរោគសញ្ញាទាក់ទងនឹងដំណាក់កាលអេដស៍

មួយភាគបីនៃអ្នកផ្ទុកមេរោគអេដស៍និងវិវត្តទៅរកជំងឺអេដស៍ ក្រោយពីបានផ្ទុកមេរោគអេដស៍អស់រយៈពេលប្រហែល 7ឆ្នាំ ។ ជំងឺអេដស៍លេចឡើងនៅពេលដែលប្រព័ន្ធស៊ាំត្រូវបានខូចខាតធ្ងន់ធ្ងរ ។ ជំងឺអេដស៍ស្ដែងឡើងដោយចង្កោមរោគសញ្ញាដែលទាក់ទងនិងជំងឺឱកាសនិយម ជំងឺមហារីក និងចង្កោមរោគសញ្ញាផ្សេងៗទៀត(សរសៃប្រសាទនិងស្រកទម្ងន់) ។

### ក. ជំងឺឱកាសនិយម

- និយមន័យ : នៅជុំវិញខ្លួនយើងមានវីរុស បាក់តេរី និងបរាសិត ដែលជាទូទៅវាមិនបង្កឱ្យមានជំងឺទេដោយសារប្រព័ន្ធស៊ាំនៃសារពាង្គកាយរបស់យើងរឹងមាំ ។ នៅពេលដែលប្រព័ន្ធស៊ាំនៃសារពាង្គកាយចុះខ្សោយ មេរោគឆ្លៀតឱកាសចូលទៅក្នុងខ្លួន ដើម្បីបង្កជំងឺដែលគេឱ្យឈ្មោះថាជាជំងឺឱកាសនិយម ។ ជំងឺឆ្លងទាំងនេះធ្ងន់ធ្ងរណាស់ ដោយសារសារពាង្គកាយមិនអាចបង្ការខ្លួនឯងបាន ទោះបីជាគ្មានថ្នាំព្យាបាល ឬជួនកាលមានការព្យាបាលក៏ដោយ ។
- រោគសញ្ញា : ប្រែប្រួលទៅតាមមេរោគនិងសរីរាង្គដែលប៉ះពាល់ ។ សរីរាង្គដែលងាយប៉ះពាល់ជាងគេគឺ ក្រពះ ពោះវៀនមានជំងឺរាក៉រ៉ៃគ្មានមូលហេតុមានរយៈពេលច្រើនជាងមួយខែ ពិបាកក្នុងការបរិភោគ ដោយសាររលាកក្រពះ ជំងឺពោះវៀនធ្ងន់ធ្ងរ និងរាករ៉ាំរ៉ៃ ។ ខួរក្បាលមានជំងឺរលាកស្រោមខួរ រោគសញ្ញាសរសៃប្រសាទ ស្រវាំងភ្នែក ខ្វិន ស្បែកមានជំងឺ ដំបៅលើស្បែក ។ ស្ថានភាពទូទៅ អ្នកជំងឺស្រកទម្ងន់ អស់កម្លាំងល្ហិតល្ហៃ ដោយអមជាមួយជំងឺផ្សេងៗ ។

### ខ. ជំងឺមហារីកមួយចំនួន

- ជំងឺមហារីកសរសៃឈាម : ជាជំងឺមហារីកដែលជួបញឹកញាប់បំផុតរហូតដល់ 35% នៃអ្នកកើតជំងឺអេដស៍ ។ ជំងឺនេះគឺជាដុំពកៗ ឬក៏ជាបន្ទះមានពណ៌ខៀវ ឬពណ៌ត្នោតនៅលើស្បែក ។ គេបានរកឃើញដុំពកទាំងនេះមិនត្រឹមតែនៅលើស្បែកទេ តែមាននៅលើកូនកណ្ដុរ សួត និងសរីរាង្គទាំងអស់ក្នុងសារពាង្គកាយ ។
- ឡាំផូម៉ា (Lymphomas) : ឡាំផូម៉ាជាដុំពកនៅតាមកូនកណ្ដុរ ។ គ្រោះថ្នាក់នៃឡាំផូម៉ានេះមានប្រហែល 100ដងនៅលើអ្នកជំងឺអេដស៍ជាងនៅលើមនុស្សធម្មតា ។
- ជំងឺផ្សេងៗទៀត : មេរោគហ៊ីវអាចប៉ះពាល់ដោយផ្ទាល់លើប្រព័ន្ធសរសៃប្រសាទកណ្ដាល បណ្ដាលឱ្យកើតជំងឺខូចខួរក្បាល ។ បណ្ដុំរោគសញ្ញាដែលបណ្ដាលឱ្យស្រកទម្ងន់ ត្រូវបានគេហៅថា ជំងឺដែលធ្វើឱ្យស្រកទម្ងន់ ។

## ៣.៤. សភាពអ្នកជំងឺអេដស៍

អ្នកជំងឺខស្សាហ៍ឈឺ គឺម្ដងឈឺនេះ ម្ដងឈឺនោះ ហើយក្នុងចន្លោះពេលឈឺនោះ អ្នកជំងឺអាចជាស្រួលខ្លួនធម្មតាឬជួនកាលក៏មិនសូវស្រួលខ្លួនដែរ ។ ដូចនេះតើអ្នកជំងឺអេដស៍មានសភាពដូចម្ដេច ?

- ការខស្សាហ៍កើតជំងឺឱកាសនិយម ច្រើនតែបាត់ទៅវិញ ដោយសារការប្រើថ្នាំព្យាបាល ។ ជាថ្មីម្ដងទៀត អ្នកជំងឺហាក់ដូចជាមានសុខភាពល្អឡើងវិញ ។ ទោះបីជាយ៉ាងណាក៏ដោយប្រព័ន្ធស៊ាំនៃសារពាង្គកាយបានចុះខ្សោយទៅហើយ ជំងឺឱកាសនិយមធ្ងន់ធ្ងរផ្សេងៗទៀតអាចកើតមានឡើងជាយថាហេតុ ហើយមិនអាចជាដោយសារការព្យាបាលឡើយ ។
- ករណីជំងឺមហារីក ដោយសារការព្យាបាលខ្លះឃើញហាក់ដូចជាបានធូរស្បើយ ក៏ប៉ុន្តែវាគ្រាន់តែអាចជាក្នុងរយៈពេលខ្លីប៉ុណ្ណោះ ។
- អ្នកជំងឺអេដស៍ភាគច្រើន កើតមានបញ្ហាធ្ងន់ធ្ងរតាមកម្រិតផ្សេងៗគ្នានៅលើប្រព័ន្ធប្រសាទក្នុងពេលដែលធ្លាក់ខ្លួនឈឺ ។ រោគសញ្ញាកើតមានប្លែកៗពីគ្នាដោយបូករួមបញ្ចូលទាំងការបាត់បង់ការចងចាំ ការមិនស៊ីសង្វាក់គ្នានៃចលនា ការនិយាយមិនច្បាស់ ការថយចុះនៃគំហើញ និងអាកប្បកិរិយាប្លែកៗមិនធម្មតា ។

## ៣.៥. របៀបឆ្លងនិងរបៀបមិនឆ្លងនៃមេរោគអេដស៍

### ក. របៀបឆ្លង



អេដស៍ឆ្លងតាមការរួមភេទ

មេរោគអេដស៍អាចឆ្លងតាមរបៀបបីសំខាន់ៗគឺ

- **តាមរយៈការរួមភេទ** : រាល់ការរួមភេទទាំងអស់ជាមួយអ្នកផ្ទុកមេរោគអេដស៍ អាចឆ្លងមេរោគទៅឱ្យដៃគូ ព្រោះក្នុងពេលរួមភេទ វីរុសអេដស៍អាចឆ្លងតាមរយៈទឹកកាមបុរសទៅស្ត្រី ឬក៏អាចឆ្លងតាមរយៈទឹករំអិលនៃប្រដាប់បន្តពូជស្ត្រីទៅបុរសវិញ ។
- **តាមការប៉ះពាល់ឈាម** : ជំងឺអេដស៍អាចឆ្លងតាមរយៈសារធាតុរាវក្នុងសារពាង្គកាយ ជាពិសេសឈាម ទឹករងៃ ។ យើងអាចឆ្លងជំងឺអេដស៍បាន ប្រសិនបើឈាមរបស់អ្នកជំងឺអេដស៍ចូលក្នុងខ្លួនរបស់យើង ។
- **ប្រើម្ជុលឬសឺរ៉ាំងរួមគ្នា** : តាមរយៈការសាក់ស្បែក ចោះត្រចៀក (ការប្រើប្រាស់ប្រដាប់ចាក់ខម្លុះស្បែក) ការប្រើប្រាស់ច្រាសដុសធ្មេញជាមួយអ្នកជំងឺ និងតាមរយៈការមុតឬរបួសស្បែកផ្សេងៗទៀត ។ ការបញ្ចូលឈាមអ្នកជំងឺអេដស៍ក្នុងខ្លួនយើង ។



រូបទី 2.7 : សាក់ស្បែក



រូបទី 2.8 : ប្រើម្ជុលសឺរ៉ាំងរួមគ្នា



រូបទី 2.9 : ការបញ្ចូលឈាម

- ពីម្តាយទៅទារក : ជាការចម្លងពីមាតាដែលមានផ្ទុកមេរោគអេដស៍ទៅឱ្យទារករបស់ខ្លួន ហើយការចម្លងនេះអាចធ្វើឡើងតាំងពីទារកនៅក្នុងផ្ទៃ នៅពេលកើត(ពេលប្រសូត្រ)និងនៅពេលបំបៅកូនដោយទឹកដោះ ។



រូបទី 2.10 : ទារកនៅក្នុងផ្ទៃ



រូបទី 2.11 : នៅពេលកើត



រូបទី 2.12 : នៅពេលបំបៅដោះកូន

## ខ. របៀបមិនឆ្លង



កណ្តាស់



ចាប់កាន់ដៃគ្នា



លេងជាមួយគ្នា



សិក្សាក្នុងថ្នាក់ជាមួយគ្នា



បរិភោគជាមួយគ្នា



មូសខាំ



ប្រើបង្គន់រួមគ្នា



សួរសុខទុក្ខអ្នកជំងឺ

រូបទី 2.13 : សកម្មភាពខាងលើនេះមិនអាចឱ្យអ្នកឆ្លងមេរោគអេដស៍ទេ

មេរោគអេដស៍មិនអាចឆ្លងតាមរយៈខ្យល់ អាហារ ឬទឹកទេ ។ មេរោគនេះមិនអាចរស់នៅក្រៅខ្លួនបានយូរឡើយ ។ សារធាតុរាវដែលមានកំហាប់មេរោគខ្ពស់នោះមាន ឈាម ទឹកកាមបុរស ទឹករំអិលនៃប្រដាប់បន្តពូជនារី ទឹករងៃ ។ ជារួម រាល់ទំនាក់ទំនងនិងការប្រាស្រ័យទាក់ទងជាសាធារណៈនៅក្នុង ការរៀនសូត្រ បំពេញការងារ នៅតាមគ្រួសារ និងសង្គមទាំងអស់ដូចជា ក្អក កណ្តាស់ ចាប់ដៃ លេងជាមួយគ្នា បរិភោគបាយរួមគ្នា ប្រើបង្គន់រួមគ្នា ការថែទាំអ្នកជំងឺអេដស៍ គឺមិននាំឱ្យមានការចម្លងមេរោគអេដស៍ទេ ។ មូសនិងសត្វដែលចិញ្ចឹមក្នុងផ្ទះ គឺមិនអាចចម្លងមេរោគអេដស៍បានឡើយ ។

## ១.៦. ការបង្ការមេរោគអេដស៍និងកាមរោគ

យើងអាចការពារខ្លួនយើង ពីការឆ្លងមេរោគអេដស៍ និងកាមរោគ ដោយគ្រាន់តែជ្រើសរើសផ្លូវដែលមានសុវត្ថិភាពខ្ពស់ក្នុងការប្រព្រឹត្តិរបស់យើង ។ មានតែមធ្យោបាយទាំងនេះទេ ដែលអាចកាត់បន្ថយគ្រោះថ្នាក់នៃការឆ្លង ។ មធ្យោបាយសំខាន់ៗមាន :

- យុវវ័យកុំឆាប់ប្រឡូកក្នុងការរួមភេទ
- ស្មោះត្រង់មួយទល់នឹងមួយ
- ប្រើស្រោមអនាម័យឱ្យបានត្រឹមត្រូវគ្រប់ពេលរួមភេទជាមួយដៃគូក្រៅ
- ចៀសវាងប្រើម្ជុល ឬសឺរ៉ាំងនិងសម្ភារៈខម្លុះស្បែកផ្សេងទៀតរួមគ្នា ។

## ១.៧. ផលប៉ះពាល់នៃជំងឺអេដស៍

ជំងឺអេដស៍បានផ្តល់នូវផលប៉ះពាល់ជាប្រព័ន្ធទៅលើបុគ្គល គ្រួសារ និងសង្គមជាតិទាំងមូលយ៉ាងធ្ងន់ធ្ងរដូចជា

- អេដស៍នាំមកនូវជំងឺរ៉ាំរ៉ៃ ដែលទាមទារថវិកាព្យាបាលយ៉ាងច្រើន ។
- អេដស៍នាំមកនូវការស្លាប់ប្តី ប្រពន្ធ ហើយការបន្សល់ទុកនូវក្មេងកំព្រាដែលជាបន្ទុកយ៉ាងធ្ងន់ធ្ងរដល់សង្គម ។
- អេដស៍បំផ្លាញទ្រព្យសម្បត្តិ គ្រួសារហិនហោច និងជំពាក់បំណុលគេថែមទៀតផង ។
- អ្នកឆ្លងជំងឺអេដស៍នឹងត្រូវទទួលការរើសអើងពីសហគមន៍ និងខ្វះការគាំទ្រផ្លូវចិត្ត ។
- អេដស៍គ្មានថ្នាំព្យាបាលឱ្យជាសះស្បើយបានទេ គឺមានតែសេចក្តីស្លាប់ប៉ុណ្ណោះ ។

## មេរៀនសង្ខេប

- ជំងឺដែលឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតតាមរយៈភ្នាក់ងារបង្ករោគគេហៅថា ជំងឺឆ្លង ។
- ជំងឺឆ្លងមិនអាចកើតបាន នៅពេលយើងអនុវត្តអនាម័យទាំងបីយ៉ាង " ហូបស្អាត ផឹកស្អាត និងរស់នៅស្អាត" ឱ្យបានត្រឹមត្រូវ ។
- ជំងឺកាមរោគជាជំងឺដែលឆ្លងតាមរយៈការរួមភេទជាមួយដៃគូដែលមានផ្ទុកមេរោគ ។
- ជំងឺកាមរោគមានជំងឺប្រមេះទឹកបាយ ប្រមេះទឹកថ្លា ជំងឺសិរមាន់ ជំងឺស្វាយ ជំងឺសង្គ្រូ ។
- ជំងឺអេដស៍ឆ្លងតាមការរួមភេទជាមួយដៃគូដែលមានផ្ទុកមេរោគ ឆ្លងពីម្ដាយទៅទារកនៅក្នុងផ្ទៃ និងការប៉ះពាល់ឈាមរបស់អ្នកជំងឺ ។

## សំណួរ

1. ចូរពន្យល់ពាក្យជំងឺឆ្លង និងរកឧទាហរណ៍ពីជំងឺឆ្លងដែលធ្លាប់ជួបប្រទះ ។
2. ហេតុអ្វីបានជាយើងត្រូវយកកន្សែងដៃខ្ទប់ច្រមុះ មាត់នៅពេលដែលយើងក្អក ឬកណ្ដាស់ ?
3. ដូចម្ដេចហៅថាជំងឺកាមរោគ ? ចូរឱ្យឧទាហរណ៍ ។
4. តើជំងឺកាមរោគអាចឱ្យមនុស្សស្លាប់ដែរឬទេ ?
5. តើជំងឺអេដស៍បង្កឡើងដោយសារមេរោគឈ្មោះអ្វី ? មេរោគនេះស្ថិតនៅកន្លែងណាខ្លះក្នុងសារពាង្គកាយរបស់មនុស្ស ?
6. ចូររៀបរាប់ពីរបៀបឆ្លង និងរបៀបមិនឆ្លងនៃជំងឺអេដស៍ ។
7. តើសកម្មភាពបង្ការណាមួយដែលមានប្រសិទ្ធិភាពបំផុតសម្រាប់យុវវ័យ ដើម្បីកុំឱ្យឆ្លងមេរោគអេដស៍និងកាមរោគ ?
8. តើការប្រើស្រោមអនាម័យពិតជាអាចបង្ការ ការឆ្លងមេរោគអេដស៍បាន 100% ដែរឬទេ ?

# 3 ជំងឺមិនឆ្លង

**ចប់មេរៀននេះ សិស្សអាច**

- ពន្យល់ពាក្យជំងឺមិនឆ្លងនិងរាប់ឈ្មោះជំងឺមិនឆ្លងមួយចំនួន
- ពន្យល់បានពីមូលហេតុនៃការកើតជំងឺមិនឆ្លង
- ពណ៌នាពីរបៀបការពារ និងការកាត់បន្ថយជំងឺមិនឆ្លង
- ពន្យល់ពីផលវិបាកនៃជំងឺមិនឆ្លង ហើយចៀសវាងការប្រព្រឹត្តិណាមួយដែលបណ្ដាលឱ្យកើតជំងឺមិនឆ្លង ។

ជំងឺខ្លះមិនបង្កឡើងដោយមេរោគទេ ជំងឺទាំងនោះហៅថាជំងឺមិនឆ្លង ។ ជំងឺនេះមិនឆ្លងទៅមនុស្សដទៃតាមរយៈការប៉ះពាល់ ឬការរួមភេទទេ ។

ជំងឺមិនឆ្លងមានជំងឺទល់លាមក ជំងឺរលាកក្រពះ ជំងឺកង្វះអាហារ ជំងឺធាត់ ជំងឺទឹកនោមផ្អែម ជំងឺបេះដូង ជំងឺសរសៃឈាម ជំងឺមហារីក ... ។

## 1. ជំងឺទល់លាមក

ជំងឺទល់លាមកជាជំងឺដែលលាមកក្លាយទៅជាស្ងួតរឹង ហើយពោះវៀនពិបាកធ្វើចលនា ឬមិនអាចបញ្ចេញលាមកមកក្រៅសរពាង្គកាយបាន ។ រោគទល់លាមក បណ្ដាលមកពីកង្វះជាតិសរសៃឬយខ្ជះក្នុងអាហារ ការបរិភោគមិនទៀងទាត់ ការផឹកទឹកតិចពេក កង្វះលំហាត់ប្រាណ ... ។

វិធីដែលល្អដើម្បីបង្ការរោគទល់លាមក គឺត្រូវបរិភោគអាហារឱ្យមានតុល្យភាព ការផឹកទឹកច្រើន និងការធ្វើលំហាត់ប្រាណឱ្យបានទៀងទាត់ ។

## 2. ជំងឺកង្វះអាហារ

ជំងឺកង្វះអាហារជាផលនៃការបរិភោគអាហារខ្វះសារធាតុចិញ្ចឹមពិសេសមួយប្រភេទ ដូចជាកង្វះប្រូតេអ៊ីន កង្វះវីតាមីន បេ(B) សេ(C) និងដេ(D) ឬជាតិដែកក្នុងអាហារ ដូចជាជំងឺស្លេក ។

ដើម្បីចៀសវាងជំងឺកង្វះអាហារ យើងត្រូវបរិភោគអាហារឱ្យមានតុល្យភាព មានន័យថាការបរិភោគអាហារដែលមានសារធាតុចិញ្ចឹមគ្រប់គ្រាន់ មិនច្រើនហួស ឬមិនតិចហួស ។

## 3. ជំងឺធាត់

ជំងឺធាត់បណ្ដាលមកពីការបរិភោគច្រើនហួសក្នុងរយៈពេលយូរ ។ អ្នកធាត់ហួសបានទទួលថាមពលពីអាហារច្រើនជាងថាមពលដែលគេបញ្ចេញ ។ ខ្លាញ់ក៏បានស្តុកទុកជាច្រើន ហើយមនុស្សក៏កើនទម្ងន់យ៉ាងខ្លាំង ។ ភាពធាត់ហួសអាចបណ្ដាលឱ្យមានជំងឺផ្សេងៗដូចជាជំងឺបេះដូង ជំងឺទឹកនោមផ្អែម ជំងឺលើសឈាមជាដើម ។

ដូចនេះមនុស្សដែលធាត់ហួសគួរជ្រើសរើសរបបអាហារសម្រាប់បរិភោគ ព្រោះការជ្រើសរើសរបបអាហារ មានសារប្រយោជន៍ក្នុងការរក្សាលំនឹងសារធាតុចិញ្ចឹមទៅតាមតម្រូវការរបស់សារពាង្គកាយ ។

## 4. ជំងឺលើសឈាម

ជំងឺនេះបណ្ដាលមកពីខ្លាញ់នៅក្នុងស្រទាប់សរសៃឈាមអាកទែ លូតលាស់ខ្លាំង ។ ស្រទាប់ខ្លាញ់នេះ ធ្វើឱ្យភាពយឺតរបស់សរសៃអាកទែថយចុះ ដែលធ្វើឱ្យការបញ្ជូនឈាមពីបេះដូងទៅក្នុងសរសៃអាកទែប្រព្រឹត្តទៅមិនប្រក្រតី ។ សំពាធឈាមនៅក្នុងសរសៃអាកទែក៏កើនឡើង ។ ដូចនេះជំងឺលើសឈាមពុំមានន័យថា បរិមាណឈាមកើននោះទេ ។ មូលហេតុដែលធ្វើឱ្យមានជំងឺលើសឈាមកើតឡើង គឺការបរិភោគអាហារសម្បូរជាតិខ្លាញ់ និងអាហារប្រៃ ។ ការជក់បារី ការផឹកស្រា និងធាត់ហួសក៏នាំឱ្យសំពាធឈាមកើនឡើងដែរ ។

## 5. ជំងឺទឹកនោមផ្អែម

ជំងឺទឹកនោមផ្អែមគឺជាជំងឺដែលបរិមាណគ្លុយកូសក្នុងឈាមលើស ហើយត្រូវបញ្ចេញចោលតាមទឹកនោម ។ នេះគឺជារោគសញ្ញានៃជំងឺទឹកនោមផ្អែម ដែលមិនមែនជារោគសញ្ញានៃជំងឺប្រដាប់ទឹកនោមទេ ។ ជំងឺទឹកនោមផ្អែមបណ្ដាលមកពីលំពែងបញ្ចេញអរម៉ូនអាំងស៊ុយលីនមិនគ្រប់គ្រាន់ ។

## 6. ជំងឺបេះដូងនិងសរសៃឈាម

ជំងឺបេះដូង ជាជំងឺមួយដែលច្រើនកើតមានចំពោះមនុស្សចាស់ ហើយគេច្រើននិយាយជាទូទៅដោយភ្ជាប់ជាមួយបញ្ហានៃបេះដូងនិងសរសៃឈាម ។ ជំងឺនេះកើតមានឡើងដោយសារបញ្ហាជាច្រើនរួមមានបញ្ហាសម្ពាធឈាមឡើងខ្ពស់ ការបាត់បង់ភាពយឺតរបស់សរសៃអាកទែ និងការគាំងបេះដូងជាដើម ។ បេះដូង ជាសរីរាង្គមួយសំខាន់ក្នុងប្រដាប់រង្វង់ឈាម ។ បេះដូងបញ្ជូនឈាមទៅគ្រប់កោសិកាតាមរយៈសរសៃឈាម ហើយឈាមនាំសារធាតុចិញ្ចឹម និងអុកស៊ីសែនទៅចិញ្ចឹមកោសិកា ។ ខាងក្រោមនេះជាបញ្ហាដែលបណ្ដាលឱ្យកើតជំងឺបេះដូង ។

- ការបាត់បង់ភាពយឺតរបស់សរសៃអាកទែ ឬអាកតេរីយ៉ូសក្លេរ៉ូស៊ីស (Arteriosclerosis)បណ្តាលមកពីសរសៃអាកទែឡើងក្រាស់ ហើយមិនមានភាពយឺត ។ ម្យ៉ាងទៀត វាបណ្តាលមកពីមានជាតិកូឡេស្តេរ៉ុល ឬខ្លាញ់កកនៅក្នុងសរសៃអាកទែ ដែលនាំឱ្យស្ទះចរន្តឈាម (អាថេរ៉ូសក្លេរ៉ូស៊ី) (Atherosclerosis) ។
- ការឈឺចាប់ក្នុងដើមទ្រូង បណ្តាលមកពីបេះដូងមិនបានទទួលឈាមគ្រប់គ្រាន់ ។
- ការគាំងបេះដូង បណ្តាលមកពីការកកស្ទះក្នុងសរសៃឈាម ឬការដាច់សរសៃឈាមដែលធ្វើឱ្យឈាមមិនអាចហូរចូលបេះដូងបាន ។
- ស្ត្រូក (Stroke)បណ្តាលមកពីខួរក្បាលមិនបានទទួលឈាមគ្រប់គ្រាន់ដោយសារការស្ទះឬដាច់សរសៃឈាម ។

កត្តាសំខាន់បណ្តាលឱ្យកើតជំងឺបេះដូងមាន ការជក់បារី ការលើសទម្ងន់ និងការមិនបានហាត់ប្រាណឱ្យបានទៀតទាត់ ។

### 6.1. ការជក់បារី

នៅក្នុងផ្សែងបារីមានសារធាតុពុលជាច្រើន ដែលអាចបណ្តាលឱ្យមានជំងឺបេះដូង ជំងឺដាច់សរសៃឈាមក្នុងខួរក្បាល ជំងឺក្រិនសរសៃឈាម និងជំងឺផ្សេងៗជាច្រើនទៀត ។ ដូចនេះការជក់បារីបង្កើនអត្រាអ្នកជំងឺបេះដូង ជំងឺសួត សរសៃឈាមនិងជំងឺខួរក្បាល ។

### 6.2. ការបរិភោគ

ការបរិភោគអាហារច្រើនប្រភេទ ហើយក្នុងរបបអាហារនោះត្រូវមានបន្លែ ផ្លែឈើ និងគ្រាប់ធញ្ញជាតិទាំងអស់អាចកាត់បន្ថយជំងឺសរសៃឈាម ជំងឺលើសឈាម និងជំងឺបេះដូងបាន ។ ម្យ៉ាងទៀតការតមអាហារមួយចំនួនជាកត្តាមួយសំខាន់ ដែលនាំឱ្យមានការកាត់បន្ថយជាតិសូដ្យូម និងខ្លាញ់ក្នុងអាហារ ព្រោះការបរិភោគអាហារច្រើនមិនមែនសុទ្ធតែល្អ និងចាំបាច់ទេ ។

### 6.3. លំហាត់ប្រាណ

សកម្មភាពមួយចំនួនដូចជាការហែលទឹក ការជិះកង់ ការរត់ ការដើរកំសាន្តជាវិធីល្អមួយនៃលំហាត់ប្រាណ ។ ការធ្វើលំហាត់ប្រាណទៀងទាត់ជួយកាត់បន្ថយនូវជំងឺបេះដូង ។

## 7. ជំងឺមហារីក

ជំងឺមហារីកជាជំងឺដែលបណ្តាលមកពីការលូតលាស់ខុសធម្មតានៃកោសិកាណាមួយ ហើយបង្កើតបានជាសំណុំកោសិកាហៅថាដុំ ដុំនេះគឺជាមហារីក ។ ដុំមហារីកនេះអាចរីករាលដាលពេញទាំងសារពាង្គកាយតាមផ្លូវឈាម និងទឹករងៃដែលបណ្តាលឱ្យខូចសរីរាង្គដទៃទៀត ។

មូលហេតុចម្បងដែលបង្កឱ្យមានជំងឺមហារីកគឺ កាំរស្មី X និងកាកសំណល់គីមីក្នុងបរិស្ថាន ។ ម្យ៉ាងទៀតការជក់បារីគឺជាមូលហេតុមួយបណ្តាលឱ្យកើតមហារីកសួតផងដែរ ។ គេអាចការពារជំងឺនេះបានចំពោះករណីមួយចំនួន ដូចជាការមិនជក់បារី និងចៀសវាងការបរិភោគអាហារដែលមានខ្លាញ់ច្រើន និងការផឹកស្រា ។ ម្យ៉ាងទៀត មិនគួរគប្បី :

- បរិភោគខ្លាញ់ច្រើន ព្រោះវាអាចបណ្តាលឱ្យកើតជំងឺមហារីកស្រទាប់ពោះវៀន ជំងឺមហារីកដោះ និងសរីរាង្គដទៃទៀតដែលត្រួតពិនិត្យដោយអរម៉ូន ។
- សេពគ្រឿងញៀនដូចជាស្រា បារី អាចបណ្តាលឱ្យកើតជំងឺមហារីកមាត់ បំពង់ក សួត ។
- ប្រើកាំរស្មី X ច្រើនហួសក្នុងការព្យាបាលជំងឺ វាក៏បណ្តាលឱ្យកើតជំងឺមហារីកផងដែរ ។

**មេរៀនសង្ខេប**

- ជំងឺមិនឆ្លងជាជំងឺដែលមិនបង្កដោយមេរោគ ហើយជំងឺនេះមិនឆ្លងពីមនុស្សម្នាក់ទៅម្នាក់ទៀតឡើយ ។
- ជំងឺមិនឆ្លងដែលគេតែងតែជួបប្រទះមានជំងឺបេះដូង ទឹកនោមផ្អែម លើសឈាម មហារីក
- ដើម្បីការពារ និងកាត់បន្ថយជំងឺមិនឆ្លងខាងលើយើងត្រូវមានវិធានការខ្លះៗដូចជា
  - បញ្ឈប់ការជក់បារី ការប្រើគ្រឿងញៀន និងគ្រឿងស្រវឹង ។
  - តមអាហារមួយចំនួនដែលមានជាតិ ស្ករ ប្រៃ និងខ្លាញ់ច្រើន ។
  - បរិភោគបន្លែ ផ្លែឈើ និងគ្រាប់ធញ្ញជាតិ ។
  - ធ្វើលំហាត់ប្រាណទៀងទាត់ ។

## ? សំណួរ

1. ចូររៀបរាប់ជំងឺមិនឆ្លងខ្លះៗដែលប្អូនបានស្គាល់ ។
2. តើជំងឺមហារីកជាអ្វី ? ហេតុអ្វីបានជាមានជំងឺនេះ ?
3. តើប្អូនត្រូវធ្វើបែបណាដើម្បីកាត់បន្ថយ និងបង្ការជំងឺមហារីក ?
4. ដើម្បីកាត់បន្ថយជំងឺធាត់បាន តើយើងត្រូវធ្វើដូចម្តេច ?
5. តើជំងឺលើសឈាមបណ្តាលមកពីអ្វី ?
6. តើរោគសញ្ញានៃជំងឺទឹកនោមផ្អែមជារោគសញ្ញានៃជំងឺប្រដាប់ទឹកនោមឬទេ ?
7. តើជំងឺទឹកនោមផ្អែមបណ្តាលមកពីអ្វី ?
8. ដើម្បីកុំឱ្យជំងឺបេះដូងនិងសរសៃឈាមរិតតែធ្ងន់ធ្ងរថែមទៀត តើយើងត្រូវចៀសវាងទម្លាប់អ្វីខ្លះ ?

## សំណួរបញ្ចប់ជំពូកទី៤

I ចូរគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវ

1. រូបធាតុវីរុសមាន

☐ ក. ហ្សែនយ៉ូ ☐ ខ. ផ្លាសែល

☐ គ. សំបកប្រូតេអ៊ីន ☐ ឃ. ភ្នាសកោសិកា

2. ជំងឺដែលបង្កដោយវីរុសមាន

☐ ក. អុតស្វាយ ☐ ខ. របេង

☐ គ. ស្រែង ☐ ឃ. គ្រុនចាញ់

3. ភ្នាក់ងារបង្ករោគមួយប្រភេទដែលធ្វើឱ្យការរំលាយអាហារប្រព្រឹត្តទៅមិនល្អជា

☐ ក. អាមីប ☐ ខ. សាឌីយ៉ា

☐ គ. បាក់តេរី ☐ ឃ. ផ្លាស្មូដ្យូម

4. ប្រភេទជំងឺមិនឆ្លងមាន

☐ ក. លើសឈាម ☐ ខ. ជំងឺផ្តែផ្តួត

☐ គ. ជំងឺគ្រុនស្វិតដៃជើង ☐ ឃ. ជំងឺកញ្ជ្រិល

5. ជំងឺកាមរោគមួយប្រភេទដែលអាចបង្កឱ្យមានជំងឺមហារីកប្រដាប់បន្តពូជគឺ

☐ ក. ជំងឺស្វាយ ☐ ខ. ជំងឺសិរមាន់

☐ គ. ជំងឺប្រមេះទឹកបាយ ☐ ឃ. ជំងឺសង្វារ

6. មេរោគអេដស៍ឆ្លងខ្លាំងជាងគេបំផុតនៅក្នុង

☐ ក. ដំណាក់តែសឈាមវិជ្ជមាន ☐ ខ. ដំណាក់ចំហ (ផ្ទុកមេរោគអេដស៍)

☐ គ. ដំណាក់ជំងឺអេដស៍ ☐ ឃ. ដំណាក់ទាំងអស់ខាងលើ ។

7. មេរោគអេដស៍មានលទ្ធភាពឆ្លងខ្លាំងជាងគេបំផុតតាមរយៈ

☐ ក. ការរួមភេទនៅជាមួយដៃគូក្រៅផ្ទះ គ្មានស្រោមអនាម័យ

☐ ខ. ការរួមភេទជាមួយអ្នកមានជំងឺផ្សេងៗ

☐ គ. ការរួមភេទជាមួយអ្នកផ្ទុកមេរោគអេដស៍ដោយគ្មានស្រោមអនាម័យ

☐ ឃ. ការរួមភេទជាអចិន្ត្រៃយ៍នៅផ្ទះ

8. ការបញ្ចូលឈាមដែលបណ្តាលឱ្យឆ្លងមេរោគអេដស៍ខ្លាំងជាងគេគឺ

☐ ក. ឈាមមានផ្ទុកមេរោគអេដស៍ ☐ ខ. ឈាមមិនបានត្រួតពិនិត្យ

☐ គ. ឈាមរបស់អ្នកមានជំងឺផ្សេងៗ ☐ ឃ. ឈាមម្តាយនិងឈាមកូន

9. ការប្រើឧបករណ៍ទម្លុះស្បែកដែលបណ្តាលឱ្យឆ្លងមេរោគអេដស៍ខ្លាំងជាងគេ :

☐ ក. ម្ជុលចាក់ថ្នាំពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត

☐ ខ. ម្ជុលចាក់ថ្នាំពីអ្នកផ្ទុកមេរោគអេដស៍ទៅអ្នកជា

☐ គ. ម្ជុលចាក់ថ្នាំជាអចិន្ត្រៃយ៍

☐ ឃ. ថ្ងៃឡាម កាំបិតកោរ ឧបករណ៍ស្រួចៗ

10. មេរោគអេដស៍ឆ្លងពីម្តាយទៅកូនខ្លាំងជាងគេគឺនៅពេល :

☐ ក. ពពោះឬនៅក្នុងផ្ទៃ ☐ ខ. សម្រាលកូន

☐ គ. បំបៅដោះកូន ☐ ឃ. ទាំងអស់ខាងលើ

II ចូរបំពេញល្បះខាងក្រោម

1. បាក់តេរីគ្មានណ្វៃយ៉ូ វាមានតែ .................. ដែលផ្តុំគ្នាត្រង់ផ្នែកកណ្តាលរបស់កោសិកា ។

2. បាក់តេរីឱ្យទោសផលិតជាតិពុលនៅក្នុងអាហារដែលធ្វើឱ្យអាហារផ្អូម ហើយបង្កទុក្ខទោសពេលបរិភោគ ។ ជាតិពុលនោះឈ្មោះថា .................... ។

3. អាមីបជាប្រភេទ ............................ផ្លាស់ទីដោយជើងបញ្ឆោត ។

4. ផ្លាស្មូដ្យូមជាប្រភេទស្ប៉័រ៉ូសូអ៊ែដែលបង្កជំងឺ ........................ ដល់មនុស្សតាមរយៈមូសដែកគោលញី ។

5. ជំងឺកាមរោគដែលមានដុះសាច់ពក ហើយរីកកាន់តែធំឡើងៗ ដោយពកខ្លះមានរាងមូល ពកខ្លះទៀតរាងដូចផ្កាស្ពៃ ហៅថា ...................... ។

6. មេរោគអេដស៍ឆ្លងពីម្ដាយទៅកូនពេល ............... ។ យើងអាចដឹងថា មនុស្សម្នាក់ផ្ទុកមេរោគអេដស៍ តាមរយៈការ ...................... ។

III សំណួរ

1. តើប្អូនត្រូវអនុវត្តដូចម្ដេចខ្លះ ដើម្បីចៀសវាងជំងឺឆ្លង ?
2. ដូចម្ដេចហៅថា ជំងឺកាមរោគ ?
3. តើជំងឺកាមរោគដែលគេប្រទះឃើញញឹកញាប់ជាងគេមានប្រភេទអ្វីខ្លះ ? ចូររៀបរាប់ ។
4. តើជំងឺកាមរោគដែលមិនបានព្យាបាលអាចឱ្យមានផលវិបាកអ្វីខ្លះ ចំពោះស្ត្រី បុរស និងទារក ?
5. តើជំងឺអ្វីដែលកំពុងរាតត្បាតចំពោះយុវវ័យ ហើយរាជរដ្ឋាភិបាលយើងកំពុងចាត់វិធានការទប់ស្កាត់ ?
6. តើក្រោយពីមេរោគអេដស៍ចូលក្នុងខ្លួន វាយាយីសារពាង្គកាយយ៉ាងដូចម្ដេច ?
7. ចូររៀបរាប់ពីមូលហេតុដែលជំងឺបេះដូងនិងសរសៃឈាមកើតមានឡើង ។
8. តើយើងមានវិធីអ្វីដើម្បីកាត់បន្ថយនូវជំងឺបេះដូងនិងសរសៃឈាម ?
9. មូលហេតុអ្វីដែលបណ្ដាលឱ្យសរសៃអាកទែបាត់បង់នូវភាពយឺត ?
10. តើជំងឺអេដស៍មានរោគសញ្ញាដូចម្ដេចខ្លះ ?
11. ហេតុអ្វីបានជាមេរោគអេដស៍ឆ្លងតាមការរួមភេទខ្លាំងជាងគេ(នៅកម្ពុជា) ?
12. ហេតុអ្វីបានជាជំងឺអេដស៍មិនអាចឆ្លងតាមរយៈការប្រស្រ័យទាក់ទងជាសាធារណៈ ដូចជាការរៀនសូត្រ បំពេញការងារតាមគ្រួសារ និងសង្គម ?
13. តើវិធានការបង្ការជំងឺអេដស៍ណាមួយមានប្រសិទ្ធភាពបំផុតសម្រាប់យុវវ័យ ?
14. តើជំងឺអេដស៍និងជំងឺកាមរោគដូចគ្នាដែរឬទេ ?
15. តើនៅដំណាក់កាលដំបូងនៃជំងឺអេដស៍ អ្នកផ្ទុកមេរោគអេដស៍មានរោគសញ្ញាចម្បងអ្វីខ្លះ ?
16. នៅពេលអ្នកមានរបួសឬមានគ្រោះថ្នាក់រហូតហូរឈាម ហេតុអ្វីបានជាអ្នកជួយសង្គ្រោះត្រូវមានបម្រុងប្រយ័ត្ន ដូចជាត្រូវពាក់ស្រោមដៃសិនមុននិងចាប់កាន់ ?

# ជំពូកទី 5 ផលប៉ះពាល់បណ្ដាលមកពីមនុស្សលើស្ថានប្រព័ន្ធធម្មជាតិ

**សកម្មភាពរបស់មនុស្សនិងការបំពុលបរិស្ថាន**




ការបំពុលទឹក ការបំពុលដី ការបំពុលខ្យល់

សកម្មភាពជាច្រើនរបស់មនុស្សធ្វើឱ្យបរិស្ថានខូចខាតយ៉ាងធ្ងន់ធ្ងរនិងជាប្រចាំ ។ ផលប៉ះពាល់ដែលបណ្ដាលមកពីសកម្មភាពរបស់មនុស្សដូចជា ការបំពុលទឹក ដី ខ្យល់ ការបំផ្លាញធនធានធម្មជាតិ បានបណ្ដាលឱ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស ។ ដូចនេះមនុស្សត្រូវកាត់បន្ថយឬបញ្ឈប់សកម្មភាពទាំងនោះជាបន្ទាន់ ពីព្រោះការបំពុលបានក្លាយទៅជាបញ្ហាមួយដ៏ធ្ងន់ធ្ងរដែលកំពុងគំរាមកំហែងដល់អាយុជីវិតមនុស្ស សត្វ រុក្ខជាតិនៅលើផែនដី ។ ដើម្បីរួមចំណែកការពារបរិស្ថាន តើយើងត្រូវប្រឈមនឹងការដោះស្រាយបញ្ហារបស់មនុស្សយ៉ាងដូចម្ដេច ?

# 1 អំពើរបស់មនុស្សលើបរិស្ថាន

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីអំពើផ្សេងៗរបស់មនុស្សលើបរិស្ថាន
- ❑ បកស្រាយពីឥទ្ធិពលផ្សេងៗបណ្តាលមកពីទង្វើរបស់មនុស្ស
- ❑ រួមចំណែកក្នុងការថែរក្សាបរិស្ថាន ។

កំណើនប្រជាជនលើពិភពលោកកើនឡើងយ៉ាងរហ័សក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលបណ្តាលឱ្យមានការបង្កើនផលិតផលសំខាន់ៗជាច្រើនដូចជាបន្លែ ផ្លែឈើ គ្រាប់ធញ្ញជាតិ សាច់សត្វ ... ។ ក្រៅពីអាហារ មនុស្សត្រូវការជម្រក សម្ភារៈសំណង់ ឥន្ធនៈ (រ៉ែថ្យូងថ្ម ប្រេងកាត លោហៈ ...) ។ តើតម្រូវការទាំងអស់នេះមានឥទ្ធិពលដល់បរិស្ថានដូចម្តេច ?

## 1. អំពើរបស់មនុស្ស

ពេលយើងនិយាយពីបរិស្ថានគឺសំដៅទៅលើភាវៈមានជីវិតនិងភាវៈគ្មានជីវិតដែលនៅជុំវិញខ្លួនយើងដូចជាដើមឈើ ខ្យល់ ទឹក ទន្លេ ដី សត្វ ... ។ មនុស្សរស់នៅអាស្រ័យដោយផ្ទាល់ឬមិនផ្ទាល់ទៅនឹងបរិស្ថានជុំវិញខ្លួន ។ ការប្រើប្រាស់ធនធានធម្មជាតិសំខាន់ៗសម្រាប់ការរស់នៅរបស់មនុស្សមានឥទ្ធិពលខុសៗគ្នាទៅលើបរិស្ថាន តាមប្រភេទនៃទង្វើរបស់មនុស្ស ។ ទង្វើទាំងនោះមាន :

- ការទាញយកផលពីធម្មជាតិ ដូចជាត្រី រ៉ែ ព្រៃឈើ ទឹកស្អាត ត្បូង ... ។
- ការបោះចោលសំណល់ទៅក្នុងបរិស្ថានវិញដូចជាកាកសំណល់ រឹង រាវ ឧស្ម័ន ។
- ការបំផ្លាញជម្រកធម្មជាតិ ដូចជាការកាប់ឆ្ការព្រៃដើម្បីធ្វើផ្លូវថ្នល់ លំនៅឋាន ឬរោងចក្រ ... ។

## 2. ឥទ្ធិពលនៃទង្វើរបស់មនុស្ស

នៅពេលដែលមនុស្សរាប់ពាន់លាននាក់នៅលើពិភពលោក ទាញយកផលពីធម្មជាតិ ហើយបោះចោលវត្ថុខ្លះទៅក្នុងបរិស្ថានវិញនិងបំផ្លាញជម្រកធម្មជាតិ ដើម្បីផលិតរបស់អ្វីផ្សេងទៀតនោះ ពិភពនៃធម្មជាតិនឹងអាចប្រែប្រួលយ៉ាងខ្លាំង ។

## 2.1. ការទាញយកផលពីបរិស្ថាន



រូបទី 1.1 : ការទាញយកផលត្បូងពីអណ្តូងរ៉ែនៅប៉ៃលិន



រូបទី 1.2 : ការទាញយកផលត្រីពីបឹងទន្លេសាប

ធនធានធម្មជាតិដូចជាខ្យល់ ទឹក ដីដែលមានដំណើរការជាវដ្តតាមធម្មជាតិ នឹងមិនបាត់បង់ជារៀងរហូតឡើយ ។ ចំណែករុក្ខជាតិ និងសត្វបន្តពូជដោយខ្លួនឯង វាទាំងនេះនឹងបាត់បង់ ប្រសិនបើយើងប្រើប្រាស់វាខ្ជះខ្ជាយ ឬលឿនជាងការកកើតឡើងវិញ ។ សកម្មភាពផ្សេងៗរបស់មនុស្សបានបំផ្លាញធនធានទាំងនេះបន្តិចម្តងៗ ។ ឧទាហរណ៍ការនេសាទត្រីច្រើនហួសដូចជា នេសាទត្រីនៅរដូវត្រីពង ការប្រើប្រាស់ឧបករណ៍នេសាទហាមឃាត់ ការប្រើខ្សែភ្លើងឆក់ត្រីដែលបណ្តាលឱ្យត្រីតូចៗងាប់ពាយ ។ ការធ្វើប្រមាញ់ហួសកំណត់ដែលធ្វើឱ្យសត្វព្រៃមួយចំនួនផុតពូជ ។

រ៉ែមួយចំនួន ដូចជារ៉ែថ្មថ្ម ឧស្ម័នធម្មជាតិ ប្រេងកាត លោហៈ រ៉ែត្បូង មិនអាចកើតឡើងវិញភ្លាមៗបានទេ ។ ធនធានទាំងនេះត្រូវបានបង្កើតនៅក្រោមលក្ខខណ្ឌពិសេសផ្សេងៗ ។ ការកកើតធនធានធម្មជាតិទាំងនេះត្រូវការរយៈពេលរាប់លានឆ្នាំ ប៉ុន្តែមនុស្សបានប្រើប្រាស់វាអស់យ៉ាងឆាប់រហ័ស និងមិនយូរប៉ុន្មាន វានឹងត្រូវហិនហោចអស់គ្មានសល់ ។

## 2.2. ការបោះចោលកាកសំណល់




រូបទី 1.3 : ការបោះចោលកាកសំណល់

កំណើនចំនួនប្រជាជនមានន័យថា កាកសំណល់ឧស្សាហកម្ម កសិកម្ម និងកាកសំណល់ផ្ទះបាយ(មនុស្ស)កាន់តែមានច្រើន ហើយតម្រូវការកន្លែងចោលកាកសំណល់ក៏ច្រើនដែរ ។ សំរាមដែលយើងបោះចោលរាល់ថ្ងៃមានកាកសំណល់ ម្ហូបអាហារ សំបកកំប៉ុង ថង់ប្លាស្ទិច សំបកដប ក្រដាសកាសែត ។ សំរាមនិងសំណល់ជាបញ្ហាមួយធំបំផុតដែលត្រូវការកន្លែងទុកដាក់វាដោយមិនធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន ។

ប្រសិនបើយើងបោះចោលសំរាម និងកាកសំណល់ពាសពេញវាល នៅពេលវាបំបែក ធាតុគីមីពុលគ្រប់ប្រភេទនឹងហូរចូលក្នុងដីនិងទឹក ។ ធាតុគីមីភាគច្រើន ហូរចូលទៅក្នុងទឹកសម្រាប់ប្រើប្រាស់ដែលធ្វើឱ្យប៉ះពាល់ដល់សុខភាព មនុស្ស សត្វ ទាំងឡាយដែរ ។

## ២.៣. ការបំផ្លាញជម្រកធម្មជាតិ

កាលណាប្រជាជនកាន់តែច្រើន នាំឱ្យមានការអភិវឌ្ឍទីក្រុងបន្ថែមទៀត ។ មនុស្សត្រូវការកាប់ព្រៃឈើ ដើម្បីយកកន្លែងធ្វើកសិដ្ឋាន សង់ផ្ទះ ធ្វើរោងចក្រ សាងសង់ទំនប់ទឹក ធ្វើផ្លូវ ... ។ ការធ្វើបែបនេះជាការបំផ្លាញជម្រកធម្មជាតិ ។ សកម្មភាពទាំងនេះនៅតែបន្តជំនួសកន្លែងនៃសហគមន៍ធម្មជាតិ ។ ការដកយកប្រភេទភាវៈរស់ជាច្រើន(សត្វនិងរុក្ខជាតិ) ចេញពីស្ថានប្រព័ន្ធអាចធ្វើឱ្យស្ថានប្រព័ន្ធនោះគ្មានតុល្យភាព ។ ប្រសិនបើស្ថានប្រព័ន្ធច្រើនខូចខាត មណ្ឌលជីវៈក៏ខូចខាតដែរ ។



*រូបទី ១៤ : ការកាប់ព្រៃឈើដើម្បីយកដីធ្វើផ្លូវគមនាគមន៍*

ជានិច្ចជាកាល ទង្វើរបស់មនុស្សតែងតែធ្វើឱ្យបរិស្ថានប្រែប្រួល ។ ពីអតីតកាល ឥទ្ធិពលនៃទង្វើនេះមានតែនៅក្នុងតំបន់តូចៗ ក៏ប៉ុន្តែបច្ចុប្បន្ននេះបច្ចេកវិទ្យាទំនើបអាចឱ្យមនុស្សបំផ្លាញប្រទេសឬក៏ពិភពលោកទាំងមូលបានយ៉ាងឆាប់រហ័ស ។ ***ឧទាហរណ៍*** បច្ចេកវិទ្យាទំនើបអាចឱ្យមនុស្សកាប់ព្រៃឈើយ៉ាងលឿនក្នុងរយៈពេលដ៏ខ្លី រហូតធ្វើឱ្យអាកាសធាតុប្រែប្រួលដែលបណ្តាលឱ្យប្រែប្រួលរបបទឹកភ្លៀង សូម្បីតែនៅកន្លែងឆ្ងាយពីព្រៃឈើក៏ដោយ ។ ដូចនេះយើងត្រូវតែចូលរួមទប់ស្កាត់ភាពបង្កក្តីអន្តរាយចំពោះបរិស្ថានធម្មជាតិឱ្យបាន ដោយយើងត្រូវយល់ពីបញ្ហាបរិស្ថាននិងការគ្រប់គ្រងបញ្ហានេះឱ្យបានសមស្រប ។

## មេរៀនសង្ខេប

- កំណើនប្រជាជនលើពិភពលោក បណ្ដាលឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើធនធានធម្មជាតិ ។ ដើម្បីការរីកចម្រើនរបស់សង្គម មនុស្សបានធ្វើសកម្មភាពផ្សេងៗដែលប៉ះពាល់ដល់សុខភាព ។
- មនុស្សបានបោះចោលសំរាមពាសវាលពាសកាល ។ នៅពេលវាបំបែក ធាតុគីមីពុលនិងហូរចូលទៅក្នុងដី ហើយខ្លះទៀតហូរចូលទៅក្នុងទឹកសម្រាប់ប្រើប្រាស់ដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពមនុស្ស សត្វ ។
- មនុស្សកែប្រែធម្មជាតិនៅជុំវិញខ្លួនតាមច្រើនរូបភាពដូចជា ការកាប់ព្រៃឈើ ការសាងសង់ទំនប់ ការធ្វើផ្លូវ ការបង្កើតទីក្រុងថ្មី ឬពង្រីកទីក្រុង ដែលនាំទៅរកការបាត់បង់ដីស្រែនិងស្ថានប្រព័ន្ធសំខាន់ៗសម្រាប់រុក្ខជាតិនិងសត្វជាច្រើន ។

## ? សំណួរ

1. ចូររកឧទាហរណ៍ធនធានធម្មជាតិដែលអាចកើតឡើងវិញនិងធនធានធម្មជាតិដែលមិនអាចកើតឡើងវិញឱ្យបាន 10 យ៉ាងតិច ។
2. រវាងធនធានធម្មជាតិទាំងពីរប្រភេទខាងលើ តើធនធានធម្មជាតិប្រភេទណាមួយដែលមនុស្សទាញយកផលមកប្រើប្រាស់ច្រើនជាងគេ ? ហេតុអ្វី ?
3. ចូរចែកធនធានធម្មជាតិដែលមានក្នុងដី លើដី ក្នុងទឹក ក្នុងព្រៃ និងក្នុងអាកាសទៅតាមប្រភេទ ។
4. ប្រៀបធៀបពីធនធានធម្មជាតិកើតឡើងជាថ្មីនិងធនធានធម្មជាតិដែលមិនអាចកើតឡើងជាថ្មី ដោយលើកឧទាហរណ៍មកបញ្ជាក់ ។
5. ដើម្បីកាត់បន្ថយល្បឿននៃការបាត់បង់ធនធានធម្មជាតិដែលមិនអាចកើតឡើងជាថ្មី តើត្រូវមានវិធានការអ្វីខ្លះ ?
6. តើមូលហេតុអ្វីខ្លះដែលបណ្ដាលឱ្យធនធានធម្មជាតិ ត្រូវទទួលរងការបំផ្លិចបំផ្លាញជាខ្លាំង ?
7. ដើម្បីរក្សាធនធានធម្មជាតិឱ្យមានស្ថិរភាព តើអ្នកត្រូវធ្វើដូចម្ដេច ?
8. ឧទាហរណ៍ជាក់ស្ដែងដូចជា ធនធានកើតឡើងជាថ្មីមានប្រភេទសត្វឬរុក្ខជាតិ ដែលកំពុងវិនាសសាបសូន្យ តើធនធានទាំងនេះអាចជំនួស ឬបង្កើតឡើងបានជាថ្មីដែរឬទេ ?

# 2 ការបំពុលបរិស្ថាន

**ចប់មេរៀននេះ សិស្សអាច**

- បង្ហាញពីប្រភពដែលនាំឱ្យមានកង្វក់ទឹក កង្វក់ខ្យល់និងកង្វក់ដី និងផលប៉ះពាល់ទៅលើមនុស្ស
- សង្កេតនិងវិភាគប្រភេទកង្វក់ទាំងឡាយ
- ជ្រើសរើសមធ្យោបាយមកអនុវត្តដើម្បីកាត់បន្ថយភាពកង្វក់ពីបរិស្ថាន
- ចូលរួមរកវិធីផ្សេងៗដើម្បីធ្វើឱ្យបរិស្ថានកាន់តែល្អប្រសើរឡើងសម្រាប់គ្រួសារនិងសហគមន៍ ។

ការបំពុលគឺជាការធ្វើឱ្យកង្វក់ដល់បរិស្ថាន ដោយសារសំណល់ផ្សេងៗដែលទុកដាក់មិនបានត្រឹមត្រូវ ។ សំណល់ ដែលទុកដាក់មិនបានត្រឹមត្រូវ អាចបំពុលខ្យល់ បំពុលទឹក និងបំពុលដី ។ វាគឺជាសកម្មភាពរបស់មនុស្សដែលបណ្តាលឱ្យមានសំណល់កើតមានឡើង ហើយសំណល់ទាំងនោះធ្វើឱ្យមានការបំពុល ។ នៅពេលដែលមានការបំពុលនេះកើតឡើង បរិស្ថានក៏ក្លាយទៅជាកខ្វក់មិនមានជាសុខភាព ដែលមានគ្រោះថ្នាក់ដល់មនុស្ស សត្វ និងរុក្ខជាតិនៅជុំវិញ ។

## 1. កខ្វក់ខ្យល់

ភាគច្រើនកង្វក់ខ្យល់មាននៅទីក្រុង ។ វាកើតឡើងពីចំហេះធ្យូងថ្ម ប្រេងកាត និងឧស្ម័នធម្មជាតិ ។ ធាតុកខ្វក់មួយចំនួនដូចមានខាងក្រោមនេះ ៖

### 1.1. ធាតុកខ្វក់

#### ក. កាបូនអុកស៊ីត

កាបូនអុកស៊ីតមានកាបូនម៉ូណូអុកស៊ីត ($CO$) និងកាបូនឌីអុកស៊ីត ($CO_2$)

- **កាបូនម៉ូណូអុកស៊ីត** ($CO$) : កើតឡើងពីចំហេះប្រេងឥន្ធនៈនិងធ្យូងថ្ម ។ ឧស្ម័ននេះប្រមូលផ្តុំនៅតាមផ្លូវតូចចង្អៀតក្នុងក្រុង ជាពិសេសនៅតាមផ្លូវដែលមានអាគារខ្ពស់ៗអមសងខាង ។ កំហាប់ខ្ពស់នៃឧស្ម័ននេះកើតមាននៅពេលដែលចរាចរណ៍កកស្ទះច្រើន ។ កាបូនម៉ូណូអុកស៊ីត($CO$) ងាយភ្ជាប់ជាមួយអេម៉ូក្លូប៊ីនរបស់គោលិកាក្រហមនិងបន្ថយសមត្ថភាពដឹកនាំអុកស៊ីសែនរបស់អេម៉ូក្លូប៊ីន ។ ឧស្ម័ននេះបណ្តាលឱ្យឈឺក្បាល វិលមុខ និងមានអារម្មណ៍ងងុយដេក ។ កំណើន $CO$ តែបន្តិចក្នុងបរិយាកាស អាចមានឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់អ្នកជក់បារីដែលមានកំហាប់

CO ខ្ពស់ស្រាប់ក្នុងឈាមរបស់ពួកគេ និងអ្នកជំងឺបេះដូង ដែលបណ្តាលឱ្យមានបញ្ហាអាក្រក់កើតឡើងនៅពេលពួកគាត់ស្ថិតនៅកន្លែងមានឧស្ម័ននេះយូរ ។

- កាបូនឌីអុកស៊ីត ឬ ឧស្ម័នកាបូនិច ($CO_2$) : កើតឡើងពីចំហេះប្រេងកាត ធ្យូងថ្ម ឧស្ម័នធម្មជាតិនិងការដុតព្រៃ ដែលផ្តល់ជាថាមពលចាំបាច់សម្រាប់ដំណើរការយានយន្ត ចំអិនអាហារ និងរោងចក្រអគ្គិសនី ។ $CO_2$ ជាអ្នកទប់បង្ខាំងកម្តៅនៅក្នុងបរិយាកាសដែលជាប្រភពនៃបម្រែបម្រួលអាកាសធាតុនិងការកើនឡើងកម្តៅនៃផែនដី ។

## ខ. ស្ពាន់ធ័រឌីអុកស៊ីត ($SO_2$)




*រូបទី 2.1 : កំណាភ្លៀងអាស៊ីត*

សារធាតុពុល $SO_2$ ភាយចេញពីចំហេះធ្យូងថ្មឬផលិតផលប្រេងកាតដែលមានស្ពាន់ធ័រ ។ ឧស្ម័ននេះបណ្តាលឱ្យមានជំងឺផ្លូវដង្ហើម ឬជំងឺបេះដូងរ៉ាំរ៉ៃ ។ ដំណកដង្ហើមនៅកន្លែងដែលមានកំហាប់ $SO_2$ តែតិចតួចក្តី ក្នុងរយៈពេលពីរបីឆ្នាំអាចបណ្តាលឱ្យមានជំងឺស្ទួតនិងរលាកទងសួត ។ ពេលដែល $SO_2$ មានប្រតិកម្មជាមួយទឹក បង្កើតបានជាសារធាតុពុលមួយទៀតគឺអាស៊ីតស៊ុលផួរិច $H_2SO_4$ ឬភ្លៀងអាស៊ីត ។

## គ. អាសូតម៉ូណូអុកស៊ីត (NO)

អាសូតម៉ូណូអុកស៊ីតជាឧស្ម័នដែលផលិតឡើងដោយប្រតិកម្មគីមីរវាងអាសូតនិងអុកស៊ីសែន ។ រោងចក្រនិងរថយន្តដែលបញ្ចេញឧស្ម័នក៏ផលិតអាសូតម៉ូណូអុកស៊ីតដែរ ។ ឧស្ម័ននេះ បង្អាក់ការលូតលាស់របស់រុក្ខជាតិនិងបន្ថយសមត្ថភាពដឹកនាំអុកស៊ីសែនរបស់ឈាម ។ NO ជាឧស្ម័នពុលដែលបណ្តាលឱ្យរលាកផ្លូវដង្ហើម ។ NO មានឥទ្ធិពលទៅលើស្រទាប់អូសូនដោយ NO មួយម៉ូលេគុលអាចបំផ្លាញអូសូនមួយម៉ូលេគុលបាន ។ NO ជាមួយទឹកបង្កើតបានជាអាស៊ីតនីទ្រិចរាវ ($HNO_3$) ដែលផ្តល់អាស៊ីតដល់ទឹកភ្លៀងដែរ ។

## ឃ. សំណ

សំណ គឺជាសារធាតុមួយទៀតដែលគេរកឃើញនៅក្នុងសមាសធាតុខ្យល់ ។ សំណកើតចេញពីផ្សែងយានយន្តដែលប្រើប្រេងសាំងមានសមាសធាតុសំណ ។ សំណជាធាតុទីមួយដែលចូលទៅក្នុងខ្សែអាហារនៃលំដាប់រុក្ខជាតិ ។ កម្រិតខ្ពស់របស់សំណនៅក្នុងខ្លួនមនុស្សធ្វើឱ្យឈឺក្បាល ដេកមិនលក់ កង្វះឈាមក្រហម និងរលូតកូន ។ ជាពិសេសចំពោះកុមារដែលរស់នៅកន្លែងមានចរាចរណ៍កកកុញងាយនិងរងគ្រោះជាងគេ ព្រោះវាបំផ្លាញការលូតលាស់ផ្នែកស្មារតី ជំងឺតាំងបេះដូង និងដាច់សរសៃឈាមក្នុងខួរក្បាល ។

## ង. អ៊ីដ្រូកាបួ



រូបទី 2.2 : ការបញ្ចេញឧស្ម័នមេតានដោយសារការចិញ្ចឹមសត្វនិងការធ្វើស្រែដែលមានទឹកជាប្រចាំ

អ៊ីដ្រូកាបួគឺជាក្រុមសារធាតុសរីរាង្គដូចជាមេតាន ($CH_4$) បង់សែន ($C_6H_6$) ។ មេតាន ($CH_4$) ជាឧស្ម័នដែលកើតចេញពីសត្វ រុក្ខជាតិ ការជីកយករ៉ែ ការធ្វើស្រូវក្នុងស្រែដែលមានទឹកជាប្រចាំ កន្លែងចោលកាកសំណល់និងសំណល់ទឹកសំអុយពីគេហដ្ឋាន ។ អ៊ីដ្រូកាបួមួយចំនួនមានឥទ្ធិពលទៅលើសុខភាពមនុស្សដូចជា ការបំផ្លាញផ្លូវដង្ហើមនិងការបង្កជំងឺមហារីក ។ មេតានក៏ចូលរួមធ្វើឱ្យអាកាសធាតុប្រែប្រួលដែរ ។

ចំពោះសត្វទំពាអៀងភាគច្រើន អាហារមិនអាចរំលាយបានទេមុនពេលវាឡើងជូរ ។ ដំណើរឡើងជូរបណ្ដាលឱ្យមានការបញ្ចេញឧស្ម័នមេតានពីសត្វទៅក្នុងបរិយាកាស ។

ការបញ្ចេញឧស្ម័នមេតានកើនឡើង នៅពេលសារធាតុសរីរាង្គនៃរុក្ខជាតិក្នុងស្រែ រលួយក្រោមអំពើរបស់បាក់តេរី ។ ឧស្ម័នមេតានភាគច្រើនភាយចេញពីដីស្រែទៅក្នុងបរិយាកាសតាមរយៈការផុយរលួយនៃរុក្ខជាតិ ដែលមាននាទីដូចជាបំពង់នាំឧស្ម័នពីដីទៅក្នុងបរិយាកាស ។ ភាគច្រើន មេតានត្រូវបានបញ្ចេញពីដំណាំស្រូវនៅតំបន់ដីសើម ។

ទឹកន្លែងចាក់សំណល់ក៏ជាប្រភពនៃឧស្ម័នមេតានដែរ ។ ដំណើររលួយនៃសារធាតុសរីរាង្គដូចជាសំណល់អាហារ រុក្ខជាតិ សត្វ បញ្ចេញមេតានដែលភាយទៅក្នុងបរិយាកាស ។

## 1.2. ផលប៉ះពាល់នៃកង្វក់ខ្យល់



រូបទី 2.3 : ការបញ្ចេញផ្សែងពុលពីរោងចក្រនិងយានយន្ត

កង្វក់ខ្យល់បណ្តាលមកពីសកម្មភាពរបស់មនុស្ស ។ រោងចក្រ សហគ្រាសយានយន្ត និងម៉ាស៊ីនគ្រឿងចក្រដែលប្រើដោយចំហេះប្រេងឥន្ធនៈ បានបញ្ចេញឧស្ម័នកាបូនិច ឧស្ម័នស្ពាន់ធ័រអុកស៊ីតនិងឧស្ម័នផ្សេងៗទៀតទៅក្នុងបរិយាកាស ។ ឧស្ម័នទាំងនេះអាចបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្សនិងសត្វ ។

បាតុភូតបីដែលកើតឡើងពីកង្វក់ខ្យល់គឺ ភ្លៀងអាស៊ីត ការបំផ្លាញស្រទាប់អូសូន និងបម្រែបម្រួលអាកាសធាតុ ។

### ក. ភ្លៀងអាស៊ីត

ឧស្ម័នផ្សេងៗដូចជាឧស្ម័នស្ពាន់ធ័រអុកស៊ីតនិងអាសូតអុកស៊ីតត្រូវបានបញ្ចេញទៅក្នុងបរិយាកាសដោយរោងចក្រ យានយន្ត ។ ឧស្ម័នទាំងនេះរលាយនៅក្នុងទឹកភ្លៀង ហើយបង្កើតជាភ្លៀងអាស៊ីត ។ ភ្លៀងអាស៊ីតបំផ្លាញរុក្ខជាតិ ព្រោះសារធាតុចិញ្ចឹមពីដី បង្អាក់ការភ្ជាប់អាសូតដោយបាក់តេរី សម្លាប់ត្រីក្នុងទឹក ។ លើសពីនេះភ្លៀងអាស៊ីតបំផ្លាញសំណង់អគារផ្សេងៗ ។

### ខ. ការបំផ្លាញស្រទាប់អូសូន




រូបទី 2.4 : កាំរស្មីស្វាយអ៊ុលត្រា (UV) និងស្រទាប់អូសូន

សារធាតុគីមីមួយចំនួនដូចជា ក្លរ៉ូភ្លុយអរ៉ូកាបូន($CFC_s$ )ដែលមាននៅក្នុងកំប៉ុងបាញ់ថ្នាំ ក្នុងម៉ាស៊ីនត្រជាក់និងក្នុងទូទឹកកកត្រូវបញ្ចេញចោលទៅក្នុងបរិយាកាស ។ ផ្នែកខាងលើនៃបរិយាកាសដែលព័ទ្ធជុំវិញផែនដី មានឧស្ម័នអូសូនមួយស្រទាប់ ។ ឧស្ម័ននេះការពារមិនឱ្យកាំរស្មីស្វាយអ៊ុលត្រា(UV) របស់ព្រះអាទិត្យចាំងចូលទៅដល់ផែនដីបាន ។ ប៉ុន្តែ $CFC_s$ មានប្រតិកម្មជាមួយអូសូននៅក្នុងស្រទាប់អូសូន ហើយធ្វើឱ្យស្រទាប់នេះក្លាយទៅជាស្តើងដែលអាចឱ្យកាំរស្មីស្វាយអ៊ុលត្រាជ្រៀតចូលទៅដល់ផែនដីកាន់តែច្រើនឡើងៗ ។ ជារួមការខូចខាតស្រទាប់អូសូន នាំឱ្យរុក្ខជាតិនិងដំណាំនានាត្រូវរងការបំផ្លាញយ៉ាងខ្លាំង ព្រោះកំណើនកម្រិតកាំរស្មីស្វាយអ៊ុលត្រានឹងធ្វើឱ្យខូចស្លឹកបណ្តាលឱ្យថយ

ចុះនូវប្រសិទ្ធភាពនៃការធ្វើរស្មីសំយោគនិងការស្រូបយកទឹកពីដី ។ ការបំផ្លាញឬស្សីតុងរុក្ខជាតិដែលជាគ្រឹះនៃខ្សែអាហារនៅសមុទ្រ អាចនឹងបន្ថយនូវផលិតភាពមហាសមុទ្រយ៉ាងច្រើន ។ ជារួមការខូចខាតស្រទាប់អូសូនអាចបន្ថយផលិតភាពនៃដំណាំសំខាន់ៗច្រើនមុខនៅលើពិភពលោក ដែលបណ្តាលឱ្យមានបញ្ហាដល់ការផ្គត់ផ្គង់អាហារ ។ ចំពោះមនុស្សបណ្តាលឱ្យមានកំណើននៃការកើតជំងឺស្បែកបាំងភ្នែកនិងជំងឺមហារីកស្បែក ។

## គ. បម្រែបម្រួលអាកាសធាតុ

ការដុតព្រៃ ការដុតរ៉ែផ្សេងៗដូចជាប្រេងកាត ធ្យូងថ្ម ឧស្ម័នធម្មជាតិ នៅក្នុងរោងចក្រនិងយានយន្តផ្សេងៗ បានបញ្ចេញឧស្ម័នកាបូនិចនិងអាសូតអុកស៊ីតទៅក្នុងបរិយាកាស ។ កាលណាបរិមាណឧស្ម័នកាបូនិច ($CO_2$) និងអាសូតអុកស៊ីតកើនឡើង វានឹងត្រូវរក្សាទុកក្នុងខ្យល់ដែលនឹងធ្វើឱ្យផែនដីកើនកម្តៅជាងមុន ។ កំណើនសីតុណ្ហភាពមានឥទ្ធិពលទៅលើផលិតផលស្បៀង កម្ពស់ទឹកភ្លៀង របាយទឹកភ្លៀង ព្រមទាំងធ្វើឱ្យទឹកសមុទ្រឡើងខ្ពស់ ហើយបណ្តាលឱ្យមានទឹកជំនន់និងភាពរាំងស្ងួតកើតមានជាញឹកញាប់ ។

## 1.3. ការទប់ស្កាត់កង្វក់ខ្យល់

ចំពោះទីក្រុង ឬប្រទេសមួយចំនួន គេអាចចាត់វិធានការខ្លះៗសម្រាប់ទប់ស្កាត់កង្វក់ខ្យល់ដូចជា :

- ប្រើប្រាស់តែប្រេងឥន្ធនៈគ្មានសំណ ។
- ប្រើផលិតផលប្រេងកាតដែលមានជាតិស្ពាន់ធ័រទាប ។
- ដាំដើមឈើតាមបណ្តោយផ្លូវដែលមានចរាចរណ៍ ព្រោះអាចស្រូបយកធូលី កាបូនម៉ូណូអុកស៊ីត និងកាត់បន្ថយសូរស័ព្ទ ។
- ត្រូវដាក់តំបន់ឧស្សាហកម្មនិងទីកន្លែងចាក់សំរាមនៅឆ្ងាយពីទីក្រុង ។ បើអាចធ្វើបានគួរធ្វើតំបន់ឧស្សាហកម្មនិងកន្លែងចាក់សំរាមនៅក្រោមចរន្តខ្យល់ ។
- សាងសង់ផ្លូវធំៗជាមួយអាគារទាបៗព្រោះផ្លូវតូចៗដែលមានអាគារខ្ពស់ៗនៅសងខាងផ្លូវអាចឱ្យមានការប្រមូលផ្តុំសារធាតុពុលកិរិតខ្ពស់ ។
- ប្រើប្រាស់ឧបករណ៍បំប្លែងកាតាលីកម្ម(Catalytc Converter) ដើម្បីជួយដល់ការត្រួតពិនិត្យការបញ្ចេញសំណល់ឧស្ម័នកាបូនម៉ូណូអុកស៊ីត និងអ៊ីដ្រូកាបួ ។

## 2. កខ្វក់ទឹក



រូបទី 25 : កខ្វក់ទឹក

ទឹកជាសារធាតុមានសារប្រយោជន៍សម្រាប់ជីវិត ។ ទឹកគ្របដណ្ដប់ 70% នៃផ្ទៃដី ប៉ុន្តែធនធានទឹកសាបមានតិចតួចប៉ុណ្ណោះទេ ដែលអាចទាញយកមកប្រើប្រាស់បាន ។

នៅតំបន់ជាច្រើននៃពិភពលោក ធនធានទឹក ត្រូវបានគេប្រើប្រាស់ហួសកម្រិត ។ លើសពីនេះធនធានទឹកកំពុងរងការបំពុលដោយសារសំណល់ឧស្សាហកម្ម ទឹកលូសំអុយ សំណល់គីមី និងសារធាតុចិញ្ចឹម(បណ្ដាលមកពីលំហូរកសិកម្ម) ។ សារធាតុបំពុលទឹកបានធ្លាក់ចូលក្នុងទឹកស្ទឹង ទន្លេ បឹងបួ ឬការធ្លាយកំពប់ប្រេងកើតមានឡើងដោយនាវាដឹកប្រេងធំៗនៅក្នុងសមុទ្រ ។ ធាតុកខ្វក់ដែលជាប្រភពនៃការបំពុលទឹកមានដូចខាងក្រោមនេះ ។

### 2.1. សំណល់សរីរាង្គ

សំណល់សរីរាង្គភាគច្រើនជាសំណល់ដែលចេញពីរុក្ខជាតិនិងសត្វ ។ តាមធម្មតា សំណល់ទាំងនេះជាសំណល់អាចបំបែកធាតុបានដោយបាក់តេរី ។ ទឹកសំអុយនិងកាកសំណល់ដែលផលិតចេញពីរោងចក្រផលិតស្បៀងអាហារនិងរោងចក្រផលិតក្រដាស ជាប្រភពនៃធាតុកខ្វក់នៅក្នុងទឹក ។ ប្រសិនបើសំណល់សរីរាង្គមានបរិមាណធំធេង បរិមាណអុកស៊ីសែនរលាយក្នុងទឹកត្រូវថយចុះយ៉ាងខ្លាំងដោយតម្រូវការសម្រាប់បំបែកធាតុទាំងនេះ ។ កង្វះអុកស៊ីសែនធ្វើឱ្យត្រីនិងសារពាង្គកាយក្នុងទឹកផ្សេងៗទៀតងាប់ ។

សំណល់សរីរាង្គខ្លះជាសារធាតុចិញ្ចឹមរបស់រុក្ខជាតិ(ជីកសិកម្ម) ប៉ុន្តែបើបរិមាណនៃសារធាតុទាំងនេះច្រើនហួសហេតុពេកនោះ វាបង្អាក់ ឬបញ្ឈប់ការលូតលាស់របស់សារាយនិងរុក្ខជាតិទឹកផ្សេងៗទៀត ។ នៅពេលរុក្ខជាតិទាំងនេះងាប់ វានឹងធ្លាក់ទៅបាតបឹងដែលអាចបណ្ដាលឱ្យជម្រៅនិងទំហំបឹងថយចុះបាន ។

## 2.2. សំណល់អសរីរាង្គ

សំណល់អសរីរាង្គបណ្ដាលមកពីការជីករ៉ែនិងការចាក់ចោលកាកសំណល់សារធាតុខនិជទៅក្នុងផ្លូវទឹក ហើយសំណល់ខ្លះមានជាតិបារតនិងសំណ ដែលជាធាតុពុលចំពោះមនុស្សនិងសត្វ ។

បម្រើបម្រាស់ថ្នាំសម្លាប់សត្វល្អិតចង្រៃបណ្ដាលឱ្យដីពុល បន្ទាប់មកទឹកភ្លៀងហូរនាំដីពុលចូលទៅក្នុងទឹក ។ ដំបូងបង្អស់ធាតុពុលមួយចំនួនបានជ្រាបចូលក្នុងសារពាង្គកាយរុក្ខជាតិទឹក ។ រុក្ខជាតិទឹកទាំងនេះត្រូវបានត្រីតូចៗស៊ី ។ បន្ទាប់មកត្រីតូចៗត្រូវត្រីធំៗស៊ីបន្ត ហើយស្ទាំងអាចចាប់ត្រីធំៗស៊ីបន្តទៀត ។ ដូចនេះរុក្ខជាតិទឹកដែលមានផ្ទុកសារធាតុពុលបានបញ្ជូនបរិមាណសារធាតុពុលទាំងនេះដល់អ្នកស៊ីបន្តបន្ទាប់តាមខ្សែអាហារ ។




*រូបទី 26 : សារធាតុពុលត្រូវបានបញ្ជូនតាមខ្សែអាហារក្នុងមជ្ឈដ្ឋានទឹក*

## 2.3. ការឡើងកម្ដៅ

ការឡើងកម្ដៅកើតមានឡើង នៅពេលដំណើរការផលិតរបស់រោងចក្រមានទីតាំងនៅតាមដងទន្លេ ឬក្បែរបឹងដែលបានបញ្ចេញទឹកសំណល់មានសីតុណ្ហភាពខ្ពស់ចូលទៅក្នុងប្រព័ន្ធផ្លូវទឹក ។ ការឡើងកម្ដៅអាចបណ្ដាលឱ្យត្រីងាប់ពាយអស់ ព្រោះវាមិនអាចទ្រាំទ្រនឹងកម្ដៅនេះបាន ។ ម្យ៉ាងទៀតទឹកក្ដៅមិនអាចចាប់យកអុកស៊ីសែនបានច្រើនជាងទឹកត្រជាក់ទេ ដូចនេះសារពាង្គកាយរស់នៅក្នុងទឹកគ្មានអុកស៊ីសែន បន្ទាប់មកវាអាចងាប់ដោយថប់ដង្ហើម ។

## 2.4. ភ្នាក់ងារបង្ករោគ

កង្វក់ទឹកភាគច្រើនទាក់ទងនឹងមីក្រូសារពាង្គកាយ ដែលបង្ករោគដូចជាបាក់តេរី អាមីប វីរុស និងដង្កូវបរាសិត ។ ភាគច្រើននៃជំងឺធ្ងន់ធ្ងរមានប្រភពចេញពីកង្វក់ទឹក ដូចជាអាសន្នរោគ រាគមួល ជំងឺថ្លើម គ្រុនពោះវៀន ជំងឺគ្រុនស្វិតដៃជើង ... ។

## 2.5. ការទប់ស្កាត់កង្វក់ទឹក

កង្វក់ទឹកបង្កគ្រោះថ្នាក់ដល់ជីវិតមនុស្សនិងសត្វ។ កង្វក់ទឹកបណ្តាលមកពីប្រភពជាច្រើន។ មធ្យោបាយសម្រាប់ទប់ស្កាត់កង្វក់ទឹកមាន ៖

- ការបង្កបង្កើនផល ៖ ចំពោះជីគីមីត្រូវប្រើក្នុងកម្រិតអប្បបរិមាបំផុត និងមិននៅក្បែរប្រភពទឹក (ស្ទឹង ព្រែក ទន្លេ...)។ ជីគីមីដែលប្រើនៅលើដីស្រែចំការ អាចហូរចូលទៅក្នុងប្រភពទឹក ហើយធ្វើឱ្យរុក្ខជាតិទឹកមានសារាយជាដើមនិងរុក្ខជាតិទឹកមួយចំនួនទៀតដុះលូតលាស់យ៉ាងលឿន ដែលធ្វើឱ្យប្រភពទឹករាប់រាក់ រីងស្ងួត និងធ្វើឱ្យទិន្នផលត្រីថយចុះ។ ការបំពុលប្រភពទឹកអាចឱ្យជីវិតសត្វព្រៃងាប់ថែមទៀតផង។ ថ្នាំសម្លាប់សត្វល្អិតធ្វើឱ្យត្រីនិងសត្វល្អិតដែលរស់នៅក្នុងទឹកងាប់បាន។ ត្រី គឺជាសត្វងាយរងគ្រោះបំផុត សូម្បីតែក្នុងបរិមាណថ្នាំសម្លាប់សត្វល្អិតតិចតួចក្នុងទឹកក៏ដោយ។
- សំណល់របស់មនុស្ស ៖ ក្នុងកាកសំណល់របស់មនុស្សមានធាតុពុលនិងភ្នាក់ងារបង្ករោគជាច្រើន។ វាជាការប្រសើរបំផុតក្នុងការសាងសង់បង្គន់អនាម័យ សម្រាប់កប់កាកសំណល់របស់មនុស្សទៅក្នុងដី ហើយត្រូវសង់ឱ្យឆ្ងាយពីអណ្តូងទឹក ស្រះទឹក និងស្ទឹង។
- ថង់ប្លាស្ទិចនិងសំណល់ផ្សេងៗទៀត ៖ សំណល់តាមផ្ទះផ្តល់នូវសារធាតុពុលដ៏គ្រោះថ្នាក់បំផុតនៅពេលវាបំបែក។ បើសិនជាមិនអាចបោះចោលឱ្យឆ្ងាយពីលំនៅដ្ឋានទេនោះ ត្រូវកប់វាឱ្យបានជ្រៅនិងឆ្ងាយពីអណ្តូងទឹក ស្រះទឹក និងស្ទឹង។
- ប្រេងម៉ាស៊ីនដែលបូមស្តារចេញពីយានយន្តនិងម៉ាស៊ីននានា ៖ ចៀសវាងការផ្លាស់ប្តូរប្រេងម៉ាស៊ីន គ្រឿងចក្រ និងត្រូវយកវាទៅចាក់ចោលឱ្យឆ្ងាយពីប្រភពទឹកមាន ស្រះ ទឹកស្ទឹង ឬអណ្តូងទឹក ហើយមិនត្រូវលាងយានយន្តនៅក្នុងបឹង ស្ទឹង ព្រែក ឬទន្លេឡើយ។
- សំណល់ពីរោងចក្រកែច្នៃ ៖ កាកសំណល់ពីរោងចក្រសិប្បកម្មនានានិងពីការរុករករ៉ែផ្សេងៗ អាចបំពុលទឹកស្ទឹង ព្រែក ទន្លេ សម្លាប់ត្រី និងគំរាមកំហែងដល់ជីវិតមនុស្សនិងសត្វដែលអាស្រ័យនឹងទឹកនោះ។

## 3. កខ្វក់ដី

សំរាមនិងកាកសំណល់គឺជាបញ្ហាធំមួយ។ បញ្ហាដែលធំបំផុតនោះគឺការរកកន្លែងទុកដាក់វាដោយមិនធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន។ នៅពេលមនុស្សពង្រាយសំរាមនៅលើដី បណ្តាលឱ្យដីក្លាយទៅជាកខ្វក់។ ពេលវាបំបែក គ្រប់ប្រភេទសារធាតុគីមីពុលទាំងអស់និងហូរចូលទៅក្នុងដី។ ធាតុគីមីទាំងនេះភាគច្រើនក៏ហូរចូលទៅក្នុងទឹកសម្រាប់ប្រើប្រាស់ដែរ ដែលធ្វើឱ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្សនិងសត្វទាំងឡាយ។

- សំណល់មួយចំនួនដូចជា ផលិតផលធ្វើពីឈើ អាហារ សំណល់សត្វរុក្ខជាតិ អាចរលួយក្រោយពីទុកចោលមួយរយៈ ។ សំណល់ទាំងនេះបំបែកដោយសារអំពើរបស់បាក់តេរី ។ ដូចនេះគេហៅវាថាជាសំណល់បំបែកបាន ។
- សំណល់មិនអាចបំបែកបានដូចជាអំបែងកែវ ប្លាស្ទិច លោហៈ ថ្នាំសម្លាប់សត្វល្អិត វាមិនអាចរលួយទេ ព្រោះបាក់តេរីមិនអាចបំបែកវាជាអាហារបាន ។ ដូចនេះគេហៅថាសំណល់បំបែកមិនបាន ។ ប្រសិនបើយើងចោលសំណល់នេះផ្ដេសផ្ដាស វានឹងស្ថិតនៅយូរលើដីរហូតដល់រាប់រយឬ រាប់ពាន់ឆ្នាំ ។ ម្យ៉ាងវិញទៀតសំណល់ទាំងនេះដូចជាថង់ប្លាស្ទិច អំបែងកែវជាដើម ធ្វើឱ្យស្ទះលូទឹកហើយការស្ទះនេះនាំឱ្យទឹកជ្រាបលិចផ្លូវ ។

# 4. ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃសំណល់

មនុស្សជាអ្នកបង្កើតសំណល់ ហើយមិនទុកដាក់ឱ្យបានត្រឹមត្រូវដែលបណ្ដាលឱ្យមានការបំពុលដល់បរិស្ថាន ។ មធ្យោបាយដែលល្អបំផុតសម្រាប់ការពារបរិស្ថានពីការបំពុលនេះ គឺត្រូវកាត់បន្ថយបរិមាណសំណល់ ដោយប្រើប្រាស់ឡើងវិញនិងការកែច្នៃសំណល់ ។

## 4.1. ការកាត់បន្ថយបរិមាណសំណល់

មធ្យោបាយកាត់បន្ថយបរិមាណសំណល់គឺ

- ចៀសវាងការប្រើប្រាស់ផលិតផលដែលបង្កើតសំរាមច្រើន ដូចជាកែវក្រដាស កែវជ័រ ចានជ័រ ដែកកេះ ជាពិសេសថង់ប្លាស្ទិចជាប្រភពសំរាមដ៏ចម្បង ។
- ចៀសវាងការទិញរបស់របរដោយខ្ចប់ថង់ប្លាស្ទិចដែលមិនអាចបំបែកធាតុបាន ។

## 4.2. ការប្រើប្រាស់ឡើងវិញ និងការកែច្នៃសំណល់

ការកែច្នៃ ឬការប្រើប្រាស់ឡើងវិញអាចកាត់បន្ថយនូវការបញ្ចេញសំណល់ទាំងស្រុង ។ រោងចក្រខ្លះធ្វើការកែច្នៃឬការប្រើប្រាស់ឡើងវិញនូវសំណល់ដែលមនុស្សបានបង្កើត ដើម្បីផលិតសម្ភារៈថ្មីៗជំនួសការនាំចូលនូវសម្ភារៈថ្លៃៗពីបរទេស ។

សំណល់ខ្លះដែលមនុស្សអាចយកទៅកែច្នៃ ឬប្រើប្រាស់ឡើងវិញ មានលោហៈគ្រប់ប្រភេទ សំណល់ប្រេងម៉ាស៊ីន ដបកែវ ដបប្លាស្ទិច និងសំណល់សរីរាង្គ ។ យើងអាចប្រើប្រាស់សំណល់ដែលយើងបង្កើតឡើងដោយខ្លួនឯងបាន ។

*ឧទាហរណ៍ :*

- លាងសំអាតដបប្លាស្ទិចដែលយើងប្រើប្រាស់រួចសម្រាប់ទុកដាក់ប្រើថ្ងៃក្រោយទៀតឱ្យបានច្រើនដងមុននិងបោះវាចោល ។
- សំបកកេសក្រដាសនិងថង់ប្លាស្ទិចខ្លះ អាចប្រើប្រាស់បានជាច្រើនដងមុននិងបោះវាចោល ។
- ធ្វើជីកំប៉ុស្តពីសំណល់សរីរាង្គដូចជាសំណល់ បន្លែ ផ្លែឈើ សំបកដូង សំបកពងមាន់ ... ។ ជីដែលផលិតបាន អាចយកមកប្រើប្រាស់សម្រាប់ដាំដំណាំផ្សេងៗ បានយ៉ាង ល្អប្រសើរ ។

## មេរៀនសង្ខេប

- ការបំពុល គឺជាការធ្វើឱ្យកខ្វក់ដល់បរិស្ថាន ដោយសារសំណល់ផ្សេងៗដែលទុកដាក់មិនបានត្រឹមត្រូវ ។
- សំណល់ដែលទុកដាក់មិនបានត្រឹមត្រូវ អាចធ្វើឱ្យមានកង្វក់ខ្យល់ កង្វក់ទឹក និងកង្វក់ដី ។
- នៅពេលផ្សែងនិងឧស្ម័នពុលផ្សេងៗភាយចូលក្នុងបរិយាកាស វាអាចបណ្ដាលឱ្យមានកង្វល់ខ្យល់ ។
- កាលណាមនុស្សបោះចោលសំណល់ចូលទៅក្នុងបឹងបួ ត្រពាំង ប្រឡាយ ព្រែក ស្ទឹង ទន្លេនានានិងមហាសមុទ្រ វានឹងបណ្ដាលឱ្យមានកង្វក់ទឹក ។
- នៅពេលមនុស្សបោះសំរាមចោលនៅលើដីឬពង្រាយសំរាម វានឹងបណ្ដាលឱ្យមានកង្វក់ដី ។
- បច្ចេបាយដែលល្អបំផុតសម្រាប់ការពារបរិស្ថានកុំឱ្យកខ្វក់គឺ ការកាត់បន្ថយបរិមាណសំណល់ដែលបង្កើតឡើងរៀងរាល់ថ្ងៃឱ្យថយចុះតិច ការកែច្នៃនិងការប្រើប្រាស់ឡើងវិញ ។

## ? សំណួរ

1 តើការបំពុលមានប៉ុន្មានប្រភេទ? អ្វីខ្លះ ?
2. ចូររកឧទាហរណ៍ពីប្រភេទនៃការបំពុលនីមួយៗ ។
3. តើប្រភពនៃការបំពុលខ្យល់នៅក្នុងសហគមន៍របស់ប្អូនជាអ្វី ?
4. តើផ្សែងដែលហុយចេញតាមបំពង់ផ្សែងវានឹងទៅទីណា ប្រសិនបើយើងដកដង្ហើមស្រូបយកផ្សែងនោះ ? តើវាប៉ះពាល់ដល់សុខភាពយើងដែរឬទេ ?
5. ទឹកដែលយើងឃើញថាថ្លាល្អ តើមានន័យថាមានសុវត្ថិភាពសម្រាប់ផឹកដែរឬទេ ?
6. តើមានមូលហេតុអ្វីខ្លះដែលបណ្ដាលឱ្យមានការបំពុលដី ?

## ? សំណួរបញ្ចប់ជំពូកទី៥

I ចូរគូសសញ្ញា ✓ ខាងដើមចម្លើយត្រឹមត្រូវ

1 ក្នុងចំណោមសារធាតុខាងក្រោម តើសារធាតុណាខ្លះដែលធ្វើឱ្យស្រទាប់អូសូនស្តើង ?

☐ ក. ឧស្ម័នកាបូនិច ☐ ខ. ក្លរ៉ូភ្លុយរ៉ូកាបូន

☐ គ. អាសូតម៉ូណូអុកស៊ីត ☐ គ. ស្ពាន់ធ័រឌីអុកស៊ីត

2. ដំណើររលួយនៃសារធាតុសរីរាង្គដូចជាសំណល់អាហារនៃរុក្ខជាតិនិងសត្វនៅកន្លែងចាក់សំណល់ជាប្រភពបញ្ចេញឧស្ម័នមួយប្រភេទចូលក្នុងបរិយាកាសគឺ :

☐ ក. មេតាន ☐ ខ. នីត្រូសែនអុកស៊ីត

☐ គ. ឧស្ម័នកាបូនិច ☐ ឆ. ស៊ុលផួឌីអុកស៊ីត

3. ការបញ្ចេញកាកសំណល់ពីរោងចក្រនិងលូទឹកសំអុយចូលទៅក្នុងជ្រោះ អូរ បឹង ស្ទឹង មហាសមុទ្រនាំឱ្យ :

☐ ក. កង្វក់ដី ☐ ខ. កង្វក់ខ្យល់

☐ គ. កង្វក់ទឹក ☐ ឃ. កង្វក់បរិស្ថាន

4. តើវិធីណាល្អជាងគេក្នុងការបោះចោលសំរាម ?

ក. សំណល់រឹងរាវចេញពីរោងចក្រ សិប្បកម្ម :

☐ ចោលឱ្យឆ្ងាយពីប្រភពទឹក ☐ បង្ហូរចូលក្នុងទឹក

☐ ជីកកប់ ☐ គរចោល

ខ. សំបកកង់ កង់ឡាន និងកង់ម៉ូតូ :

☐ ដុតចោល ☐ ជីកកប់

☐ បោះចូលក្នុងទន្លេ ☐ ច្នៃប្រើប្រាស់ឡើងវិញ

គ. សត្វកណ្តុរងាប់ :

☐ បោះចោលកណ្តាលថ្នល់ ☐ ចោលក្នុងគំនរសំរាម

☐ ជីកកប់ឱ្យឆ្ងាយពីប្រភពទឹក ☐ ដុត

5. ក្នុងចំណោមសារធាតុធ្វើឱ្យមានកង្វក់ទាំងឡាយ តើសារធាតុណាខ្លះ ដែលបណ្ដាលឱ្យមានភ្លៀងអាស៊ីត

☐ ក. កាបូនម៉ូណូអុកស៊ីត ☐ ខ. សមាសធាតុសំណ

☐ គ. ក្លរ៉ូភ្លុយរ៉ូកាបូន ☐ ឃ. ស្ពាន់ធ័រឌីអុកស៊ីត

II ចូរបំពេញចន្លោះនៃឃ្លាខាងក្រោមនេះឱ្យបានត្រឹមត្រូវ

1. ដំណើររលួយនៃសារធាតុសរីរាង្គនៅក្នុងគំនរសំរាមជាប្រភពបញ្ចេញឧស្ម័ន .............. ដែលភាយចូលក្នុងបរិយាកាស ។

2. ការបំពុលខ្យល់បណ្ដាលឱ្យមានបាតុភូតបីទៀតកើតឡើងគឺ .............. និង ........... ។

3. ឧស្ម័នស្ពាន់ធ័រឌីអុកស៊ីតនិងអាសូតអុកស៊ីតត្រូវបានបញ្ចេញពីរោងចក្រទៅក្នុងបរិយាកាស ។ ឧស្ម័នទាំងនេះរលាយទៅក្នុងទឹកហើយបង្កើតបានជា .......... ។

4. សារធាតុគីមីដែលធ្វើឱ្យស្រទាប់អូសូនស្តើងគឺ .......................... ។

5. មធ្យោបាយដែលល្អបំផុតសម្រាប់ការពារបរិស្ថានពីការបំពុលគឺត្រូវធ្វើការ ...... បរិមាណសំណល់ ....... និង ...... ។

III ចូរឆ្លើយទៅនឹងសំណួរខាងក្រោម

1. តើការកាប់ព្រៃថ្មី (ព្រៃមិនទាន់មានអ្នកកាប់ពីមុនមក)សម្រាប់យកដីធ្វើកសិកម្ម ជាប្រភេទទង្វើអ្វីរបស់មនុស្ស ?

2. តើការចាប់ត្រីច្រើនហួសហេតុពីបឹង ទន្លេ ជាប្រភេទទង្វើអ្វីរបស់មនុស្ស ?

3. តើការធ្វើឱ្យទឹកកខ្វក់ដែលបណ្ដាលមកពីសំណលរឹង រាវហូរចូលទៅក្នុងទន្លេ បឹងបួ សមុទ្រ ជាប្រភេទទង្វើអ្វីរបស់មនុស្ស ?

4. ហេតុអ្វីបានជាការចិញ្ចឹមសត្វទំពាអៀងនិងដំណាំស្រូវក្នុងស្រែមានទឹកជាប្រចាំ ជាប្រភពនៃការបញ្ចេញឧស្ម័នមេតានចូលទៅក្នុងបរិយាកាស ?

5. ហេតុអ្វីបានជាការបំបែកសំណល់សរីរាង្គនៅក្នុងទឹក ដោយសារបាក់តេរីបណ្ដាលឱ្យបរិមាណអុកស៊ីសែនថយចុះ ?

6. ហេតុអ្វីបានជាការបំពុលទឹកដោយកម្ដៅ បណ្ដាលឱ្យសារពាង្គកាយដែលរស់នៅក្នុងទឹកគ្មានអុកស៊ីសែនដកដង្ហើម ហើយវាអាចងាប់ដោយថប់ដង្ហើម ?

7. តើឧស្ម័នពុលអ្វីខ្លះ ដែលធ្វើឱ្យផែនដីឡើងកម្តៅ ?

8. ដូចម្តេចហៅថាសំណល់បំបែកធាតុបាន ? ចូររកឧទាហរណ៍ ។

9. ដូចម្តេចហៅថាសំណល់បំបែកធាតុមិនបាន ? ចូររកឧទាហរណ៍ ។

10. តើធាតុកខ្វក់អ្វីខ្លះ ដែលធ្វើឱ្យមានបម្រែបម្រួលអាកាសធាតុ ?

11. បម្រែបម្រួលអាកាសធាតុបណ្តាលមកពីអ្វី ?

12. តើប្អូនត្រូវចិញ្ចឹមសត្វទំពាអៀងឬទេ ទោះបីជាប្អូនដឹងថា ឧស្ម័នមេតានដែលបំផ្លាញសុខភាពមនុស្សកើតឡើងដោយការចិញ្ចឹមសត្វទាំងនេះក៏ដោយ ? ហេតុអ្វី ?

13. ហេតុអ្វីបានជាកន្លែងចាក់សំណល់ជាប្រភពនៃឧស្ម័នមេតាន ?

14. នៅពេលមនុស្សធ្វើឱ្យមានកង្វក់ខ្យល់ តើមានបាតុភូតអ្វីខ្លះដែលកើតឡើងបាន ?

15. តើបាតុភូតនីមួយៗដែលបណ្តាលមកពីកង្វក់ខ្យល់ បង្កឱ្យមានគ្រោះថ្នាក់អ្វីខ្លះ ?

16. ប្អូនដឹងហើយថា សំណល់សរីរាង្គជាសារធាតុចិញ្ចឹមរបស់រុក្ខជាតិ(ជីកសិកម្ម) ។ ប្រសិនបើបរិមាណសារធាតុទាំងនេះច្រើនហួស តើវាបណ្តាលឱ្យមានផលប៉ះពាល់ដល់ត្រីនិងសារពាង្គកាយផ្សេងទៀតដែលរស់នៅក្នុងទឹកដែរឬទេ ? ហេតុអ្វី ?

17. តើបណ្តាលមកពីអ្វីបានជាមានសារធាតុអសរីរាង្គដែលភ្លៀងនាំហូរចូលទៅក្នុងទឹក ? តើសំណល់អសរីរាង្គនេះជាសារធាតុយ៉ាងដូចម្តេច ?

18. ចូរពន្យល់ពីការបញ្ជូនសារធាតុពុលក្នុងទឹកដល់អ្នកស៊ីបន្តបន្ទាប់ ដោយលើកឧទាហរណ៍មកបញ្ជាក់ ។